# ពាក្យប្រារព្ធ

ព្រះពុទ្ធសាសនា មានអាយុវែងឆ្ងាយមកដល់សព្វថ្ងៃនេះ ចាប់តាំងពីព្រះពុទ្ធអង្គទ្រង់បរិនិព្វានទៅ ដោយមនុស្សជំនាន់ក្រោយៗ មានការរក្សាទ្រទ្រង់បន្តជាប់មកមិនដាច់ ។ ដោយសទ្ធាជឿមាំក្នុងពាក្យទូន្មានរបស់ព្រះអង្គ យ៉ាងនេះហើយ ទើបធ្វើឱ្យព្រះពុទ្ធសាសនាឋិតនៅជាទីពឹងទីរលឹកដ៏ប្រសើរ សម្រាប់ពុទ្ធសាសនិកជន និងដើម្បីបង្ហាននាំយកមកជាគោលក្នុងការរៀបចំដំណើរជីវិត ប្រព្រឹត្តទៅបានយ៉ាងល្អបំផុត រហូតមក ។

**ជីវិតដែលគ្រប់គ្រងដោយព្រះធម៌ ជាជីវិតសុខស្ងប់** គួរចែកពេលវេលាមួយចំណែកឱ្យបានប្រាកដ សម្រាប់សិក្សានូវព្រះធម៌ ព្រោះមនុស្សយើងមានទាំងរូបកាយ មានទាំងវិញ្ញាណ ។

មាសប្រាក់កែវកង វត្ថុសម្ភារៈ ជាគ្រឿងសម្រាប់រក្សារូបកាយ តែព្រះធម៌ជាគ្រឿងសម្រាប់រក្សានូវវិញ្ញាណ បើវិញ្ញាណខ្វះព្រះធម៌ហើយ វិញ្ញាណមិនអាចស្វែងរកបាននូវសេចក្ដីសុខ ដ៏ពិតប្រាកដឡើយ ។





ព្រះធម៌ដែលព្រះសម្មាសម្ពុទ្ធទ្រង់នាំយកមកសម្ដែង គឺ ព្រះអង្គទ្រង់ស្វែងរកដោយការបំពេញបារមីដ៏ក្រៃលែង និងយូរអស់កាលជាអង្វែង ដូច្នេះទើបពុទ្ធបរិស័ទ គួរស្ដាប់ គួររៀន គួរទ្រទ្រង់ គួរពិចារណា និងគួរសិក្សាបដិបត្តិកម្ចាត់កិលេស សម្រេចនូវប្រយោជន៍ ទាន់ពេលដែលព្រះធម៌នៅមាននេះឯង ។

ព្រះធម៌ស្ថិតនៅក្នុងព្រះត្រៃបិដក ១១០ ក្បាល រួមទាំងបាលី និងសេចក្ដីប្រែ សូមពុទ្ធបរិស័ទបាននូវឧបនិស្ស័យដាស់តឿនហើយគិតឃើញថា « មិនត្រូវឱ្យនៅតែក្នុងទូនោះឡើយ គួរឱ្យនៅក្នុងចិត្ត ប្រព្រឹត្តទៅព្រមជាមួយគ្នានឹងដំណើរនៃជីវិត » ។

សៀវភៅ **សិក្សាសុភាសិត** នេះ គ្រាន់តែជាការប្រមូលយកនូវចំណុចខ្លះៗ ពីព្រះត្រៃបិដក ដែលសមគួរដល់ការសិក្សាទាំងបព្វជិត ទាំងគ្រហស្ថ ហើយនឹងបានពីរោះក្នុងអត្ថនៃសុភាសិតតាមសតិបញ្ញារៀងៗខ្លួន ។

សូមឱ្យព្រះធម៌ស្ថិតក្នុងចិត្តរបស់ពុទ្ធបរិស័ទជានិច្ចនិរន្តរ៍

សូមចិត្តនៃពុទ្ធបរិស័ទ មានព្រះធម៌ជាអាហារប្រចាំថ្ងៃ ។

**ថ្ងៃសុក្រ ៥ រោច ខែជេស្ឋ ព.ស.២៥៥០**

**ខ្ញុំព្រះករុណា ខ្ញុំបាទ ប៊ុត សាវង្ស**

# សារបណ្ណ

ឈ្មោះអត្ថបទ ទំព័រ


១.គាថារបស់ព្រះសីលវត្ថេរ ........................................ ១
២.គាថារបស់ព្រះអធិមុត្តត្ថេរ ....................................... ៥
៣.គាថារបស់ព្រះរដ្ឋបាលត្ថេរ ..................................... ១២
៤.គាថារបស់ព្រះអង្គុលិមាលត្ថេរ ................................ ២១
៥.គាថារបស់ព្រះនាងសុមេធាថេរី ................................ ២៩
៦.រាហុលសូត្រ ........................................................ ៥៣
៧.ជរាសូត្រ ............................................................. ៥៦
៨.អត្តទណ្ឌសូត្រ ....................................................... ៦០
៩.អាឡវិកាសូត្រ ....................................................... ៦៨
១០.ចាលាសូត្រ ....................................................... ៧១
១១.វជិរាសូត្រ ....................................................... ៧៤
១២.អាយាចនសូត្រ ................................................ ៧៧
១៣.ធនញ្ជានីសូត្រ ................................................ ៨៥
១៤.អក្កោសកសូត្រ ................................................ ៨៩
១៥.កសិសូត្រ ....................................................... ៩៤
១៦.ឧទយសូត្រ ....................................................... ៩៩







១៧.សុភាសិតសូត្រ ............................................... ១០៣
១៨.បុនព្វសុសូត្រ ............................................... ១០៧
១៩.អាឡវកសូត្រ ............................................... ១១១
២០.សុទត្តសូត្រ ............................................... ១១៨
២១.អនាថបិណ្ឌិកសូត្រ ............................................... ១២១
២២.សិវសូត្រ ............................................... ១២៣
២៣.ធម្មបទគាថា យមកវគ្គទី ១ ................................. ១២៧
២៤.ធម្មបទគាថា អប្បមាទវគ្គទី ២ ............................. ១៣៦
២៥.ធម្មបទគាថា ចិត្តវគ្គទី ៣ ................................. ១៤២
២៦.ធម្មបទគាថា បុប្ផវគ្គទី ៤ ................................. ១៤៧
២៧.ធម្មបទគាថា ពាលវគ្គទី ៥ ................................. ១៥៤
២៨.ធម្មបទគាថា បណ្ឌិតវគ្គទី ៦ ................................. ១៦១
២៩.ធម្មបទគាថា អរហន្តវគ្គទី ៧ ................................. ១៦៧
៣០.ធម្មបទគាថា សហស្សវគ្គទី ៨ ................................. ១៧២
៣១.ធម្មបទគាថា បាបវគ្គទី ៩ ................................. ១៧៩
៣២.ធម្មបទគាថា ទណ្ឌវគ្គទី ១០ ................................. ១៨៥
៣៣.ធម្មបទគាថា ជរាវគ្គទី ១១ ................................. ១៩២
៣៤.ធម្មបទគាថា អត្តវគ្គទី ១២ ................................. ១៩៨

## ១-គាថារបស់ព្រះសីលវត្ថេរ
### បិដកលេខ ៥៧ ទំព័រ ២៨

សីលមេវិធ សិក្ខេថ    អស្មឹ លោកេ សុសិក្ខិតំ
សីលំ ហិ សព្វសម្បត្តឹ    ឧបនាមេតិ សេវិតំ ៕

បុគ្គលគប្បីសិក្សានូវសីល ឱ្យជាសីលដែលខ្លួនសិក្សាល្អ ហើយក្នុងលោកនេះ ព្រោះថា សីលដែលបុគ្គលសេពហើយ រមែងបង្អោនមកនូវសម្បត្តិទាំងពួង ។

សីលំ រក្ខេយ្យ មេធាវី    បត្ថយានោ តយោ សុខេ
បសំសំ វិត្តិលាភញ្ច    បេច្ច សគ្គេ បមោទនំ ៕

ជនអ្នកមានប្រាជ្ញា កាលចង់បាននូវសេចក្តីសុខ ៣ យ៉ាង គឺ សេចក្តីសរសើរ ១ ការបាននូវសេចក្តីត្រេកអរ ១ ការលះលោកនេះទៅហើយ រីករាយក្នុងឋានសួគ៌ ១ គប្បីរក្សានូវសីល ។

សីលវា ហិ ពហូ មិត្តេ    សញ្ញមេនាធិគច្ឆតិ
ទុស្សីលោ បន មិត្តេហិ    ធំសតេ បាបមាចរំ ៕





ពិតណាស់ បុគ្គលអ្នកមានសីល រមែងបាននូវមិត្តទាំងឡាយច្រើន ដោយការសង្រួម ចំណែកបុគ្គលទ្រុស្តសីល កាលប្រព្រឹត្តអាក្រក់ រមែងឃ្លាតចាកមិត្តទាំងឡាយ ។

អវណ្ណញ្ច អកិត្តិញ្ច    ទុស្សីលោ លភតេ នរោ
វណ្ណំ កិត្តឹ បសំសញ្ច    សទា លភតិ សីលវា ៕

ជនទ្រុស្តសីល រមែងបាននូវទោសផង នូវតំណិះដំណៀលផង ឯជនអ្នកមានសីល រមែងបាននូវគុណផង នូវកិត្តិសព្ទផង នូវសេចក្តីសរសើរផង សព្វៗកាល ។

អាទិ សីលំ បតិដ្ឋា ច    កល្យាណានញ្ច មាតុកំ
បមុខំ សព្វធម្មានំ    តស្មា សីលំ វិសោធយេ ៕

សីលជាខាងដើម ជាទីតាំង ជាមេនៃកល្យាណធម៌ និងជាប្រធាននៃធម៌ទាំងពួង ព្រោះហេតុនោះ បុគ្គលគប្បីជម្រះសីល ។

វេលា ច សំវរំ សីលំ    ចិត្តស្ស អភិហាសនំ
តិត្ថញ្ច សព្វពុទ្ធានំ    តស្មា សីលំ វិសោធយេ ៕

សីលជាច្រាំង ជាទំនប់ ជាគ្រឿងញុំាងចិត្តឱ្យរីករាយ ទាំង

ជាកំពង់របស់ព្រះពុទ្ធគ្រប់ព្រះអង្គ ព្រោះហេតុនោះ បុគ្គលគប្បីជម្រះនូវសីល ។

**សីលំ ពលំ អប្បដិមំ    សីលំ អាវុធមុត្តមំ**
**សីលំ អាភរណំ សេដ្ឋំ    សីលំ កវចមព្ភុតំ ។**

សីលជាកម្លាំងរកអ្វីប្រៀបផ្ទឹមមិនបាន សីលជាអាវុធដ៏ឧត្តម សីលជាគ្រឿងអាភរណៈដ៏ប្រសើរ សីលជាគ្រឿងក្រោះយ៉ាងអស្ចារ្យ ។

**សីលំ សេតុ មហេសក្ខោ    សីលំ គន្ធោ អនុត្តរោ**
**សីលំ វិលេបនំ សេដ្ឋំ    យេន វាតិ ទិសោ ទិសំ ។**

សីលជាស្ពានមានសក្តិធំ សីលជាគ្រឿងក្រអូបដ៏ប្រសើរ សីលជាគ្រឿងលាបដ៏ប្រសើរ តែងបក់ទៅសព្វៗទិស ។

**សីលំ សម្ពលមេវគ្គំ    សីលំ បាថេយ្យមុត្តមំ**
**សីលំ សេដ្ឋោ អតិវាហោ    យេន វាតិ ទិសោ ទិសំ ។**

សីលជាកញ្ចប់បាយដ៏ប្រសើរ សីលជាស្បៀងដ៏ឧត្តម សីលជាវាហនៈដ៏ប្រសើរសម្រាប់ទៅកាន់ទិសទាំងពួង ។



**ឥធេវ និន្ទំ លភតិ    បេច្ចាបាយេ ច ទុម្មនោ**
**សព្វត្ថ ទុម្មនោ ពាលោ    សីលេសុ អសមាហិតោ ។**

បុគ្គលពាលមានចិត្តអាក្រក់ក្នុងទីទាំងពួង មិនតាំងមាំក្នុងសីលទាំងឡាយ រមែងបាននូវសេចក្តីនិន្ទាក្នុងលោកនេះផង លុះលះលោកនេះទៅហើយ រមែងមានចិត្តជាទុក្ខក្នុងអបាយផង ។

**ឥធេវ កិត្តឹ លភតិ    បេច្ច សគ្គេ ច សុមនោ**
**សព្វត្ថ សុមនោ ធីរោ    សីលេសុ សុសមាហិតោ ។**

អ្នកប្រាជ្ញមានចិត្តល្អក្នុងទីទាំងពួង តាំងមាំក្នុងសីលទាំង-ឡាយ រមែងបាននូវកិត្តិសព្ទ ក្នុងលោកនេះផង លុះលះលោកនេះទៅ រមែងមានចិត្តរីករាយក្នុងឋានសួគ៌ផង ។

**សីលមេវ ឥធ អគ្គំ    បញ្ញវា បន ឧត្តមោ**
**មនុស្សេសុ ច ទេវេសុ    សីលបញ្ញាណតោ ជយន្តិ ។**

សីលជាកំពូលក្នុងលោកនេះ ចំណែកបុគ្គលមានប្រាជ្ញាក៏ឧត្តមដែរ ជ័យជម្នះក្នុងមនុស្សលោកនិងទេវលោក ព្រោះសីលនិងបញ្ញា ។

## ២_គាថារបស់ព្រះអធិមុត្តត្ថេរ

### បិដកលេខ ៥៧ ទំព័រ ៤៥

(ចោរពោលថា) ក្នុងកាលមុន យើងខ្ញុំទាំងឡាយ សម្លាប់ពួកសត្វណា ដើម្បីយញ្ញ ឬដើម្បីទ្រព្យ ភ័យក៏កើតមាន (ដល់សត្វពួកនោះ) ឥតមានសេសសល់ សត្វទាំងនោះ រមែងញាប់ញ័រផង សោកសៅផង ។ សេចក្តីភិតភ័យនៃលោកមិនមាន ទាំងសម្បុរ (មុខលោក) ក៏ស្រស់បស់ក្រៃពេក ហេតុអ្វីក៏លោកមិនខ្សឹកខ្សួល ព្រោះភ័យធំ មានសភាពយ៉ាងនេះ ។

ព្រះអធិមុត្តត្ថេរពោលតបថា :

**នត្ថិ ចេតសិកំ ទុក្ខំ អនបេក្ខស្ស គាមណិ**
**អតិក្កន្តា ភយា សព្វេ ខីណសំយោជនស្ស វេ ។**

ម្នាលចោរជាធំ សេចក្តីទុក្ខ ប្រព្រឹត្តទៅក្នុងចិត្តនៃបុគ្គលអ្នកមិនមានសេចក្តីអាឡោះអាល័យ មិនមានទេ បុគ្គលអ្នកមានសំយោជនៈអស់ហើយ បានកន្លងផុតនូវភ័យទាំងពួង ។



**ខីណាយ ភវនេត្តិយា ទិដ្ឋេ ធម្មេ យថាតថា**
**ន ភយំ មរណេ ហោតិ ភារនិក្ខេបនេ យថា ។**

កាលបើតណ្ហា ជាគ្រឿងនាំសត្វទៅកាន់ភពក្នុងបច្ចុប្បន្នអស់ហើយ (ព្រោះឃើញធម៌តាមពិត) ភ័យចំពោះសេចក្តីស្លាប់ក៏មិនមានដោយហេតុណាមួយឡើយ ដូចការមិនមានភ័យក្នុងកិរិយាដាក់ចុះនូវភារៈចេញ (អំពីក្បាល) ។

**សុចិណ្ណំ ព្រហ្មចរិយំ មេ មគ្គោ ចាបិ សុភាវិតោ**
**មរណេ មេ ភយំ នត្ថិ រោគានមិវ សង្ខយេ ។**

ព្រហ្មចរិយធម៌ អាត្មាបានសន្សំល្អហើយ ទាំងមគ្គ អាត្មាក៏បានចម្រើនល្អហើយ ភ័យចំពោះសេចក្តីស្លាប់នៃអាត្មា មិនមានទេ ដូចការមិនមានភ័យ ក្នុងកិរិយាអស់ទៅនៃរោគទាំងឡាយ ។

**សុចិណ្ណំ ព្រហ្មចរិយំ មេ មគ្គោ ចាបិ សុភាវិតោ**
**និរស្សាទា ភវា ទិដ្ឋា វិសំ បិត្វាវ ឆឌ្ឌិតំ ។**

ព្រហ្មចរិយធម៌ អាត្មាបានសន្សំល្អហើយ ទាំងមគ្គ អាត្មាក៏បានចម្រើនល្អហើយ ភពទាំងឡាយដែលមិនមានសេចក្តីត្រេកអរ អាត្មាក៏បានឃើញហើយ ដូចបុគ្គលផឹកនូវថ្នាំពិស ហើយខ្ជាក់ចោលវិញ ។

បារគូ អនុបាទានោ  កតកិច្ចោ អនាសវោ
តុដ្ឋោ អាយុក្ខយា ហោតិ  មុត្តោ អាឃាតនា យថា ៗ

បុគ្គលអ្នកដល់នូវត្រើយ គឺព្រះនិព្វាន មិនមានសេចក្តីប្រកាន់ មានសោឡសកិច្ចធ្វើហើយ មិនមានអាសវៈ រមែងជាអ្នកត្រេកអរ ក្នុងកិរិយាអស់ទៅនៃអាយុ ដូចបុគ្គលរួចហើយចាកការសម្លាប់ ។

ឧត្តមំ ធម្មតំ បត្តោ  សព្វលោកេ អនត្ថិកោ
អាទិត្តាវ ឃរា មុត្តោ  មរណស្មឹ ន សោចតិ ៗ

បុគ្គលបានដល់នូវធម៌ដ៏ឧត្តម ជាអ្នកមិនត្រូវការអ្វីក្នុងលោកទាំងអស់ រមែងមិនសោកសៅ ព្រោះសេចក្តីស្លាប់ ដូចបុគ្គលស្ទុះផុតចាកផ្ទះដែលភ្លើងឆេះ ។

យទត្ថិ សង្គតំ កិញ្ចិ  ភវោ ច យត្ថ លព្ភតិ
សព្វំ អនិស្សរំ ឯតំ  ឥទំ វុត្តំ មហេសិនា ៗ

ការជួបជុំដោយសត្វនិងសង្ខារឯណានីមួយក្តី ការកើតមានក្នុងពួកសត្វឯណាក្តី ទាំងអស់នោះមិនមែនជាធំ(ក្នុងខ្លួនឯង)ឡើយ ពាក្យនេះព្រះសម្មាសម្ពុទ្ធអ្នកស្វែងរកនូវគុណធំបានសម្តែងហើយ។



យោ តំ តថា បជានាតិ  យថា ពុទ្ធេន ទេសិតំ
ន គណ្ហាតិ ភវំ កិញ្ចិ  សុតត្តំ វ អយោគុឡំ ៗ

បុគ្គលណា បានដឹងច្បាស់នូវព្រះពុទ្ធដីកាតាមដែលព្រះពុទ្ធទ្រង់សម្តែងហើយនោះ បុគ្គលនោះ រមែងមិនប្រកាន់នូវភពណានីមួយឡើយ ដូចបុរសមិនកាន់ដុំដែកដែលក្តៅសព្វ ។

ន មេ ហោតិ អហោសិន្តិ  ភវិស្សន្តិ ន ហោតិ មេ
សង្ខារា វិភវិស្សន្តិ  តត្ថ កា បរិទេវនា ៗ

អាត្មាមិនមានសេចក្តីត្រិះរិះថា ខ្លួនអញបានមានហើយទេ អាត្មាមិនមានគិតថា ខ្លួនអញនឹងមានតទៅទេ (ព្រោះថា) សង្ខារទាំងឡាយ ទៀងតែវិនាសទៅវិញ ហេតុនោះសេចក្តីខ្សឹកខ្សួលក្នុងសង្ខារទាំងនោះដូចម្តេចកើត ។

សុទ្ធំ ធម្មសមុប្បាទំ  សុទ្ធំ សង្ខារសន្តតឹ
បស្សន្តស្ស យថាភូតំ  ន ភយំ ហោតិ គាមណិ ៗ

ម្នាលចោរជាធំ បុគ្គលដែលឃើញច្បាស់តាមសេចក្តីពិតនូវការប្រជុំកើតនៃធម៌ដ៏បរិសុទ្ធ និងតំណនៃសង្ខារដ៏បរិសុទ្ធ ភ័យរមែងមិនមានឡើយ ។

**តិណកដ្ឋសមំ លោកំ យទា បញ្ញាយ បស្សតិ**
**មមត្តំ សោ អសំវិន្ទំ នត្ថិ មេតិ ន សោចតិ ។**

បុគ្គលដែលឃើញច្បាស់ ដោយបញ្ញានូវលោក ប្រាកដស្មើដោយស្មៅ និងកំណាត់ឈើ ក្នុងកាលណា ក្នុងកាលនោះ បុគ្គលនោះ ក៏មិនបាននូវសេចក្ដីប្រកាន់ ថាជារបស់អញ រមែងមិនសោកសៅថា របស់នោះមិនមានដល់អាត្មាអញឡើយ ។

**ឧក្កណ្ឋាមិ សរីរេន ភវេនម្ហិ អនត្ថិកោ**
**សោយំ ភិជ្ជិស្សតិ កាយោ អញ្ញោ ច ន ភវិស្សតិ ។**

អាត្មាធុញទ្រាន់នឹងសរីរៈ ជាអ្នកមិនត្រូវការដោយភពព្រោះថាកាយនេះនឹងបែកធ្លាយទៅ ទាំងកាយដទៃទៀត ក៏នឹងមិនមានដែរ ។

**យំ វោ កិច្ចំ សរីរេន តំ ករោថ យទិច្ឆថ**
**ន មេ តប្បច្ចយា តត្ថ ទោសោ បេមំ ច ហេហីតិ ។**

កិច្ចណាដោយសរីរៈមានដល់ពួកអ្នក ពួកអ្នកប្រាថ្នានូវកិច្ចណា ចូរធ្វើនូវកិច្ចនោះចុះ សេចក្ដីទោមនស្សក្ដី សេចក្ដីស្រឡាញ់ក្ដីនៃអាត្មានឹងមិនមានក្នុងអំពើទាំងនោះ ព្រោះបច្ច័យនៃកិច្ចនោះ ។





ពួកចោរ បានស្ដាប់ពាក្យនៃព្រះអធិមុត្តត្ថេរនោះ ជាពាក្យចម្លែកអស្ចារ្យ គួរឱ្យព្រឺរោម ហើយក៏ទម្លាក់ចោលនូវគ្រឿងសស្ត្រាទាំងឡាយ បានពោលពាក្យនេះថា បពិត្រលោកដ៏ចម្រើនលោកបានធ្វើតបោកម្មដូចម្ដេច ឬអ្នកណាជាអាចារ្យរបស់លោកសេចក្ដីមិនសោកសៅ លោកបានព្រោះអាស្រ័យពាក្យប្រដៅរបស់អ្នកណា ។

**សព្វញ្ញូ សព្វទស្សាវី ជិនោ អាចរិយោ មម**
**មហាការុណិកោ សត្ថា សព្វលោកតិកិច្ឆកោ ។**

ព្រះថេរៈឆ្លើយថា ព្រះជិនស្រីព្រះអង្គជាសព្វញ្ញូ ទ្រង់ឃើញនូវធម៌ទាំងពួង ជាសាស្ដាប្រកបដោយករុណាដ៏ធំ ទ្រង់រក្សានូវសត្វលោកទាំងអស់ ជាអាចារ្យរបស់អាត្មា ។

**តេនាយំ ទេសិតោ ធម្មោ ខយគាមី អនុត្តរោ**
**តស្ស សាសនមាគម្ម លព្ភតេ តំ អសោកតា ។**

ព្រះធម៌នេះ ជាធម៌ដល់នូវកិរិយាអស់ទៅនៃកិលេស ជាធម៌ដ៏ប្រសើរ ព្រះជិនស្រីនោះ បានសម្ដែងហើយ សេចក្ដីមិនសោកសៅ ដែលអាត្មាបាន ព្រោះអាស្រ័យនូវធម៌ជាពាក្យប្រៀនប្រដៅរបស់ព្រះជិនស្រីនោះ ។

ព្រះធម្មសង្គាហកាចារ្យ បានសម្តែងគាថាចុងក្រោយដូច្នេះថា :

សុត្វាន ចោរា ឥសិនោ សុភាសិតំ
និក្ខិប្ប សត្ថានិ ច អាវុធានិ ច
តម្ហា ច កម្មា វិរមឹសុ ឯកេ
ឯកេ ច បព្វជ្ជមរោចយឹសុ ។
តេ បព្វជិត្វា សុគតស្ស សាសនេ
ភាវេត្វា ពោជ្ឈង្គពលានិ បណ្ឌិតា
ឧទគ្គចិត្តា សុមនា កតិន្ទ្រិយា
ផុសឹសុ និព្វានបទំ អសង្ខតន្តិ ។

ចោរទាំងឡាយបានស្តាប់នូវសុភាសិតនៃឥសី(អធិមុត្តត្ថេរ) ក៏ទម្លាក់ចោលនូវគ្រឿងសស្ត្រាទាំងឡាយផង នូវអាវុធទាំងឡាយផង ពួកខ្លះក៏វៀរចាកចោរកម្មនោះ ពួកខ្លះក៏ពេញចិត្តនឹងបព្វជ្ជា ។ ចោរទាំងនោះក៏ចូលទៅបួសក្នុងសាសនានៃព្រះសុគត ចម្រើននូវពោជ្ឈង្គ និងពលៈទាំងឡាយ ជាបណ្ឌិតមានចិត្តខ្ពស់ឡើង មានចិត្តល្អ មានឥន្ទ្រិយចម្រើនហើយ ក៏បានពាល់ត្រូវនូវនិព្វានបទ ជាអសង្ខតធម៌ ។





## ៣.គាថារបស់ព្រះរដ្ឋបាលត្ថេរ

### បិដកលេខ ៥៧ ទំព័រ ៥៦

បស្សាមិ លោកេ សធនេ មនុស្សេ
លទ្ធាន វិត្តំ ន ទទន្តិ មោហា ។

អាត្មាបានឃើញនូវមនុស្សទាំងឡាយ បរិបូណ៌ដោយទ្រព្យសម្បត្តិក្នុងលោក (ពួកមនុស្សទាំងនោះ) លុះបានទ្រព្យគាប់ចិត្តហើយ មិនឱ្យ ( ដល់បុគ្គលណាមួយឡើយ ) ព្រោះតែសេចក្តីវង្វេង ។

លទ្ធា ធនំ សន្និចយំ ករោន្តិ
ភិយ្យោ ច កាមេ អភិបត្ថយន្តិ ។

ពួកមនុស្សបានទ្រព្យហើយ ក៏ធ្វើនូវការសន្សំទុក ទាំងប្រាថ្នាក្នុងកាមដ៏លើសលប់ ។

រាជា បសយ្ហប្បថវឹ វិជេត្វា
សសាគរន្តំ មហិមាវសន្តោ
ឱរំ សមុទ្ទស្ស អតិត្តរូបោ

ចារំ សមុទ្ទស្សបិ បត្ថយេថ ៕

ព្រះរាជាឈ្នះនូវផែនដី ដែលព្រះអង្គរឹបជាន់បានហើយ នៅគ្រប់គ្រងផែនដី មានសាគរជាទីបំផុត មានសភាពមិនឆ្អែតនឹងត្រើយសមុទ្រខាងអាយ ក៏ប្រាថ្នានូវត្រើយសមុទ្រខាងនាយ ។

រាជា ច អញ្ញេ ច ពហូ មនុស្សា
អវីតតណ្ហា មរណំ ឧបេន្តិ
ឩនាវ ហុត្វាន ជហន្តិ ទេហំ
កាមេហិ លោកម្ហិ ន ហត្ថិ តិត្តិ ៕

ព្រះរាជាក្តី ពួកមនុស្សដទៃច្រើននាក់ក្តី មិនទាន់ប្រាសចាកតណ្ហា រមែងដល់នូវសេចក្តីស្លាប់ គឺថាជាអ្នកមានសេចក្តីខ្វះខាតលះបង់រាងកាយ ព្រោះថាសេចក្តីឆ្អែតដោយកាមទាំងឡាយក្នុងលោកមិនមាន ។

កន្ទន្តិ នំ ញាតិ បកិរិយ កេសេ
អហោ វតា នោ អមរាតិ ចាហុ
វត្ថេន នំ បារុតំ នីហរិត្វា
ចិត្តំ សមោធាយ តតោ ឌហន្តិ ៕



ពួកញាតិ រំសាយសក់កន្ទក់កន្ទេញ ចំពោះបុគ្គលដែលស្លាប់ហើយនោះ ទាំងបាននិយាយថា ធ្វើម្តេចហ្ន៎ ញាតិរបស់យើងទាំងឡាយកុំស្លាប់វិញ ក៏នាំខ្មោចនោះដែលរុំដោយសំពត់ទៅកាន់ជើងថ្ករ ប្រជុំគ្នាដុតក្នុងទីនោះ ។

សោ ឌយ្ហតិ សូលេហិ តុជ្ជមានោ
ឯកេន វត្ថេន បហាយ ភោគេ
ន មិយ្យមានស្ស ភវន្តិ តាណា
ញាតី ច មិត្តា អថ វា សហាយា ៕

បុគ្គលដែលស្លាប់នោះ ត្រូវពួកអ្នកដុតចាក់ដោយឈើស្នូលដុត បុគ្គលនោះលះបង់នូវភោគៈទាំងឡាយ មានតែសំពត់មួយស្លាប់ទៅ ញាតិទាំងឡាយក្តី មិត្តទាំងឡាយក្តី ឬសម្លាញ់ទាំងឡាយក្តី ជាទីពឹងមិនមានទេ ។

ទាយាទកា តស្ស ធនំ ហរន្តិ
សត្តោ បន គច្ឆតិ យេន កម្មំ
ន មិយ្យមានំ ធនមន្វេតិ កិញ្ចិ
បុត្តា ច ទារា ច ធនញ្ច រដ្ឋំ ៕

ពួកទាយាទ (អ្នកត្រូវទទួលមត៌ក) រមែងនាំទៅនូវទ្រព្យរបស់សត្វដែលស្លាប់នោះ ចំណែកសត្វដែលស្លាប់នោះ ក៏ទៅតាមយថាកម្ម ទ្រព្យតិចតួច កូនប្រពន្ធមាសប្រាក់ និងដែន ក៏មិនមែនជាប់តាមសត្វដែលស្លាប់នោះទេ ។

**ន ទីឃមាយុំ លភតេ ធនេន**
**ន ចាបិ វិត្តេន ជរំ វិហន្តិ**
**អប្បញ្ហិ នំ ជីវិតមាហុ ធីរា**
**អសស្សតំ វិបរិណាមធម្មំ ៕**

បុគ្គលមិនមែនបាននូវអាយុវែង ដោយសារទ្រព្យទេ ទាំងមិនមែនកម្ចាត់បង់នូវជរាដោយសារទ្រព្យបានទេ ព្រោះថា អ្នកប្រាជ្ញទាំងឡាយបានពោលនូវជីវិតនេះថា តិច មិនទៀង មានការប្រែប្រួលទៅ ជាធម្មតា ។

**អន្ធា ទលិទ្ទា ច ផុសន្តិ ផស្សំ**
**ពាលោ ច ធីរោ ច តថេវ ផុដ្ឋោ**
**ពាលោ ហិ ពាល្យា វធិតោវ សេតិ**
**ធីរោ ច ន វេធតិ ផស្សផុដ្ឋោ ៕**





ជនទាំងឡាយ អ្នកស្តុកស្តម្ភ និងអ្នកទ័លក្រ រមែងប៉ះពាល់នូវផស្សៈ (មិនជាទីប្រាថ្នា) បុគ្គលពាលនិងអ្នកប្រាជ្ញ រមែងប៉ះពាល់ដូចគ្នា ប៉ុន្តែបុគ្គលពាល បើមានសេចក្តីទុក្ខបៀតបៀនហើយ រមែងដេក (សោកស្តាយ) ព្រោះភាវៈនៃខ្លួនពាល ឯអ្នកប្រាជ្ញ បើទុកជាប៉ះពាល់នូវផស្សៈ ក៏មិនបានញាប់ញ័រ ។

**តស្មា ហិ បញ្ញាវ ធនេន សេយ្យោ**
**យាយ វោសានមិធាធិគច្ឆតិ**
**អព្យោសិតត្តា ហិ ភវាភវេសុ**
**បាបានិ កម្មានិ ករោន្តិ មោហា ៕**

ព្រោះហេតុនោះ បុគ្គលបាននូវព្រះនិព្វាន ជាទីបំផុតនៃភពក្នុងលោកនេះ ដោយបញ្ញាណា បញ្ញានោះជាធម្មជាតិប្រសើរជាងទ្រព្យ ដ្បិតបុគ្គលទាំងឡាយមិនទាន់បានសម្រេចប្រយោជន៍ រមែងធ្វើនូវបាបកម្មទាំងឡាយ ក្នុងភពតូច និងភពធំ ព្រោះតែមោហៈ ។

**ឧបេតិ គព្ភញ្ច បរញ្ច លោកំ**
**សំសារមាបជ្ជ បរម្បរាយ**
**តស្សប្បបញ្ញោ អភិសទ្ទហន្តោ**
**ឧបេតិ គព្ភញ្ច បរញ្ច លោកំ ៕**

បុគ្គលណា (បានធ្វើបាបកម្ម) ក៏ដល់នូវការអន្ទោលទៅមក រមែងចូលទៅកាន់គភ៌ និងបរលោក បុគ្គលអ្នកអប្បប្រាជ្ញា (ឯទៀត) កាលបើជឿបុគ្គលអ្នកធ្វើបាបកម្មនោះ ក៏ទៅកាន់គភ៌ និងបរលោក ។

**ចោរោ យថា សន្ធិមុខេ គហីតោ**
**សកម្មុនា ហញ្ញតិ បាបធម្មោ**
**ឯវំ បជា បេច្ច បរម្ហិ លោកេ**
**សកម្មុនា ហញ្ញតិ បាបធម្មោ ។**

ចោរអ្នកមានធម៌ដ៏លាមកដែលគេចាប់បានត្រង់មុខតំណ[១] (នៃផ្ទះ) រមែងក្តៅក្រហាយដោយកម្មរបស់ខ្លួន យ៉ាងណាមិញ សត្វអ្នកមានធម៌ដ៏លាមក លុះស្លាប់ទៅ រមែងក្តៅក្រហាយ ក្នុងលោកខាងមុខ ដោយកម្មរបស់ខ្លួន ក៏យ៉ាងនោះដែរ ។

**កាមា ហិ ចិត្រា មធុរា មនោរមា**
**វិរូបរូបេន មថេន្តិ ចិត្តំ**
**អាទីនវំ កាមគុណេសុ ទិស្វា**
**តស្មា អហំ បព្វជិតោម្ហិ រាជ ។**

១-គេចាប់បានត្រង់កន្លែងជញ្ជាំងដែលខ្លួនចោះ ឬកាត់នោះ ។





កាមទាំងឡាយដ៏វិចិត្រ មានរសឆ្ងាញ់ ជាទីរីករាយនៃចិត្ត តែងញាំញីចិត្តដោយសភាពផ្សេងៗ បពិត្រមហារាជ ហេតុនោះ អាត្មាភាពឃើញទោសក្នុងកាមគុណទាំងឡាយ ទើបចេញទៅបួស ។

**ទុមប្ផលានីវ បតន្តិ មាណវា**
**ទហរា ច វុឌ្ឍា ច សរីរភេទា**
**ឯតម្បិ ទិស្វា បព្វជិតោម្ហិ រាជ**
**អបណ្ណកំ សាមញ្ញមេវ សេយ្យោ ។**

សត្វទាំងឡាយទោះក្មេងក្តី ចាស់ក្តី តែងបែកធ្លាយនូវសរីរៈ ដូចជាផ្លែឈើជ្រុះ (ចាកដើម) បពិត្រមហារាជ អាត្មាភាពបានឃើញនូវរបស់មិនទៀងនេះឯងបានជាចេញបួស ភាពជាសមណៈមិនសូវខុសភ្លាត់ ជារបស់ប្រសើរលើសលប់ ។

**សទ្ធាយាហំ បព្វជិតោ ឧបេតោ ជិនសាសនេ**
**អវជ្ជា មយ្ហំ បព្វជ្ជា អនណោ ភុញ្ជាមិ ភោជនំ ។**

អាត្មាភាពបួសដោយសទ្ធា បានប្រកបសេចក្តីប្រតិបត្តិ ក្នុងសាសនានៃព្រះជិនស្រី បព្វជ្ជារបស់អាត្មាភាព មិនមានទោស

អាត្មាភាពបរិភោគភោជន មិនមានបំណុលទេ ។

**កាមេ អាទិត្តតោ ទិស្វា ជាតរូបានិ សត្ថតោ**
**គព្ភេ វោក្កន្តិតោ ទុក្ខំ និរយេសុ មហព្ភយំ ។**

អាត្មាភាពឃើញនូវកាមទាំងឡាយ ហាក់ដូចជាភ្លើងឆេះសព្វហើយ ឃើញនូវជាតរូប ហាក់ដូចជាគ្រឿងសស្ត្រាវុធ ឃើញហេតុនាំមកនូវទុក្ខ តាំងតែអំពីការចុះចាប់បដិសន្ធិក្នុងគភ៌ ឃើញនូវភ័យធំ ក្នុងនរកទាំងឡាយ ។

**ឯតមាទីនវំ ទិស្វា សំវេគំ អលភឹ តទា**
**សោហំ វិទ្ធោ តទា សន្តោ សម្បត្តោ អាសវក្ខយំ ។**

អាត្មាភាពឃើញនូវទោសនេះឯង ក៏បាននូវសេចក្តីសង្វេគក្នុងកាលនោះ អាត្មាភាពហ្នឹងឯង ជាអ្នកត្រូវសរមុតហើយ ក្នុងកាលនោះ (ឥឡូវនេះ) បានដល់ហើយ នូវការអស់ទៅនៃអាសវៈ។

**បរិចិណ្ណោ មយា សត្ថា កតំ ពុទ្ធស្ស សាសនំ**
**ឱហិតោ គរុកោ ភារោ ភវនេត្តិ សមូហតា ។**

ព្រះសាស្តា អាត្មាភាពបានបម្រើហើយ ព្រះពុទ្ធសាសនា





អាត្មាភាពក៏បានធ្វើហើយ ភារៈដ៏ធ្ងន់ អាត្មាភាពបានដាក់ចុះហើយ តណ្ហាជាគ្រឿងនាំសត្វទៅកាន់ភព អាត្មាភាព បានដកចោលហើយ ។

**យស្ស ចត្ថាយ បព្វជិតោ អគារស្មា អនគារិយំ**
**សោ មេ អត្ថោ អនុប្បត្តោ សព្វសំយោជនក្ខយោតិ ។**

កុលបុត្របានចេញចាកផ្ទះ ចូលមកកាន់ផ្នួស ដើម្បីប្រយោជន៍ណា ប្រយោជន៍នោះ គឺការអស់ទៅនៃសំយោជនៈទាំងពួង អាត្មាភាពបានដល់ហើយ ។

## ជ័យជំនះដែលមិនមានពៀរ

**អក្កោធេន ជិនេ កោធំ អសាធុំ សាធុនា ជិនេ**
**ជិនេ កទរិយំ ទានេន សច្ចេនាលិកវាទិនំ ។**

បុគ្គលគប្បីឈ្នះមនុស្សក្រោធខឹង ដោយការមិនក្រោធខឹងតប គប្បីឈ្នះមនុស្សមិនល្អ ដោយសេចក្តីល្អ គប្បីឈ្នះមនុស្សកំណាញ់ ដោយការឱ្យទាន គប្បីឈ្នះមនុស្សនិយាយឡេះឡោះឥតបានការ ដោយការនិយាយពាក្យពិតមានប្រយោជន៍ ។

ព្រះអង្គទ្រង់គង់ប្រថាប់នៅវេឡុវនារាម ទ្រង់ប្រារព្ធ
ឧត្តរាឧបាសិកាដែលមិនក្រោធខឹងជាមួយនឹងនាងសិរិមា

## ៤.គាថារបស់ព្រះអង្គុលិមាលត្ថេរ
### បិដកលេខ ៥៧ ទំព័រ ៧២

**យោ ច បុព្វេ បមជ្ជិត្វា   បច្ឆា សោ នប្បមជ្ជតិ**
**សោមំ លោកំ បភាសេតិ   អព្ភា មុត្តោវ ចន្ទិមា ។**

(ព្រះអង្គុលិមាលត្ថេរពោលថា )បុគ្គលណាប្រមាទក្នុងកាលមុន ហើយមិនប្រមាទក្នុងកាលខាងក្រោយ បុគ្គលនោះរមែងញ៉ាំងលោកនេះឱ្យរុងរឿង ដូចព្រះចន្ទផុតស្រឡះចាកពពក ។

**យស្ស បាបំ កតំ កម្មំ   កុសលេន បិធីយតិ**
**សោមំ លោកំ បភាសេតិ   អព្ភា មុត្តោវ ចន្ទិមា ។**

បុគ្គលណាបានធ្វើអំពើបាប ហើយបិទ (អំពើបាបនោះ ) ដោយកុសល បុគ្គលនោះ រមែងញ៉ាំងលោកនេះឱ្យរុងរឿង ដូចព្រះចន្ទផុតស្រឡះចាកពពក ។





**យោ ហវេ ទហរោ ភិក្ខុ   យុញ្ជតី ពុទ្ធសាសនេ**
**សោមំ លោកំ បភាសេតិ   អព្ភា មុត្តោវ ចន្ទិមា ។**

ភិក្ខុណានៅក្មេង តែខ្មីឃ្មាតក្នុងពុទ្ធសាសនា ភិក្ខុនោះរមែងញ៉ាំងលោកនេះឱ្យរុងរឿង ដូចព្រះចន្ទផុតស្រឡះចាកពពក។

**ទិសា ហិ មេ ធម្មកថំ សុណន្តុ**
**ទិសា ហិ មេ យុញ្ជន្តុ ពុទ្ធសាសនេ ច**
**ទិសា ហិ មេ តេ មនុស្សេ ភជន្តុ**
**យេ ធម្មមេវាទបយន្តិ សន្តោ ។**

សូមពួកជនជាសត្រូវនឹងយើង ស្តាប់នូវធម្មកថា សូមពួកជនជាសត្រូវនឹងយើង ខ្មីឃ្មាតក្នុងព្រះពុទ្ធសាសនាចុះ ពួកមនុស្សណា ដែលជាសប្បុរស តែងដឹកនាំក្នុងធម៌តែម្យ៉ាង សូមពួកជនជាសត្រូវនឹងយើង គប់រកនូវមនុស្សទាំងនោះចុះ ។

**ទិសា ហិ មេ ខន្តិវាទានំ   អវិរោធប្បសំសិនំ**
**សុណន្តុ ធម្មំ កាលេន   តញ្ច អនុវិធីយន្តុ ។**

សូមពួកជនជាសត្រូវនឹងយើង ស្តាប់ធម៌របស់ពួកសប្បុរស ដែលជាអ្នកពោលនូវខន្តី ជាអ្នកសរសើរនូវសេចក្តីមិនក្រោធ តាមកាលគួរផង ចូរធ្វើតាមនូវធម៌នោះផង ។

ន ហិ ជាតុ សោ មមំ ហឹសេ អញ្ញំ វា បន កញ្ចិ នំ
បប្បុយ្យ បរមំ សន្តឹ រក្ខេយ្យ តសថាវរេ ។

បើជននោះ មិនបៀតបៀនយើង ឬសត្វដទៃណាមួយទេ ជននោះគប្បីដល់នូវសេចក្តីស្ងប់យ៉ាងឧត្តម គប្បីរក្សានូវជនដែលមានចិត្តតក់ស្លុត និងមានចិត្តមាំមួន ។

ឧទកំ ហិ នយន្តិ នេត្តិកា
ឧសុការា នមយន្តិ តេជនំ
ទារុំ នមយន្តិ តច្ឆកា
អត្តានំ ទមយន្តិ បណ្ឌិតា ។

ពួកអ្នកបង្ហូរទឹក តែងបង្ហូរទឹក ពួកជាងព្រួញ តែងពត់ព្រួញ ពួកជាងចាំង តែងចាំងពត់ឈើ ពួកអ្នកប្រាជ្ញ តែងទូន្មានខ្លួន ។

ទណ្ឌេនេកេ ទមយន្តិ អង្កុសេហិ កសាហិ ច
អទណ្ឌេន អសត្ថេន អហំ ទន្តោម្ហិ តាទិនា ។

ជនពួកខ្លះ តែងទូន្មាន (នូវសត្វពាហនៈមានដំរីជាដើម ) ដោយដំបង កង្វេរ និងរំពាត់ផ្តៅ ព្រះមានព្រះភាគ ជាតាទិបុគ្គល ទ្រង់ទូន្មានខ្ញុំ ដោយមិនបាច់ប្រើដំបង និងគ្រឿងសស្ត្រាទេ ។





អហឹសកោតិ មេ នាមំ ហឹសកស្ស បុរេ សតោ
អជ្ជាហំ សច្ចនាមោម្හិ ន នំ ហឹសាមិ កញ្ចិ នំ ។

ក្នុងកាលមុន ខ្ញុំជាអ្នកបៀតបៀនគេ តែមាននាមថា អហឹសកៈ[១] ក្នុងថ្ងៃនេះ ខ្ញុំមាននាមត្រូវតាមដំណើរពិតហើយ ព្រោះខ្ញុំមិនបៀតបៀនជនណាមួយឡើយ ។

ចោរោ អហំ បុរេ អាសឹ អង្គុលិមាលោតិ វិស្សុតោ
វុយ្ហមានោ មហោឃេន ពុទ្ធំ សរណមាគមំ ។

ក្នុងកាលមុន ខ្ញុំជាចោរល្បីឈ្មោះថា អង្គុលិមាល ដែលជំនន់ធំក្តួចនាំទៅហើយ (ឥឡូវ ) ខ្ញុំបានដល់នូវព្រះពុទ្ធជាទីពឹងហើយ ។

លោហិតបាណី បុរេ អាសឹ អង្គុលិមាលោតិ វិស្សុតោ
សរណាគមនំ បស្ស ភវនេត្តិ សមូហតា ។

ក្នុងកាលមុន ខ្ញុំជាអ្នកមានដៃប្រឡាក់ឈាម ល្បីឈ្មោះថា អង្គុលិមាល អ្នកចូរមើលនូវដំណើរមកកាន់សរណៈ (របស់ខ្ញុំ ) ចុះ ខ្ញុំបានដកនូវតណ្ហា ដែលនាំទៅកាន់ភពហើយ ។

---

១-អ្នកមិនបៀតបៀនគេ ។

**តានិសំ កម្មំ កត្វាន          ពហុំ ទុគ្គតិគាមិនំ**
**ផុដ្ឋោ កម្មវិបាកេន          អនណោ ភុញ្ជាមិ ភោជនំ ។**

ខ្ញុំបានធ្វើកម្ម ដែលជាដំណើរទៅកាន់ទុគ្គតិបែបនោះជាច្រើន ត្រូវផលនៃកម្មប៉ះពាល់ (ឥឡូវ ) ជាអ្នកមិនមានបំណុលបរិភោគនូវភោជន ។

**បមាទមនុយុញ្ជន្តិ          ពាលា ទុម្មេធិនោ ជនា**
**អប្បមាទញ្ច មេធាវី          ធនំ សេដ្ឋំវ រក្ខតិ ។**

ពួកជនពាលឥតប្រាជ្ញា តែងប្រកបរឿយៗ នូវសេចក្តីប្រមាទ ចំណែកអ្នកប្រាជ្ញ តែងរក្សាទុកនូវសេចក្តីមិនប្រមាទ ដូចគេរក្សាទ្រព្យយ៉ាងប្រសើរ ។

**មា បមាទមនុយុញ្ជេថ          មា កាមរតិសន្ថវំ**
**អប្បមត្តោ ហិ ឈាយន្តោ          បប្បោតិ បរមំ សុខំ ។**

អ្នកទាំងឡាយ កុំប្រកបរឿយៗ នូវសេចក្តីប្រមាទ កុំធ្វើនូវសេចក្តីស្និទ្ធស្នាលដោយតម្រេកក្នុងកាមទាំងឡាយ ដ្បិតថា បុគ្គលអ្នកមិនប្រមាទ ប្រឹងចម្រើនឈាន រមែងបាននូវសេចក្តីសុខយ៉ាងក្រៃលែង ។



**ស្វាគតំ នាបគតំ          នេតំ ទុម្មន្តិតំ មម**
**សំវិភត្តេសុ ធម្មេសុ          យំ សេដ្ឋំ តទុបាគមំ ។**

ដំណើរមករបស់ខ្ញុំ ជាដំណើរល្អ មិនមែនជាដំណើរប្រាសចាក (ប្រយោជន៍ ) គំនិតរបស់ខ្ញុំនុ៎ះ មិនមែនជាគំនិតខុសទេ ព្រោះខ្ញុំបានសម្រេចធម៌ដ៏ប្រសើរបំផុត ក្នុងពួកធម៌ដែលព្រះមានព្រះភាគចែកទុកដោយប្រពៃ ។

**ស្វាគតំ នាបគតំ          នេតំ ទុម្មន្តិតំ មម**
**តិស្សោ វិជ្ជា អនុប្បត្តា          កតំ ពុទ្ធស្ស សាសនំ ។**

ដំណើរមករបស់ខ្ញុំ ជាដំណើរល្អ មិនមែនជាដំណើរប្រាសចាក (ប្រយោជន៍ ) គំនិតរបស់ខ្ញុំនុ៎ះ មិនមែនជាគំនិតខុសទេ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ ពុទ្ធសាសនាខ្ញុំក៏បានធ្វើហើយ ។

**អរញ្ញេ រុក្ខមូលេ វា          បព្វតេសុ គុហាសុ វា**
**តត្ថ តត្ថេវ អដ្ឋាសី          ឧព្វិគ្គមនសោ តទា ។**

(ក្នុងកាលមុន ) ខ្ញុំឋិតក្នុងទីទាំងឡាយនោះៗ គឺព្រៃក្តី ម្លប់ឈើក្តី ភ្នំក្តី គុហាក្តី ខ្ញុំក៏មានចិត្តតក់ស្លុត ក្នុងកាលនោះ ។

**សុខំ សយាមិ ឋាយាមិ　　សុខំ កប្បេមិ ជីវិតំ**
**អហត្ថបាសោ មារស្ស　　អហោ សត្ថានុកម្បិតោ ៚**

ឥឡូវនេះ ខ្ញុំដេកជាសុខ ឈរជាសុខ ចិញ្ចឹមជីវិតជាសុខ ជាបុគ្គលមិននៅក្នុងអន្ទាក់ដៃរបស់មារ ឱ ! ព្រះសាស្ដា ទ្រង់អនុគ្រោះខ្ញុំ ។

**ព្រាហ្មណោ បុរេ អាសឹ　　ឧភតោ ឧទិច្ចោ អហុំ**
**សោជ្ជ បុត្តោ សុគតស្ស　　ធម្មរាជស្ស សត្ថុនោ ៚**

ក្នុងកាលមុន ខ្ញុំបានកើតជាព្រាហ្មណ៍ មានត្រកូលខ្ពស់ទាំងពីរខាង គឺខាងមាតានិងខាងបិតា ថ្ងៃនេះ ខ្ញុំបានជាបុត្តនៃព្រះ-សុគត ជាសាស្ដា ធម្មរាជ ។

**វីតតណ្ហោ អនាទានោ　　គុត្តទ្វារោ សុសំវុតោ**
**អឃមូលំ វធិត្វាន　　បត្តោ មេ អាសវក្ខយោ ៚**

ខ្ញុំជាបុគ្គលប្រាសចាកតណ្ហា មិនមានសេចក្ដីប្រកាន់ បានគ្រប់គ្រងទ្វារ សង្រួមដោយប្រពៃហើយ ការអស់ទៅនៃអាសវៈ ខ្ញុំបានដល់ហើយ ព្រោះបានសម្លាប់ឫសគល់នៃទុក្ខ ។

**បរិចិណ្ណោ មយា សត្ថា　　កតំ ពុទ្ធស្ស សាសនំ**
**ឱហិតោ គរុកោ ភារោ　　ភវនេត្តិ សមូហតាតិ ៚**

ព្រះសាស្ដា ខ្ញុំបានប្រណិប័តន៍ហើយ ពុទ្ធសាសនា ខ្ញុំបានធ្វើហើយ ភារៈដ៏ធ្ងន់ ខ្ញុំបានដាក់ចោលហើយ តណ្ហាជាគ្រឿងនាំទៅកាន់ភព ខ្ញុំក៏ដកចោលហើយ ។

## ខំប្រឹងរើខ្លួនចាកទីស្មោកគ្រោក

**អប្បមាទរតា ហោថ　　សចិត្តមនុរក្ខថ**
**ទុគ្គា ឧទ្ធរថត្តានំ　　បង្កេ សន្នោវ កុញ្ជរោ។**

អ្នកទាំងឡាយ ចូរត្រេកអរក្នុងសេចក្ដីមិនប្រមាទ ចូរតាមរក្សាចិត្តរបស់ខ្លួន ចូររើខ្លួនឡើងចាកភក់គឺកិលេស ដូចជាដំរីដែលជាប់ភក់ ហើយខំប្រឹងរើខ្លួនរួចបាន ដូច្នោះឯង ។

ព្រះអង្គទ្រង់គង់ប្រថាប់នៅជេតវនារាម
ទ្រង់ប្រារព្ធដំរីបាវេរកៈដែលជាប់ផុងក្នុងរណ្ដៅភក់

## ៥-គាថារបស់ព្រះនាងសុមេធាថេរី
### បិដកលេខ ៥៧ ទំព័រ ២២៦

នាងសុមេធា ជាធីតានៃអគ្គមហេសីរបស់ព្រះរាជា ទ្រង់ព្រះនាមកោញ្ចៈ ក្នុងនគរឈ្មោះមន្តាវតី ជាស្ត្រីដែលព្រះអរិយៈអ្នកធ្វើតាមសាសនា បានញ៉ាំងនាងឱ្យជ្រះថ្លាហើយ ។ នាងសុមេធា ជាស្រីមានសីល ជាធម្មកថិកាដ៏វិចិត្រ ជាពហុស្សូតជាស្រីបានបទក្នុងព្រះពុទ្ធសាសនា ចូលទៅជិតព្រះមាតាព្រះបិតា ហើយទូលថា សូមទ្រង់ទាំងពីរស្តាប់ (ពាក្យខ្ញុំម្ចាស់) ។

**និព្វានាភិរតា អហំ អសស្សតំ ភវគតំ យទិបិ ទិព្វំ**
**កិមង្គ បន តុច្ឆា កាមា អប្បស្សាទា ពហុវិឃាតា ។**

ខ្ញុំម្ចាស់ជាអ្នកត្រេកអរ ចំពោះព្រះនិព្វាន ភពសូម្បីជាទិព្វ ក៏ជារបស់មិនទៀងទាត់ នឹងចាំបាច់ពោលទៅថ្វីដល់កាមទាំងឡាយ ដែលជារបស់សោះសូន្យ មានការត្រេកអរតិច មានសេចក្តីចង្អៀតចង្អល់ច្រើន ។





**កាមា កដុកា អាសីវិសូបមា យេសុ មុច្ឆិតា ពាលា**
**តេ ទីឃរត្តំ និរយេ សមប្បិតា ហញ្ញន្តេ ទុក្ខិតា ។**

ពួកជនពាល ឈ្លក់ក្នុងកាមទាំងឡាយណា កាមទាំងឡាយនោះ ជាសភាវៈខ្លោចផ្សា ឧបមាដូចជាអាសិរពិស ពួកជនពាលទាំងនោះ សឹងពេញណែនត្រៀបត្រាក្នុងនរក រងទុក្ខលំបាកអស់កាលដ៏អង្វែង ។

**សោចន្តិ បាបកកម្មា វិនិបាតេ បាបវុឌ្ឍិនោ**
**សទា កាយេន វាចាយ ច មនសា ច អសំវុតា ពាលា ។**

ពួកជនពាល មានកម្មដ៏លាមក មានគំនិតអាក្រក់មិនសង្រួម កាយ វាចា ចិត្ត រមែងសង្រេងសង្រៃ ក្នុងវិនិបាត (អបាយ) សព្វ ៗ កាល ។

**ពាលា តេ ទុប្បញ្ញា អចេតនា ទុក្ខសមុទយោ រុទ្ធា**
**ទេសេន្តេ អជានន្តា ន ពុជ្ឈរេ អរិយសច្ចានិ ។**

ជនពាលទាំងនោះ ឥតប្រាជ្ញា ឥតចេតនា (គឺស្លាប់គំនិត) ត្រូវតណ្ហា ជាហេតុនៃទុក្ខរួបរឹត កាលមិនដឹងនូវធម៌ ដែលព្រះសម្ពុទ្ធ ទ្រង់សម្តែង រមែងមិនត្រាស់ដឹង នូវអរិយសច្ចទាំងឡាយ ។

សច្ចានិ អម្ម ពុទ្ធវរទេសិតានិ តេ ពហុតរា អជានន្តា
យេ អភិនន្ទន្តិ ភវគតំ បិហន្តិ ទេវេសុ ឧបបត្តឹ ៕

បពិត្រព្រះមាតា ជនទាំងឡាយ ជាច្រើននាក់ណាស់ ដែលមិនដឹងនូវសច្ចធម៌ ដ៏ជាធម៌គឺព្រះពុទ្ធដ៏ប្រសើរទ្រង់សម្តែង ហើយត្រេកអរតែនឹងភព ពេញចិត្តតែនឹងការកើតក្នុងពួកទេវតា ។

ទេវេសុបិ ឧបបត្តិ អសស្សតា ភវគតេ អនិច្ចម្ហិ
ន ច ឧត្តសន្តិ ពាលា បុនប្បុនំ ជាយិតព្វស្ស ៕

សូម្បីការកើតក្នុងពួកទេវតាក៏មិនទៀង កាលបើភពមិនទៀង ពួកជនពាល ក៏នៅតែមិនតក់ស្លុតនឹងភព ដែលសត្វត្រូវកើតញយៗ ។

ចត្តារោ វិនិបាតា ទ្វេ ច គតិយោ កថញ្ចិ លព្ភន្តិ
ន ច វិនិបាតគតានំ បព្វជ្ជា អត្ថិ និរយេសុ ៕

វិនិបាត[១] ៤ (សត្វទាំងឡាយបានដោយងាយ) ឯគតិ ២ (គឺមនុស្ស និងទេវតា) បុគ្គលគប្បីបានដោយងាយដូចម្តេចកើតបព្វជ្ជារបស់ពួកសត្វវិនិបាតក្នុងនរកមិនមានឡើយ ។

---

១_វិនិបាត ៤ គឺ នរក តិរច្ឆាន ប្រេត អសុរកាយ ។ អដ្ឋកថា ។





អនុជានាថ មំ ឧភយោ បព្វជិតុំ ទសពលស្ស បាវចនេ
អប្បោស្សុក្កា យតិស្សំ ជាតិមរណប្បហានាយ ៕

សូមទ្រង់ទាំងពីរអនុញ្ញាតឱ្យខ្ញុំម្ចាស់ ទៅបួសក្នុងសាសនានៃព្រះទសពល ខ្ញុំម្ចាស់នឹងជាស្ត្រីមានសេចក្តីខ្វល់ខ្វាយតិច ប្រឹង-ប្រែងដើម្បីលះបង់នូវជាតិនិងមរណៈ ។

កឹ ភវគតេន អភិនន្ទិតេន កាយកលិនា អសារេន
ភវតណ្ហានិរោធាយ អនុជានាថ បព្វជិស្សាមិ ៕

ប្រយោជន៍អ្វី ដោយភព ដែលអ្នកផងតែងត្រេកត្រអាល ប្រយោជន៍អ្វីដោយកាយជាទោសដ៏ឥតខ្លឹមសារ សូមទ្រង់អនុញ្ញាតខ្ញុំម្ចាស់នឹងបួស ដើម្បីរំលត់នូវភវតណ្ហា ។

ពុទ្ធានំ ឧប្បាទោ វិវជ្ជិតោ អក្ខណោ ខណោ លទ្ធោ
សីលានិ ព្រហ្មចរិយំ យាវជីវំ ន ទូសេយ្យំ ៕

ការកើតឡើងនៃព្រះពុទ្ធទាំងឡាយ (ខ្ញុំម្ចាស់បានជួបប្រទះហើយ) កាលមិនមែនជាខណៈ ខ្ញុំម្ចាស់វៀរស្រឡះហើយ ខណៈខ្ញុំម្ចាស់បានហើយ ខ្ញុំម្ចាស់មិនប្រទូស្តនូវសីល និងព្រហ្មចរិយៈរហូត អស់ជីវិត ។

នាងសុមេធា ក្រាបទូលព្រះមាតាបិតាយ៉ាងនេះថា ខ្ញុំម្ចាស់នៅជាគ្រហស្ថនឹងមិនសោយអាហារ ខ្ញុំម្ចាស់សុខចិត្តស្លាប់[(១)] ។

មាតាជាទុក្ខស្រែកយំ បិតាក៏ជាទុក្ខ ត្រូវសេចក្តីសោក-ស្តាយគ្របសង្កត់ដូចគ្នា ប្រឹងប្រែងសង្រួបសង្រួមធីតានោះ ដែលដួលចុះលើផែនដី នាផ្ទៃប្រាសាទថា :

ម្នាលកូនស្រី ចូរនាងក្រោកឡើង ប្រយោជន៍អ្វីដោយការសោក ( ដើម្បីចង់បួស ) យើងបានថ្វាយនាងដល់ស្តេច ទ្រង់ព្រះនាមអនិករត្តៈ ជាស្តេចមានរូបល្អ ក្នុងនគរឈ្មោះវារណវតីហើយ ។ នាងនឹងបានជាអគ្គមហេសី នឹងបានជាភរិយារបស់ស្តេចអនិករត្តៈ នៃកូនស្រី សីល ព្រហ្មចរិយធម៌ និងបញ្ញា គេធ្វើបានដោយកម្រណាស់ ។ អាណាចក្រក្នុងរាជ្យ ( នៃស្តេចអនិករត្តៈ ) ទ្រព្យនិងឥស្សរិយយស ( ក៏មានច្រើន ) ភោគសម្បត្តិទាំងឡាយនាំមកនូវសេចក្តីសុខ ទាំងខ្លួននាងក៏នៅក្រមុំ ព្រោះហេតុនោះនាងចូរប្រើប្រាស់ភោគសម្បត្តិតាមប្រាថ្នាចុះ ម្នាលកូនស្រី កិច្ចដែលគេត្រូវដណ្តឹង ចូរមានដល់នាង ។

**អថ នេ ភណតិ សុមេធា មា ឯទិសកានិ ភវគតំ អសារំ**
**បព្វជ្ជា វា ហោតុ មរណំ វា តេនចេវ វារេយ្យំ ។**

---
១.ប្រែតាមបាលីលេខយោង ។





គ្រានោះ ព្រះនាងសុមេធា ក្រាបទូលមាតាបិតានោះថា សម្បត្តិទាំងឡាយប្រាកដដូច្នេះ ចូរកុំមាន (ដល់ខ្ញុំម្ចាស់ ) ភពជារបស់គ្មានខ្លឹមសារ បព្វជ្ជា ឬមរណៈ ចូរមានដល់ខ្ញុំម្ចាស់ ព្រោះហេតុនោះ កិច្ចដែលគេត្រូវដណ្តឹង (ចូរកុំមានដល់ខ្ញុំម្ចាស់ឡើយ )។

**កិមិវ បូតិកាយំ អសុចឹ សវនគន្ធំ ភយានកំ**
**កុណបំ អភិសំវិសេយ្យំ គត្តំ សកិបគ្ឃរិតំ អសុចិបុណ្ណំ ។**

(សរីរៈនេះ ) ដូចជាដង្កូវ ជាកាយស្អុយ មិនស្អាត មានក្លិនផ្សាយទៅ គួរឱ្យខ្លាច ដូចជាការុងជាវិការនៃស្បែក ពេញដោយសាកសព ពេញដោយរបស់មិនស្អាត ដែលហូរចេញក្នុងកាលម្តង ។ ។

**កិមិវ តាហំ ជានន្តី វិកូលកំ មំសសោហិតុបលិត្តំ**
**កិមិកុលាលយំ សកុណភត្តំ កឡេវរំ កិស្សទិយ្យតីតិ ។**

ខ្ញុំម្ចាស់ដឹងនូវសរីរៈនោះថា ដូចជាអ្វីមួយ ដែលបូកលាបដោយសាច់និងឈាម ជារបស់គួរខ្ពើមក្រៃពេក ជាលំនៅនៃហ្វូងដង្កូវ ជាចំណីនៃសត្វស្លាប ជាសាកសព (គេ ) នឹងឱ្យដល់អ្នកណាម្តេចបាន ។

និព្ពុយ្ហតិ សុសានំ អចិរំ   កាយោ អបេតវិញ្ញាណោ
ឆឌ្ឌិតោ កលិង្គរំ វិយ   ជិគុច្ឆមានេហិ ញាតីហិ ៕

កាយដែលមានវិញ្ញាណប្រាសចេញហើយ មិនយូរប៉ុន្មាន គេតែងដុតក្នុងព្រៃស្មសាន ពួកញាតិដែលខ្ពើមរអើម ក៏បោះបង់ចោល ដូចជាអង្កត់អុស ។

ឆឌ្ឌន នំ សុសានេ បរភត្តំ   ឆ្វាយន្តិ ជិគុច្ឆន្តា
និយកា មាតាបិតរោ   កឹ បន សាធារណា ជនតា ៕

មាតាបិតារបស់ខ្លួន ចោលសាកសពនោះ ឱ្យជាចំណីសត្វដទៃក្នុងព្រៃស្មសាន ខ្ពើមរអើម ងូតលាង (ខ្លួនដើរចេញទៅ ) ចំណង់បើសាធារណជន (នឹងមិនខ្ពើម ) ដូចម្ដេចកើត ។

អជ្ឈោសិតា អសារេ កឡេវរេ   អដ្ឋិន្ហារុសង្ឃាតេ
ខេឡស្សុមុច្ចាននសាវ   បរិបុណ្ណេ បូតិកាយម្ហិ ៕

សត្វទាំងឡាយតែងជ្រុលជ្រប់ក្នុងគ្រោងកាយ ជាសាកសពឥតខ្លឹមសារ ដែលសង្ខារផ្សំផ្គុំដោយឆ្អឹងនិងសរសៃ ជាកាយស្អុយពេញដោយទឹកមាត់ ទឹកភ្នែក ទឹកសម្បោរ និងទឹករងៃ ។

យោ នំ វិនិព្ភុជិត្វា   អព្ភន្តរមស្ស ពាហិរំ
កយិរា គន្ធស្ស អសហមានា សកាបិ មាតា ជិគុច្ឆេយ្យ ៕

បើបុគ្គលពន្លាត់រាងកាយនោះ ធ្វើអាការខាងក្នុងនៃវាឱ្យត្រឡប់មកខាងក្រៅវិញ សូម្បីមាតារបស់ខ្លួនក៏ខ្ពើមរអើមអត់ទ្រាំនឹងក្លិនពុំបាន ។

ខន្ធធាតុអាយតនំ   សង្ខតំ ជាតិមូលកំ
ទុក្ខំ យោនិសោ អរុចឹ ភណន្តិ   វារេយ្យំ កិស្ស ឥច្ឆេយ្យំ ៕

ខ្ញុំម្ចាស់និយាយដោយឧបាយនៃប្រាជ្ញានូវខន្ធ ធាតុ អាយតនៈ ដែលសង្ខារតាក់តែង ថាមានជាតិជាឫសគល់ នាំមកនូវ ទុក្ខមិនជាទីពេញចិត្ត នឹងប្រាថ្នានូវកិច្ចដែលគេត្រូវដណ្ដឹងដើម្បីអ្វី ។

ទិវសេ ទិវសេ តិសត្តិសតានិ   នវនវា បាតេយ្យុំ កាយម្ហិ
វស្សសតម្បិ បឃាតោ   សេយ្យោ ទុក្ខស្ស ចេវ ខយោ ៕

លំពែង ៣ រយ ដែលសំលៀងថ្មីៗ គប្បីធ្លាក់ចុះលើកាយរាល់ៗ ថ្ងៃ ប្រសិនបើ ការអស់ទៅនៃទុក្ខ សូម្បីមានការលំបាក (យ៉ាងនេះ ) អស់រយឆ្នាំ ជាការប្រសើរ ។

**អជ្ឈុបគច្ឆេ យាតំ យោ  វិញ្ញូ ឯវំ សត្ថុនោ វចនំ**
**ឆីយោ ច តេសំ សំសារោ បុនប្បុនំ ហញ្ញមានានំ ៕**

បុគ្គលណា ដឹងព្រះពុទ្ធដីការបស់ព្រះសាស្តា យ៉ាងនេះ ហើយបានទទួលនូវសេចក្តីលំបាក (ការអស់ទៅនៃទុក្ខតែងមានដល់បុគ្គលនោះ) សង្សារ (ការអន្ទោលទៅ) របស់បុគ្គលពាលទាំងឡាយ ដែលលំបាករឿយៗ ជាសង្សារវែងឆ្ងាយ ។

**ទេវេសុ មនុស្សេសុ ច  តិរច្ឆានយោនិយា អសុរកាយេសុ**
**បេតេសុ ច និរយេសុ ច  អបរិមិតា ឌិស្សន្តេ ឃាតា ៕**

ការលំបាកតានតឹងមិនមានប្រមាណ រមែងប្រាកដក្នុងពួកទេវតា ពួកមនុស្ស ក្នុងកំណើតតិរច្ឆាន ក្នុងពួកអសុរកាយ ក្នុងពួកប្រេត និងក្នុងពួកនរក ។

**និរយេសុ ពហូ វិនិបាត-  គតស្ស កិលិស្សមានស្ស**
**ទេវេសុបិ អត្តាណំ  និព្វានសុខា បរំ នត្ថិ ៕**

ក្នុងនរកមានសេចក្តីលំបាកច្រើន សត្វដែលកើតក្នុងវិនិបាតក៏លំបាក សូម្បីក្នុងពួកទេវតា ក៏មិនមានទីពឹង សេចក្តីសុខដទៃក្រៃលែងជាងសេចក្តីសុខក្នុងព្រះនិព្វាន មិនមានទេ ។





**បត្តា តេ និព្វានំ យេ យុត្តា ទសពលស្ស បាវចនេ**
**អប្បោស្សុក្កា ឃដេន្តិ  ជាតិមរណប្បហានាយ ៕**

បុគ្គលពួកណា ខំប្រឹងប្រែងក្នុងសាសនារបស់ព្រះទសពល ជាអ្នកមានសេចក្តីខ្វល់ខ្វាយតិច ខំព្យាយាមលះបង់ជាតិនិងមរណៈ បុគ្គលពួកនោះក៏បានដល់នូវព្រះនិព្វាន ។

**អជ្ជេវ តាត អភិនិក្ខមិស្សំ ភោគេហិ កឹ អសារេហិ**
**និព្វិណ្ណា មេ កាមា  វន្តសមា តាលវត្ថុកតា ៕**

បពិត្រព្រះបិតា ខ្ញុំម្ចាស់នឹងចេញបួសក្នុងថ្ងៃនេះប្រយោជន៍អ្វីដោយភោគៈទាំងឡាយ ដែលឥតខ្លឹមសារ កាមទាំងឡាយទុកស្មើនឹងវត្ថុដែលគេខ្ជាក់ចោល ខ្ញុំម្ចាស់នឿយណាយហើយ ធ្វើឱ្យដូចដើមត្នោតដែលដាច់ក មានតែទីតាំង(មិនអាចដុះតទៅទៀតបាន)។

ព្រះនាងសុមេធានោះ កំពុងតែនិយាយនឹងបិតាយ៉ាងនេះ ស្រាប់តែព្រះបាទអនិករត្តៈ ដែលបិតាបានថ្វាយនាងឱ្យដល់ទ្រង់ស្តេចព្រះរាជដំណើរចូលទៅដល់ ដោយមានពួកកំលោះហែហម (ព្រោះ) ការត្រូវដណ្តឹងមានក្នុងកាលប្រាកដហើយ ។ ក្នុងកាលនោះ នាងសុមេធា កាត់នូវសក់ទាំងឡាយ ដែលមានពណ៌ខ្មៅ

រលើប ស្លូតទន់ ដោយព្រះខាន់ ហើយបិទទ្វារប្រាសាទ រួចចូលបឋមជ្ឈាន ។ នាងសុមេធាកំពុងតែចូលសមាបត្តិ ចម្រើននូវអនិច្ចសញ្ញាលើប្រាសាទ គាប់ចួនស្តេចអនិករត្តៈក៏យាងមកដល់នគរ ។ នាងសុមេធានោះ កំពុងតែធ្វើទុកក្នុងចិត្ត (នូវអនិច្ចសញ្ញា) ស្តេចអនិករត្តៈ ដែលស្អិតស្អាងព្រះអង្គ ដោយគ្រឿងអលង្ការជាវិការៈកែវមណីនិងមាស ក៏ឡើងមកដោយរួសរាន់ ហើយធ្វើអញ្ជលីអង្វរនាងសុមេធាថា ។ អាជ្ញាក្នុងរាជ្យរបស់យើង ទ្រព្យនិងឥស្សរិយយស (ក៏មានច្រើន ) ភោគសម្បត្តិទាំងឡាយ នាំមកនូវសេចក្តីសុខ ទាំងខ្លួននាងសោត ក៏នៅក្រមុំ នាងចូរប្រើប្រាស់ភោគសម្បត្តិតាមប្រាថ្នាចុះ (ព្រោះថា ) កាមសុខក្នុងលោក គេរកបានដោយកម្រណាស់ ។ រាជសម្បត្តិ យើងប្រគល់ផ្តាច់ឱ្យនាង នាងចូរប្រើប្រាស់នូវភោគសម្បត្តិទាំងឡាយ ចូរឱ្យនូវទានចុះ នាងកុំតូចចិត្តឡើយ មាតាបិតារបស់នាង ជាទុក្ខ ។

**តន្តំ ភណតិ សុមេធា  កាមេហិ អនត្ថិកា វិគតមោហា**
**មា កាមេ អភិនន្ទិ  កាមេស្វាទីនវំ បស្ស ។**

នាងសុមេធា ជាស្រ្តីមិនត្រូវការដោយកាម មានមោហៈទៅប្រាសហើយ ក៏ទូលតបស្តេចអនិករត្តៈនោះថា ព្រះអង្គកុំត្រេកត្រអាលចំពោះកាមទាំងឡាយ ព្រះអង្គចូរឃើញទោសក្នុងកាមទាំងឡាយវិញ ។



**ចាតុទ្ទីបោ រាជា មន្ធាតា  អាសិ កាមភោគិនំ អគ្គោ**
**អតិត្តោ កាលកតោ  ន ចស្ស បរិបូរិតា ឥច្ឆា ។**

ព្រះរាជាទ្រង់ព្រះនាមមន្ធាតុ ជាធំលើទ្វីបទាំងបួន ជាបុគ្គលប្រសើរបំផុត ជាងពួកជនអ្នកបរិភោគកាម ទ្រង់មិនឆ្អែតឆ្អន់ (ដោយកាមទាំងឡាយ ) ទ្រង់ទិវង្គតទៅ សេចក្តីប្រាថ្នារបស់ស្តេចនោះ នៅតែមិនពេញគ្រប់គ្រាន់នៅឡើយ ។

**សត្ត រតនានិ វស្សេយ្យ  វុដ្ឋិមា ទសទិសា សមន្តេន**
**ន ចត្ថិ តិត្តិ កាមានំ  អតិត្តាវ មរន្តិ នរា ។**

ភ្លៀងគប្បីបង្អុរចុះនូវរតនៈទាំងឡាយ ៧ ប្រការ ជុំវិញគ្រប់ទិសទាំង ១០ សេចក្តីឆ្អែតចំពោះកាមទាំងឡាយក៏នៅតែមិនល្មម ពួកនរជន រមែងស្លាប់ទៅទាំងមិនឆ្អែត ។

**អសិសូលូបមា កាមា  កាមា សប្បសិរោបមា**
**ឧក្កោបមា អនុទហន្តិ  អដ្ឋិកង្កាលសន្និភា ។**

កាមទាំងឡាយប្រៀបដូចដាវនិងឈើស្រួច កាមទាំងឡាយ

ប្រៀបដូចក្បាលនៃពស់ ឬប្រៀបដូចជាគប់ភ្លើង ក្រៀមក្រោះ ដូចជារាងឆ្អឹង តែងដុតកម្តៅរឿយ ៗ ។

**អនិច្ចា អទ្ធុវា កាមា ពហុទុក្ខា មហាវិសា**
**អយោគុឡោវ សន្តត្តោ អឃមូលា ទុក្ខប្ផលា ៕**

កាមទាំងឡាយ មិនទៀងទាត់ មិនឋិតថេរ មានទុក្ខច្រើន មានពិសខ្លាំង មានសេចក្តីតានតឹងជាឫសគល់ មានសេចក្តីទុក្ខជាផល ដូចជាដុំដែកដែលកំពុងឆេះ ។

**រុក្ខប្ផលូបមា កាមា មំសបេសូបមា ទុខា**
**សុបិនោបមា វញ្ចនិយា កាមា យាចិតកូបមា ៕**

កាមទាំងឡាយ ប្រៀបដូចជាផ្លែឈើ ឬប្រៀបដូចដុំសាច់នាំមកនូវទុក្ខ កាមទាំងឡាយដូចការយល់សប្តិ ជាគ្រឿងបញ្ឆោតដូចជារបស់ខ្ចីគេ ។

**សត្តិសូលូបមា កាមា រោគោ គណ្ឌោ អឃំ និឃំ**
**អង្គារកាសុសទិសា អឃមូលំ ភយំ វធោ ៕**

កាមទាំងឡាយ ដូចជាលំពែងនិងដែកស្រួច ដូចជារោគ ឬ





ដូចជាបូស ជាគ្រឿងតានតឹង ចង្អៀតចង្អល់ កាមទាំងឡាយប្រាកដស្មើដោយរណ្តៅនៃរងើកភ្លើង មានសេចក្តីតានតឹងជាឫសជាភ័យ ជាខ្មាំង ។

**ឯវំ ពហុទុក្ខា កាមា អក្ខាតា អន្តរាយិកា**
**គច្ឆថ ន មេ ភវគតេ វិស្សាសោ អត្ថិ អត្តនោ ៕**

កាមទាំងឡាយ មានសេចក្តីទុក្ខច្រើនយ៉ាងនេះ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ជាសភាវៈធ្វើនូវសេចក្តីអន្តរាយ សូមព្រះអង្គយាងទៅវិញចុះ សេចក្តីស្និទ្ធស្នាលក្នុងភពរបស់ខ្ញុំម្ចាស់មិនមានទេ ។

**កឹ មម បរោ ករិស្សតិ អត្តនោ សីសម្ហិ ឌយ្ហមានម្ហិ**
**អនុពន្ធេ ជរាមរណេ តស្ស ឃាតាយ ឃដិតព្វំ ៕**

បុគ្គលដទៃនឹងធ្វើនូវប្រយោជន៍ដូចម្តេច ដល់ខ្ញុំម្ចាស់កើតកាលបើក្បាលរបស់ខ្លួនត្រូវភ្លើងឆេះ កាលបើជរាមរណៈកំពុងជាប់តាម ខ្ញុំម្ចាស់ត្រូវប្រឹងប្រែង ដើម្បីកម្ចាត់បង់នូវជរាមរណៈនោះ ។

ព្រះនាងសុមេធា លុះឃើញមាតាបិតា និងស្តេចអនិករត្ត: ដែលមកមិនទាន់ដល់ទ្វារ កំពុងគង់យំលើផែនដី ក៏ទូលនូវពាក្យនេះថា :

**ទីឃោ ពាលាន សំសារោ បុនប្បុនញ្ច រោទតំ**
**អនមតគ្គេ បិតុ មរណេ ភាតុ វធេ អត្តនោ ច វធេ ។**

សង្សាររបស់បុគ្គលអន្ធពាល ដែលយំទួញញយ១ ចំពោះសេចក្តីស្លាប់ របស់បិតា សេចក្តីស្លាប់របស់បងប្អូន និងសេចក្តីស្លាប់របស់ខ្លួន ក្នុងសង្សារវដ្តដែលគេមិនអាចដឹងទីបំផុតបាន ជាសង្សារវែងឆ្ងាយ ។

**អស្សុ ថញ្ញំ រុធិរំ សំសារំ អនមតគ្គតោ សរថ**
**សត្តានំ សំសរិតំ សរាហិ អដ្ឋីនញ្ច សន្និចយំ ។**

សូមទ្រង់ទាំងឡាយរលឹកនូវទឹកភ្នែក ទឹកដោះ និងឈាមកាលទ្រង់អន្ទោលទៅ ព្រោះសង្សារដែលគេមិនអាចដឹងទីបំផុតបាន សូមទ្រង់រលឹកនូវគំនរឆ្អឹងទាំងឡាយ របស់ពួកសត្វដែលអន្ទោលទៅមក១ ។



**សរ ចតុរោទធី ឧបនីតេ អស្សុថញ្ញរុធិរម្ហិ**
**សរ ឯកកប្បមដ្ឋីនំ សញ្ចយំ វិបុលេន សមំ ។**

សូមទ្រង់រលឹកដល់ទឹកភ្នែក ទឹកដោះ និងឈាម ដែលប្រៀបធៀបនឹងសមុទ្រធំទាំង ៤ សូមទ្រង់រលឹកនូវគំនរនៃឆ្អឹងទាំងឡាយក្នុងកប្បមួយ១ ដែលស្មើនឹងភ្នំវេបុល្ល: ។

**អនមតគ្គេ សំសរតោ មហឹ ជម្ពុទីបមុបនីតំ**
**កោលដ្ឋិមត្តគុឡិកា មាតាបិតូស្វេវ នប្បហោន្តិ ។**

ដុំដីប៉ុនគ្រាប់ក្រពៅ ដែលបុគ្គលលញ់ដីអស់ទាំងជម្ពូទ្វីប ក៏មិនល្មម គឺតិចជាងមាតាបិតាទាំងឡាយរបស់សត្វ កាលអន្ទោលទៅក្នុងសង្សារ ដែលគេមិនអាចដឹងទីបំផុតបាន ។

**សរ តិណកដ្ឋសាខាបលាសំ ឧបនីតំ អនមតគ្គតោ**
**បិតូសុ ចតុរង្គុលិកា ឃដិកា បិតុបិតូស្វេវ នប្បហោន្តិ ។**

សូមទ្រង់រលឹកនូវស្មៅ កំណាត់ឈើ មែកឈើនិងស្លឹកឈើ ដែលគេនាំមកប្រៀបធៀប គឺខ្នាច់ទាំងឡាយ (របស់ស្មៅជាដើមនោះ) ប្រមាណបួនធ្នាប់ ១ ក៏មិនល្មមស្មើនឹងបិតា និងជីតាទាំងឡាយដែរ ព្រោះសង្សារមានទីបំផុតគេមិនអាចដឹងបាន ។

**សរ កាណកច្ឆបំ បុព្វេ សមុទ្ទេ អបរតោ ច យុគច្ឆិទ្ទំ**
**សិរំ តស្ស ច បដិមុក្កំ មនុស្សលាភម្ហិ ឱបម្មំ ។**

សូមទ្រង់នឹកមើលនូវអណ្តើកខ្វាក់ និងប្រហោងនឹម (ដែលខ្យល់បក់បង្វិល ) ទៅក្នុងសមុទ្រ អំពីត្រើយខាងកើតទៅត្រើយដទៃទៀត និងក្បាលអណ្តើកនោះ ដែលចូលទៅ (ក្នុងប្រហោងនឹម ) នេះ ជាសេចក្តីឧបមាក្នុងការបានអត្តភាពជាមនុស្ស ។

**សរ រូបំ ផេណបិណ្ឌូបមស្ស កាយកលិនោ អសារស្ស**
**ខន្ធេ បស្ស អនិច្ចេ សរាហិ និរយេ ពហុវិឃាតេ ។**

សូមទ្រង់រលឹកនូវរូបកាយជាទោស ឥតខ្លឹមសារ មានឧបមាដូចដុំនៃពពុះទឹក សូមទ្រង់ឃើញនូវខន្ធទាំងឡាយ ថាជាសភាវៈមិនទៀងទាត់ សូមទ្រង់រលឹកនូវនរកទាំងឡាយ ដែលមានសេចក្តីទុក្ខក្តួលក្តៅជាច្រើន ។

**សរ កដសី វឌ្ឍេន្តេ បុនប្បុនំ តាសុ តាសុ ជាតីសុ**
**សរ កុម្ភីលភយានិ ច សរាហិ ចត្តារិ សច្ចានិ ។**

សូមទ្រង់រលឹកនូវសត្វទាំងឡាយ ដែលញ៉ាំងទីស្មសានឱ្យចម្រើនរឿយៗ ក្នុងជាតិទាំងឡាយនោះៗ សូមរលឹកនូវភ័យក្នុងការចិញ្ចឹមពោះផង សូមរលឹកនូវអរិយសច្ចទាំង ៤ ផង ។





**អមតម្ហិ វិជ្ជមានេ កិំ តវ បញ្ចកដុកេន បីតេន**
**សព្វា ហិ កាមរតិយោ កដុកតរា បញ្ចកដុកេន ។**

កាលបើអមតធម៌មាន ប្រយោជន៍អ្វី ដោយហេតុក្តៅផ្សា(១) ៥ យ៉ាង ដែលទ្រង់សោយហើយ ដ្បិតតម្រេកក្នុងកាមទាំងអស់ក្តៅផ្សាក្រៃពេក ព្រោះហេតុក្តៅផ្សា ៥ យ៉ាង ។

**អមតម្ហិ វិជ្ជមានេ**
**កិំ តវ កាមេហិ យេ បរិឡាហា**
**សព្វា ហិ កាមរតិយោ**
**ជលិតា ច កុថិតា កុបិតា សន្តាបិតា ។**

កាលបើអមតធម៌ មាន ទ្រង់មានប្រយោជន៍អ្វី ដោយកាមទាំងឡាយ ដែលជារបស់ក្តៅក្រហាយ ដ្បិតតម្រេកក្នុងកាមទាំងអស់ (ត្រូវភ្លើង ១១ កង )ឆេះពុះឡើង ញាប់ញ័រ ក្តៅសព្វ ។

---

១-ហេតុដ៏ក្តៅផ្សារបស់កាមគុណ មាន ៥ យ៉ាង បដ្ឋនា ការប្រាថ្នា ១ បរិយេសនា ការស្វែងរក ១ បរិគ្គហោ ការហួងហែងទុក ១ អារក្ខា ការរក្សាទុកទៅមិនដាច់ ១ បរិភោគោ ការប្រើប្រាស់លៃលក ១ ។ អដ្ឋកថា ។

**អសបត្តម្ហិ សមានេ**
**កឹ តវ កាមេហិ យេ ពហុសបត្តា**
**រាជគ្គិចោរុទកប្បិយេហិ**
**សាធារណា កាមា ពហុសបត្តា ។**

កាលបើធម៌ដែលឥតសត្រូវ (នេក្ខម្មៈ) មាន ទ្រង់មានប្រយោជន៍អ្វី ដោយកាមទាំងឡាយ ដែលមានសត្រូវច្រើន កាមទាំងឡាយ ជាសាធារណៈ មានសត្រូវច្រើន គឺសត្រូវអំពីស្តេច ភ្លើង ចោរ ទឹក និងបុគ្គលមិនជាទីស្រឡាញ់ ។

**មោក្ខម្ហិ វិជ្ជមានេ កឹ តវ កាមេហិ យេសុ វធពន្ធោ**
**កាមេសុ ហិ វធពន្ធោ កាមកាមា ទុក្ខានិ អនុភោន្តិ ។**

កាលបើព្រះនិព្វាន មាន ទ្រង់មានប្រយោជន៍អ្វី ដោយកាមទាំងឡាយ ដែលជាគ្រឿងសម្លាប់ ជាគ្រឿងចង ព្រោះថាកាមទាំងឡាយ តែងមានគ្រឿងសម្លាប់និងគ្រឿងចង ពួកសត្វនេះ តែងទទួលសេចក្តីទុក្ខទាំងឡាយ ព្រោះតែការប្រាថ្នាកាម ។

**អាទីបិតា តិណុក្កា គណ្ហន្តំ ទហន្តិ នេវ មុញ្ចន្តិ**
**ឧក្កោបមា ហិ កាមា ទហន្តិ យេ តេ ន មុញ្ចន្តិ ។**





គប់ស្នៅ ដែលភ្លើងកំពុងឆេះ តែងឆេះនូវបុគ្គលអ្នកកាន់ មិនលែងចេញ ព្រោះថាកាមទាំងឡាយ ប្រៀបដូចជាគប់ភ្លើង តែងឆេះនូវពួកសត្វ ដែលមិនលែងចេញ ។

**មា អប្បកស្ស ហេតុ កាម- សុខស្ស វិបុលំ ជហិ សុខំ**
**មា បុថុលោមោវ ពលិសំ គិលិត្វា បច្ឆា វិហញ្ញសិ ។**

សូមទ្រង់កុំលះបង់ នូវសេចក្តីសុខដ៏ធំទូលាយ ព្រោះហេតុតែសុខក្នុងកាមបន្តិចបន្តួចឡើយ សូមទ្រង់កុំក្តៅក្រហាយក្នុងកាលជាខាងក្រោយ ដូចជាត្រីលេបនូវសន្ទូច ។

**កាមេហិ មា បរិព្ភមសិ សុនខោវ សង្ខលាពន្ធោ**
**កាហន្តិ ខុ តំ កាមា ឆាតា សុនខំវ ចណ្ឌាលា ។**

សូមទ្រង់កុំច្រាស់ច្រាល់ ព្រោះតែកាមទាំងឡាយ ដូចសុនខ ដែលគេចងភ្ជាប់នឹងបង្គោល ឱសត្វទាំងឡាយ ជាអ្នកស្រេកឃ្លាន តែងធ្វើតាមសេចក្តីប្រាថ្នា ដូចជាពួកចណ្ឌាល (ព្រានបណ្តើរឆ្កែ ដល់នូវសេចក្តីវិនាស ព្រោះបាន) នូវឆ្កែ ។

**អបរិមិតញ្ច ទុក្ខំ ពហូនិ ច ចិត្តទោមនស្សានិ**
**អនុភោហិសិ កាមយុត្តោ បជិនិស្សជ្ជ អន្តវេ កាមេ ។**

បើទ្រង់ប្រកបខ្លួនក្នុងកាម នឹងរងទុក្ខ មិនមានប្រមាណផង រងទោមនស្សក្នុងចិត្តដ៏ច្រើនផង សូមទ្រង់ លះបង់កាមទាំងឡាយ ជារបស់មិនទៀងចេញ ។

**អជរម្ហិ វិជ្ជមានេ កឹ តវ កាមេហិ យេសុ ជរា**
**មរណព្យាធិគហិតា សព្វា សព្វត្ថ ជាតិយោ ។**

កាលបើព្រះនិព្វាន ជាធម្មជាតិ មិនចេះចាស់ មាន ទ្រង់មានប្រយោជន៍អ្វី ដោយកាមទាំងឡាយ ជារបស់ចាស់ កំណើតទាំងអស់ក្នុងភពទាំងពួង (សុទ្ធតែ) ត្រូវមរណៈនិងព្យាធិរឹបជាន់ ។

**ឥទមជរមិទមមរណំ ឥទមជរាមរណមិទមសោកំ**
**អសបត្តមសម្ពាធំ អខលិតមភយំ និរុបតាបំ ។**

ព្រះនិព្វាននេះ មិនចាស់ ព្រះនិព្វាននេះមិនស្លាប់ ព្រះនិព្វាននេះ ជាបទដែលមិនចាស់ មិនស្លាប់ មិនមានសោក មិនមានសត្រូវ មិនចង្អៀត មិនភ្លាំងភ្លាត់ មិនមានភ័យ មិនក្តៅរោលរាល ។





**អធិគតមិទំ ពហុហិ អមតំ អជ្ជាបិ ច លភនីយំ ឥទំ**
**យោ យោនិសោ បយុញ្ជតិ ន ច សក្កា អឃដមានេន ។**

អមតនិព្វាននេះ ព្រះអរិយៈទាំងឡាយ មានព្រះពុទ្ធជាដើមច្រើនរូបបានហើយ មិនតែប៉ុណ្ណោះទេ ព្រះនិព្វាននេះ គេគប្បីបានក្នុងកាលសព្វថ្ងៃនេះ បុគ្គលណាព្យាយាម ដោយឧបាយប្រាជ្ញា (បុគ្គលនោះ រមែងបាននូវព្រះនិព្វាន ) តែបុគ្គលដែលមិនមានសេចក្តីប្រឹងប្រែង មិនអាចបាននូវព្រះនិព្វានឡើយ ។

នាងសុមេធា មិនបាននូវសេចក្តីត្រេកអរក្នុងសង្ខារ បានពោលហើយ យ៉ាងនេះឯង នាងសុមេធា កាលពន្យល់ស្តេចអនិករត្តៈហើយ ក៏បោះសក់ទាំងឡាយចោលលើផែនដី ។ ស្តេចអនិករត្តៈនោះក្រោកឡើង ផ្គងអញ្ជលីអង្វរបិតារបស់នាងសុមេធានោះថា សូមព្រះអង្គអនុញ្ញាត បើកឱកាសដល់ព្រះរាជបុត្រីឈ្មោះនាងសុមេធា ឱ្យបួសចុះ ដើម្បីឱ្យនាងឃើញនូវព្រះនិព្វាន ដែលជាគុណដ៏ទៀងទាត់ ។

នាងសុមេធានោះ ដែលជាស្ត្រីតក់ស្លុតចំពោះសោក និងភ័យ លុះមាតាបិតាបើកឱកាសឱ្យ ក៏បួស ហើយសិក្សានូវអគ្គផលបានធ្វើឱ្យជាក់ច្បាស់នូវអភិញ្ញា ៦ ។ ព្រះនិព្វាននោះ ជាគុណដ៏អស្ចារ្យ ចម្លែក បានកើតមានដល់រាជកញ្ញា លុះក្នុងកាលជាទីបំផុត

(ទៀបនឹងបរិនិព្វាន) នាងបានសម្ដែងនូវបុព្វេនិវាសចរិតថា ។

**ភគវតិ កោនាគមនេ សង្ឃារាមម្ហិ នវនិវេសម្ហិ**
**សខិយោ តិស្សោ ជនិយោ វិហារទានំ អទាសិម្ហា ៕**

កាលព្រះមានព្រះភាគ ទ្រង់ព្រះនាមកោនាគមនៈ (ត្រាស់ឡើងក្នុងលោក) យើងជាសម្លាញ់នឹងគ្នាទាំងបីនាក់ (គឺនាងធនញ្ជានី ១ នាងខេមា ១ ខ្ញុំ ១) បានថ្វាយវិហារទានក្នុងអារាមនៃសង្ឃ ជានិវេសន៍ដ៏ថ្មី ។

**ទសក្ខត្តុំ សតក្ខត្តុំ ទសសតក្ខត្តុំ សតានិ ច សតក្ខត្តុំ**
**ទេវេសុ ឧបបជ្ជិម្ហា កោ បន វាទោ មានុសកេសុ ៕**

(ដោយអានិសង្សនៃវិហារទាននេះ) យើងទាំងឡាយ បានទៅកើតក្នុងពួកទេវតា ១០ ដង ១០០ ដង ១០០០ ដង ១០០០០ ដង នឹងចាំបាច់និយាយទៅថ្វីក្នុងពួកមនុស្ស ។

**ទេវេសុ មហិទ្ធិកា អហុម្ហា មានុសកម្ហិ កោ បន វាទោ**
**សត្តរតនស្ស មហេសី ឥត្ថីរតនំ អហំ អាសិំ ៕**

យើងជាអ្នកមានឫទ្ធិច្រើនក្នុងពួកទេវតា នឹងចាំបាច់និយាយ





ទៅថ្វីក្នុងពួកមនុស្ស ខ្ញុំបានកើតជាស្ត្រីកែវ ជាអគ្គមហេសីនៃស្ដេចដែលមានរតនៈទាំង ៧ ប្រការ ។

**សោ ហេតុ សោ បភវោ តំ មូលំ ច សាសនេ ខមំ**
**តំ បឋមសមោធានំ តំ ធម្មរតាយ និព្វានំ ៕**

អានិសង្សនៃវិហារទាននោះ ជាហេតុ អានិសង្សនោះ ជាប្រភព (ដែនកើត) អំណោយទាននោះ ជាឫសគល់ដ៏ពេញចិត្តក្នុងសាសនា អំណោយទាននោះជាការជួបជុំមុនដំបូង អំណោយទាននោះ ជាហេតុឱ្យរលត់កិលេស (ព្រះនិព្វាន) របស់ខ្ញុំដែលជាអ្នកត្រេកអរក្នុងធម៌ ។

**ឯវំ ភណន្តិ យេ សទ្ទហន្តិ វចនំ អនោមបញ្ញស្ស**
**និព្វិន្ទន្តិ ភវគតេ និព្វិន្ទិត្វា វិរជ្ជន្តីតិ ៕**

ពួកជនណា ជឿនូវព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គមានប្រាជ្ញាមិនថោកថយ ពួកជននោះ រមែងពោលយ៉ាងនេះថា ពួកជន នឿយណាយក្នុងភព គឺសង្សារវដ្ត លុះនឿយណាយហើយ ក៏ប្រាសចាកតម្រេក ។

# ៦_រាហុលសូត្រ

## បិដកលេខ ៥៤ ទំព័រ ១០៧

ព្រះមានព្រះភាគត្រាស់សួរព្រះរាហុលថា :

**កច្ចិ អភិណ្ហសំវាសា នាវជានាសិ បណ្ឌិតំ**
**ឱក្កាធារោ មនុស្សានំ កច្ចិ អបចិតោ តយា ។**

អ្នកមិនមើលងាយអ្នកប្រាជ្ញ ព្រោះតែនៅរួមគ្នារឿយៗទេឬ បុគ្គលអ្នកទ្រោលគប់ភ្លើង បំភ្លឺដល់ពួកមនុស្ស អ្នកកោតក្រែងដែរឬ ។

ព្រះរាហុលដ៏មានអាយុក្រាបទូលថា :

**នាហំ អភិណ្ហសំវាសា អវជានាមិ បណ្ឌិតំ**
**ឱក្កាធារោ មនុស្សានំ និច្ចំ អបចិតោ មយា ។**

ខ្ញុំព្រះអង្គមិនមើលងាយអ្នកប្រាជ្ញព្រោះតែនៅរួមគ្នារឿយៗទេ បុគ្គលអ្នកទ្រោលគប់ភ្លើងបំភ្លឺដល់ពួកមនុស្ស ខ្ញុំព្រះអង្គកោតក្រែងជានិច្ច ។





ព្រះមានព្រះភាគទ្រង់ត្រាស់ប្រទានឱវាទដល់ព្រះរាហុលថា:

**បញ្ច កាមគុណេ ហិត្វា បិយរូបេ មនោរមេ**
**សទ្ធាយ ឃរា និក្ខម្ម ទុក្ខស្សន្តករោ ភវ ។**

អ្នកចូរលះនូវកាមគុណ ៥ មានសភាពជាទីស្រឡាញ់ ជាទីត្រេកអរនៃចិត្ត ចេញចាកផ្ទះមកបួសដោយសទ្ធាហើយ អ្នកចូរធ្វើនូវទីបំផុតនៃទុក្ខចុះ ។

**មិត្តេ ភជស្សុ កល្យាណេ បន្តញ្ច សយនាសនំ**
**វិវិត្តំ អប្បនិគ្ឃោសំ មត្តញ្ញូ ហោហិ ភោជនេ ។**

អ្នកចូរគប់រក នូវកល្យាណមិត្ត និងទីដេក ទីអង្គុយដែលស្ងប់ស្ងាត់ មិនមានសំឡេងគឹកកង ចូរជាអ្នកស្គាល់ប្រមាណក្នុងភោជន ។

**ចីវរេ បិណ្ឌបាតេ ច បច្ចយេ សយនាសនេ**
**ឯតេសុ តណ្ហមាកាសិ មា លោកំ បុនរាគមិ ។**

អ្នកកុំធ្វើបំណង ក្នុងបច្ច័យទាំងនេះ គឺចីវរប្បច្ច័យ បិណ្ឌ-បាតប្បច្ច័យ សេនាសនប្បច្ច័យ និងគិលានប្បច្ច័យឡើយ កុំត្រឡប់មកកាន់លោកទៀតឡើយ ។

សំវុតោ បាតិមោក្ខស្មឹ ឥន្ទ្រិយេសុ ច បញ្ចសុ
សតិ កាយគតា ត្យត្ថុ និព្វិទាពហុលោ ភវ ។

អ្នកចូរសង្រួមក្នុងបាតិមោក្ខផង ក្នុងឥន្ទ្រិយទាំង ៥ ផង ចូរមានស្មារតីប្រព្រឹត្តទៅក្នុងកាយ ចូរជាបុគ្គលច្រើនដោយសេចក្តីនឿយណាយ ។

និមិត្តំ បរិវជ្ជេហិ សុភំ រាគូបសញ្ហិតំ
អសុភាយ ចិត្តំ ភាវេហិ ឯកគ្គំ សុសមាហិតំ
អនិមិត្តញ្ច ភាវេហិ មានានុសយមុជ្ជហ
តតោ មានាភិសមយា ឧបសន្តោ ចរិស្សសីតិ ។

អ្នកចូរលះនូវសុភនិមិត្ត ដែលប្រកបដោយរាគៈ ចូរចម្រើនចិត្តដោយអសុភ ឱ្យជាចិត្តមូលតែមួយ តាំងមាំដោយប្រពៃ មួយទៀត ចូរចម្រើននូវអនិមិត្តវិបស្សនា ចូរលះនូវអនុស័យគឺមានះ លំដាប់តអំពីនោះ អ្នកនឹងប្រព្រឹត្តស្ងប់រម្ងាប់ ព្រោះលះបង់មានះ ។

ព្រះមានព្រះភាគ ទ្រង់ទូន្មានព្រះរាហុលដ៏មានអាយុជារឿយៗ ដោយគាថាទាំងនេះ ដោយប្រការយ៉ាងនេះឯង ។



## ៧-ជរាសូត្រ

### បិដកលេខ ៥៤ ទំព័រ ២៧៥

(ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងព្រះសូត្រនេះ នៅនគរ សាកេត)

អប្បំ វត ជីវិតំ ឥទំ ឱរំ វស្សសតាបិ មិយ្យតិ
សចេបិ អតិច្ច ជីវតិ អថខោ សោ ជរសាបិ មិយ្យតិ ។

ជីវិតនេះមានប្រមាណតិចហ្ន៎ សត្វតែងស្លាប់ថយអំពី ១០០ ឆ្នាំ ប្រសិនបើរស់ហួសពី ១០០ ឆ្នាំ សត្វនោះនឹងស្លាប់ដោយជរាជាប្រាកដ ។

សោចន្តិ ជនា មមាយិតេ ន ហិ សន្តិ និច្ចា បរិគ្គហា
វិនាភាវសន្តមេវិទំ ឥតិ ទិស្វា នាគារមាវសេ ។

ជនទាំងឡាយតែងសោក ព្រោះវត្ថុដែលប្រកាន់ថា របស់យើង សេចក្តីប្រកាន់ជារបស់ទៀងទាត់មិនមានឡើយ ជីវិតនេះមានការព្រាត់ប្រាសចាករបស់ដែលមានជាធម្មតា អ្នកប្រាជ្ញលុះឃើញដូច្នេះហើយ រមែងមិននៅគ្រប់គ្រងផ្ទះឡើយ ។

**មរណេនបិ តំ បហីយតិ យំ បុរិសោ មមយិទន្តិ មញ្ញតិ**
**ឯតម្បិ វិទិត្វា បណ្ឌិតោ ន មមត្តាយ នមេថ មាមកោ ។**

បុរសសំគាល់របស់ណាថា នេះជារបស់អញ រមែងលះរបស់នោះដោយមរណៈ ឯអ្នកប្រាជ្ញរាប់អានព្រះរតនត្រ័យ ជ្រាបច្បាស់នូវទោសនោះហើយ រមែងមិនបង្អោន (ចិត្ត) ទៅ ដើម្បីសេចក្តីប្រកាន់ថា របស់យើងឡើយ ។

**សុបិនេន យថាបិ សង្គតំ បដិពុទ្ធោ បុរិសោ ន បស្សតិ**
**ឯវម្បិ បិយាយិតំ ជនំ បេតំ កាលកតំ ន បស្សតិ ។**

បុរសអ្នកភ្ញាក់ (ពីដេក) រមែងមិនឃើញរូបារម្មណ៍ជាដើម ដែលមកជួបប្រទះ ដោយការយល់សប្តិ យ៉ាងណាមិញ បុគ្គលមិនឃើញជនជាទីស្រឡាញ់ ដែលធ្វើកាលកិរិយាទៅកាន់លោកខាងមុខ ក៏យ៉ាងនោះដែរ ។

**ទិដ្ឋាបិ សុតាបិ តេ ជនា យេសំ នាមមិទំ បវុច្ចតិ**
**នាមមេវាវសិស្សតិ អក្ខេយ្យំ បេតស្ស ជន្តុនោ ។**

ជនទាំងនោះដែលគេឃើញហើយ ឮហើយ គេតែងហៅឈ្មោះ កាលលះលោកនេះទៅ នៅសល់តែឈ្មោះសម្រាប់ហៅប៉ុណ្ណោះ ។





**សោកបរិទេវមច្ឆរំ ន ជហន្តិ គិទ្ធា មមាយិតេ**
**តស្មា មុនយោ បរិគ្គហំ ហិត្វា អចរឹសុ ខេមទស្សិនោ ។**

ពួកសត្វមានសេចក្តីលោភ តែងមិនលះបង់ នូវសេចក្តីសោកខ្សឹកខ្សួលនិងសេចក្តីកំណាញ់ ក្នុងវត្ថុដែលជាទីរាប់អានបានឡើយ ព្រោះហេតុនោះ អ្នកប្រាជ្ញទាំងឡាយដែលឃើញព្រះនិព្វានថាជាទីក្សេមហើយ រមែងលះបង់សេចក្តីប្រកាន់បាន ។

**បដិលីនចរស្ស ភិក្ខុនោ ភជមានស្ស វិវិត្តមាសនំ**
**សាមគ្គិយមាហុ តស្ស តំ យោ អត្តានំ ភវនេ ន ទស្សយេ ។**

ភិក្ខុណាមិនសម្តែងខ្លួនក្នុងភព(ថ្មីទៀត) អ្នកប្រាជ្ញទាំងឡាយហៅអំពើនោះ របស់ភិក្ខុនោះ ដែលជាអ្នកប្រព្រឹត្តជៀសគេច និងជាអ្នកភប់ប្រសព្វអាសនៈស្ងាត់ ថាជាការសមរម្យហើយ ។

**សព្វត្ថ មុនី អនិស្សិតោ ន បិយំ កុព្វតិ នោបិ អប្បិយំ**
**តស្មឹ បរិទេវមច្ឆរំ បណ្ណេ វារិ យថា ន លិម្បតិ ។**

អ្នកប្រាជ្ញមិនបានអាស្រ័យ ក្នុងអាយតនៈទាំងអស់ឡើយ មិនធ្វើសត្វនិងសង្ខារឱ្យជាទីស្រឡាញ់ ទាំងមិនធ្វើសត្វនិងសង្ខារឱ្យមិនជាទីស្រឡាញ់ សេចក្តីខ្សឹកខ្សួលនិងសេចក្តីកំណាញ់មិនជាប់

ក្នុងសន្តានរបស់ព្រះខីណាស្រពនោះ ដូចទឹកមិនប្រឡាក់លើស្លឹកឈូកដូច្នោះដែរ ។

**ឧទកពិន្ទុ យថាបិ បោក្ខរេ បទុមេ វារិ យថា ន លិម្បតិ**
**ឯវំ មុនី នោ បលិម្បតិ យទិទំ ទិដ្ឋំ សុតំ មុតេសុ វា ។**

ដំណក់ទឹកមិនជក់នៅលើស្លឹកឈូក ដូចម្តេចក្តី ទឹកមិនទទឹកនាផ្កាឈូកដូចម្តេចក្តី អ្នកប្រាជ្ញមិនជាប់នៅក្នុងអារម្មណ៍ណានីមួយ ដែលបានឃើញ ដែលបានឮ ឬដែលបានប៉ះពាល់ ក៏ដូច្នោះដែរ ។

**ធោនោ ន ហិ តេន មញ្ញតិ យទិទំ ទិដ្ឋំ សុតំ មុតេសុ វា**
**នាញ្ញេន វិសុទ្ធិមិច្ឆតិ ន ហិ សោ រជ្ជតិ នោ វិរជ្ជតីតិ ។**

មួយទៀត ព្រះអរហន្តមិនសំគាល់ក្នុងអារម្មណ៍ណានីមួយ ដែលបានឃើញ ដែលបានឮ ឬដែលបានប៉ះពាល់ ដោយវត្ថុនោះៗឡើយ ទាំងមិនប្រាថ្នាការស្អាតដោយវត្ថុដទៃទេ ព្រោះព្រះអរហន្តនោះមិនត្រេកត្រអាល ហើយក៏មិនមែនប្រទូស្តទាស់ មានទូវទោមនស្ស (ដូចកល្យាណបុថុជ្ជន និងសេក្ខបុគ្គល) ឡើយ ។





## ៨-អត្តទណ្ឌសូត្រ

**បិដកលេខ ៥៤ ទំព័រ ៣១៣**

(ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់សម្តែងប្រោសព្រះញាតិដែលកំពុងឈ្លោះគ្នា ឱ្យមានមេត្រីភាពនឹងគ្នាវិញ)

**អត្តទណ្ឌា ភយំ ជាតំ ជនំ បស្សថ មេធគំ**
**សំវេគំ កិត្តយិស្សាមិ យថា សំវិជិតំ មយា ។**

(ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា) ភ័យកើតមកពីអាជ្ញារបស់ខ្លួន (សេចក្តីប្រព្រឹត្តកាចអាក្រក់របស់ខ្លួន) អ្នកទាំងឡាយចូរមើលជនអ្នកទាស់ទែងគ្នា តថាគត (កាលនៅជាពោធិសត្វ) បានតក់ស្លុតហើយ យ៉ាងណា តថាគតនឹងសម្តែង នូវសេចក្តីតក់ស្លុត យ៉ាងនោះ (ដល់អ្នកទាំងឡាយ)។

**ផន្ទមានំ បជំ ទិស្វា មច្ឆេ អប្បោទកេ យថា**
**អញ្ញមញ្ញេហិ ព្យារុទ្ធេ ទិស្វា មំ ភយមាសិវិ ។**

ភ័យមកកាន់តថាគត ព្រោះឃើញនូវពពួកសត្វ កំពុងញាប់ញ័រ (ដោយតណ្ហាជាដើម) ដូចពួកមច្ឆជាតិក្នុងទីមានទឹកតិច និងព្រោះឃើញសត្វលោកបៀតបៀនគ្នានឹងគ្នា ។

សមន្តមសារោ លោកោ ទិសា សព្វា សមេរិតា
ឥច្ឆំ ភវនមត្តនោ នាទ្ទសាសឹ អនោសិតំ ។

លោកមិនមានខ្លឹមសារដោយជុំវិញ ទិសទាំងពួង រមែងញាប់ញ័រ តថាគត កាលប្រាថ្នានូវភព (ជាទីពឹង) របស់ខ្លួន ក៏មិនបានឃើញភពណាមួយដែលជរាធម៌ជាដើម ជិះជាន់មិនបាននោះឡើយ ។

ឱសានេ ត្វេវ ព្យារុទ្ធេ ទិស្វា មេ អរតី អហុ
អថេត្ថ សល្លមទ្ទក្ខឹ ទុទ្ទសំ ហទយនិស្សិតំ ។

សេចក្ដីមិនរីករាយ បានកើតមាន ដល់តថាគតហើយ ព្រោះបានឃើញសត្វទាំងឡាយត្រូវជរាធម៌ជាដើម បៀតបៀនហើយ ក្នុងកាលជាទីបំផុត តពីនោះមក តថាគតបានឃើញសរដែលគេឃើញបានដោយកម្រ អាស្រ័យនៅក្នុងហឫទ័យ នៃសត្វទាំងឡាយនោះ ។

យេន សល្លេន ឱតិណ្ណោ ទិសា សព្វា វិធាវតិ
តមេវ សល្លំ អព្វុយ្ហ ន ធាវតិ ន សីទតិ ។

សត្វលោកដែលសរដោតជាប់ហើយ រមែងស្ទុះទៅកាន់ទិសផ្សេងៗ បុគ្គលជាបណ្ឌិត ដកសរនោះបាន ទើបមិនស្ទុះទៅ មិនលិចចុះ ។



តត្ថ សិក្ខានុគីយន្តិ
(យានិ លោកេ គធិតានិ) ន តេសុ បសុតោ សិយា
និព្វិជ្ឈ សព្វសោ កាមេ សិក្ខេ និព្វានមត្តនោ ។

(អារម្មណ៍ជាទីស្រឡាញ់ គឺបញ្ចកាមគុណណា មានក្នុងលោក) ប្រជុំជន តែងសម្ដែងនូវភាសិតជាគ្រឿងសិក្សា (មានការសិក្សាដំរីជាដើម) ដើម្បីឱ្យបានអារម្មណ៍ជាទីស្រឡាញ់នោះ បណ្ឌិតមិនគួរខ្វល់ខ្វាយក្នុងបញ្ចកាមគុណ ឬក្នុងកិច្ចសិក្សានោះឡើយ គប្បីនឿយណាយ ក្នុងកាមារម្មណ៍ ដោយប្រការទាំងពួង គប្បីសិក្សានូវព្រះនិព្វាន បម្រុងខ្លួន ។

សច្ចោ សិយា អប្បគព្ភោ អមាយោ រិត្តបេសុណោ
អក្កោធនោ លោភបាបកំ វេវិច្ឆំ វិតរេ មុនិ ។

បុគ្គលជាអ្នកប្រាជ្ញ គប្បីជាអ្នកមានសច្ចៈ[១] ជាបុគ្គលមិនឃ្មើសឃ្មង មិនមានមាយា លះបង់ពាក្យញុះញង់ មិនក្រេវក្រោធ ឆ្លងរួចនូវលោភៈដ៏លាមក និងមច្ឆរិយៈ ។

១.សច្ចៈ ៣ យ៉ាងគឺ វចីសច្ចៈ ញាណសច្ចៈ មគ្គសច្ចៈ ។

និទ្ទំ តន្ទឹ សហេ ថីនំ　　បមាទេន ន សំវសេ
អតិមានេ ន តិដ្ឋេយ្យ　　និព្វានមនសោ នរោ ។

នរជនមានចិត្តឱនទៅរកព្រះនិព្វាន គប្បីគ្របសង្កត់នូវការដេកលក់ សេចក្ដីខ្ជិលច្រអូស ការរួញរា មិនគប្បីដំអក់នៅដោយសេចក្ដីប្រហែសធ្វេស និងមិនគប្បីតាំងខ្លួនក្នុងមានះដ៏ក្រៃលែង ។

មោសវជ្ជេ ន និយ្យេថ　　រូបេ ស្នេហំ ន កុព្វយេ
មានញ្ច បរិជានេយ្យ　　សាហសា វិរតោ ចរេ ។

(បុគ្គលអ្នកបង្អោនចិត្តទៅរកព្រះនិព្វាន )មិនគប្បីដឹកនាំក្នុងពាក្យមុសាវាទ មិនគប្បីធ្វើសេចក្ដីស្នេហាក្នុងរូប ត្រូវកំណត់ដឹងនូវមានះ ហើយគប្បីវៀរចេញចាកអំពើដ៏រួសរាន់ ។

បុរាណំ នាភិនន្ទេយ្យ　　នវេ ខន្តិមកុព្វយេ
ហិយ្យមានេ ន សោចេយ្យ អាកាសំ ន សិតោ សិយា ។

មិនគប្បីស្រើបស្រាលទៅរកបញ្ចក្ខន្ធ ដែលជារបស់ចាស់គឺជាអតីត មិនគប្បីធ្វើសេចក្ដីពេញចិត្តនឹងបញ្ចក្ខន្ធ ដែលជារបស់ថ្មីគឺជាបច្ចុប្បន្ន មិនត្រូវសោកស្ដាយនឹងបញ្ចក្ខន្ធ ដែលសាបរលាបទៅហើយ និងមិនត្រូវជាប់ស្អិតនៅក្នុងតណ្ហា ។





គេធំ ព្រូមិ មហោឃោតិ　　អាជវំ ព្រូមិ ជប្បនំ
អារម្មណំ បកប្បនំ　　កាមបង្កោ ទុរច្ចយោ ។

តថាគតពោលនូវសេចក្ដីជាប់ចិត្ត គឺតណ្ហាថា ជាអន្លង់ធំ តថាគតពោលនូវសេចក្ដីជក់ចិត្ត គឺតណ្ហា ថាជាគ្រឿងលឿនទៅនៃចិត្ត ថាជាគ្រឿងជាប់ញ៉ាមនៅនៃចិត្ត ថាជាអារម្មណ៍នៃចិត្ត ថាជាគ្រឿងត្រិះរិះ (ព្រោះ ) កាមតណ្ហាដូចជាភក់ សត្វទាំងឡាយ អាចឆ្លងបានដោយលំបាក ។

សច្ចា អវោក្កម្ម មុនិ　　ថលេ តិដ្ឋតិ ព្រាហ្មណោ
សព្វសោ បដិនិស្សជ្ជ　　ស វេ សន្តោតិ វុច្ចតិ ។

អ្នកប្រាជ្ញ ជាព្រាហ្មណ៍ មិនគេចចេញចាកសច្ចៈ រមែងតាំងនៅលើទីទួលគឺព្រះនិព្វាន តថាគតហៅបុគ្គលនោះថាជាអ្នកស្ងប់ ព្រោះលះអាយតនៈទាំងអស់ ។

សវេ វិទ្វា ស វេទគូ　　ញត្វា ធម្មំ អនិស្សិតោ
សម្មា សោ លោកេ ឥរិយានោ ន បិហេតីធ កស្សចិ ។

បុគ្គលនោះជាអ្នកប្រាជ្ញ បុគ្គលនោះ ជាអ្នកដល់នូវវេទ ជាបុគ្គលដែលតណ្ហានិងទិដ្ឋិមិនអាស្រ័យនៅហើយ ព្រោះឃើញ

សង្ខារធម៌ (ថាជារបស់មិនទៀង ជាទុក្ខ មិនមែនខ្លួន )បុគ្គលនោះ រមែងប្រព្រឹត្តទៅក្នុងលោកដោយប្រពៃ មិនជាប់ចិត្តនឹងបុគ្គលណាមួយឡើយ ។

**យោធ កាមេ អច្ចតរិ សង្គំ លោកេ ទុរច្ចយំ**
**ន សោ សោចតិ នាជ្ឈេតិ ឆិន្នសោតោ អពន្ធនោ ។**

បុគ្គលណា បានឆ្លងផុតនូវកាមផង នូវកិលេសគ្រឿងជាប់ដែលឆ្លងបានដោយកម្រ ក្នុងលោកផង បុគ្គលនោះ ឈ្មោះថាកាត់ខ្សែតណ្ហា មិនមានចំណង រមែងមិនសោក មិនសុបសៅ ។

**យំ បុព្វេ តំ វិសោសេហិ បច្ឆា តេ មាហុ កិញ្ចនំ**
**មជ្ឈេ ចេ នោ គហេស្សសិ ឧបសន្តោ ចរិស្សសិ ។**

កិលេសណាកើតឡើង (ព្រោះប្រារព្ធ ) សង្ខារជាអតីត អ្នកចូរធ្វើកិលេសនោះ ឱ្យរីងស្ងួតទៅ កិលេសគ្រឿងកង្វល់ (មានរាគៈជាដើមកើតឡើងព្រោះប្រារព្ធ ) សង្ខារដែលនឹងមានទៅខាងក្រោយ ចូរកុំមានដល់អ្នកឡើយ បើអ្នកមិនប្រកាន់ក្នុងធម៌ជាកណ្តាល (មានរូបជាដើមដែលជាបច្ចុប្បន្ន ) អ្នកនឹងទៅជាបុគ្គលស្ងប់ ។





**សព្វសោ នាមរូបស្មឹ យស្ស នត្ថិ មមាយិតំ**
**អសតា ច ន សោចតិ ស វេ លោកេ ន ជិយ្យតិ ។**

បុគ្គលណា មិនមានសេចក្តីប្រកាន់ ក្នុងនាមនិងរូប ថាជារបស់អញសព្វកន្លែងទេ បុគ្គលនោះឯង រមែងមិនសោក ព្រោះនាមរូបដែលមិនមានផង មិនទ្រុឌទ្រោមទៅក្នុងលោកផង ។

**យស្ស នត្ថិ ឥទំ មេតិ បរេសំ ចាបិ កិញ្ចនំ**
**មមត្តំ សោ អសំវិន្ទំ នត្ថិ មេតិ ន សោចតិ ។**

កង្វល់ថា នេះរបស់អញ នុ៎ះរបស់ជនដទៃ មិនមាន ដល់បុគ្គលណា បុគ្គលនោះ កាលមិនបាននូវវត្ថុដែលប្រកាន់ថា របស់អញ រមែងមិនសោកថា អញគ្មានដូច្នេះឡើយ ។

**អនុដ្ឋុរី អននុគិទ្ធោ អនេជោ សព្វធិ សមោ**
**តមានិសំសំ បព្រូមិ បុច្ឆិតោ អវិកម្បិនំ ។**

បុគ្គលដែលមិនមានឫស្យា មិនមានសេចក្តីត្រេកអរ ជាអ្នកមិនញាប់ញ័រ ជាអ្នកស្ងប់រម្ងាប់ ក្នុងអាយតនៈខាងក្នុង ខាងក្រៅទាំងអស់ តថាគត កាលបើមានបុគ្គលចូលមកសួរអានិសង្សរបស់បុគ្គលមិនញាប់ញ័រនោះ ក៏នឹងសម្តែង (អានិសង្សទាំង ៤ មានមិនឫស្យាជាដើមនោះ ) ។

**អនេជស្ស វិជានតោ        នត្ថិ កាចិ និសង្ខតិ**

**វិរតោ សោ វិយារម្ភា      ខេមំ បស្សតិ សព្វធិ ។**

(បណ្ដាសង្ខារទាំង ៣ មានបុញ្ញាភិសង្ខារជាដើម) សង្ខារណាមួយ មិនមានដល់បុគ្គលអ្នកមិនញាប់ញ័រ អ្នកដឹងច្បាស់ (នូវត្រៃលក្ខណ៍) បុគ្គលនោះវៀរស្រឡះចាកសង្ខារទាំង ៣ នោះ រមែងឃើញសេចក្ដីក្សេមក្នុងទីទាំងពួង ។

**ន សមេសុ ន ឱមេសុ    ន ឧស្សេសុ វទតេ មុនិ**

**សន្តោ សោ វិតមច្ឆរោ  នាទេតិ ន និរស្សតីតិ ភគវាតិ ។**

អ្នកប្រាជ្ញ រមែងមិននិយាយអួតខ្លួន (ដោយមានះថា អញជាបុគ្គលស្មើគ្នាជាដើម) ក្នុងពួកបុគ្គលដែលស្មើគ្នា (ថាអញជាបុគ្គលថោកទាបជាដើម) ក្នុងពួកបុគ្គលដែលថោកទាប (ថាអញជាបុគ្គលប្រសើរជាដើម) ក្នុងពួកបុគ្គលដែលប្រសើរ បុគ្គលនោះជាអ្នកស្ងប់ ប្រាសចាកសេចក្ដីកំណាញ់ រមែងមិនប្រកាន់ មិនអន្ទះសា ។





## ៩-អាឡវិកាសូត្រ

### បិដកលេខ ៣០ ទំព័រ ១

ខ្ញុំបានស្ដាប់មក យ៉ាងនេះ ។ សម័យមួយព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះ ភិក្ខុនីឈ្មោះអាឡវិកា ស្លៀកស្បង់ប្រដាប់ដោយបាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ចូលទៅកាន់ក្រុងសាវត្ថីដើម្បីបិណ្ឌបាត លុះត្រាច់ទៅបិណ្ឌបាត ក្នុងក្រុងសាវត្ថីហើយត្រឡប់មកអំពីបិណ្ឌបាតវិញ ក្នុងបច្ឆាភត្ត ក៏មានសេចក្ដីត្រូវការដោយទីស្ងាត់ ហើយចូលទៅកាន់អន្ធវ័ន ។

គ្រានោះ មារមានចិត្តបាប មានប្រាថ្នាដើម្បីញុំាងភ័យសេចក្ដីតក់ស្លុតនិងសេចក្ដីព្រឺរោម ឱ្យកើតឡើងដល់អាឡវិកាភិក្ខុនី មានប្រាថ្នាឱ្យនាងឃ្លាតចាកសេចក្ដីស្ងប់ស្ងាត់ ហើយក៏ចូលទៅរកអាឡវិកាភិក្ខុនី លុះចូលទៅដល់ហើយ បានពោលគាថានឹងអាឡវិកាភិក្ខុនីថា :

**នត្ថិ និស្សរណំ លោកេ     កឹ វិវេកេន កាហសិ**

**ភុញ្ជស្សុ កាមរតិយោ      មាហុ បច្ឆានុតាបិនីតិ ។**

ធម្មជាតជាគ្រឿងរលាស់ចេញ[១] ក្នុងលោក មិនមានទេ នាងនឹងធ្វើនូវប្រយោជន៍អ្វី ដោយសេចក្តីស្ងប់ស្ងាត់ ចូរនាងបរិភោគ នូវសេចក្តីត្រេកអរក្នុងកាម នាងពុំមានសេចក្តីក្តៅក្រហាយ ក្នុងកាលជាខាងក្រោយឡើយ ។

គ្រានោះ អាឡវិកាភិក្ខុនីមានសេចក្តីត្រិះរិះ យ៉ាងនេះថា អ្នកនេះជាអ្វីហ្ន៎ ជាមនុស្ស ឬជាអមនុស្ស បានជាពោលនូវគាថា ។ ទើបអាឡវិកាភិក្ខុនី មានសេចក្តីចូលចិត្តដូច្នេះថា នេះពិតជាមារ មានចិត្តបាប មានប្រាថ្នាដើម្បីញ៉ាំងភ័យ សេចក្តីតក់ស្លុត និងសេចក្តីព្រឺរោមឱ្យកើតឡើងដល់អាត្មាអញ ប្រាថ្នាឱ្យអាត្មាអញឃ្លាតចាកសេចក្តីស្ងប់ស្ងាត់ បានជាពោលនូវគាថា។ លុះអាឡវិកា-ភិក្ខុនីស្គាល់ច្បាស់ថា នេះជាមារ មានចិត្តបាប ដូច្នេះហើយ ក៏ពោលគាថាទាំងឡាយនឹងមារមានចិត្តបាបថា :

**អត្ថិ និស្សរណំ លោកេ  បញ្ញាយ មេ សុផុស្សិតំ**
**បមត្តពន្ធុ បាបិម  ន ត្វំ ជានាសិ តំ បទំ ។**

ធម្មជាតជាគ្រឿងរលាស់ចេញ ក្នុងលោក មាន យើងបានពាល់ត្រូវ ដោយបញ្ញា[២] ម្នាលមារមានចិត្តបាប មានផៅពង្សជាអ្នកប្រមាទ អ្នកមិនដឹងនូវបទនោះទេ ។

១.ព្រះនិព្វាន ។ ២.បច្ចវេក្ខណញ្ញាណ ។





**សត្តិសូលូបមា កាមា  ខន្ធាសំ អធិកុដ្ដនា**
**យំ ត្វំ កាមរតឹ ព្រូសិ  អរតិ មយ្ហ សា អហូតិ ។**

កាមទាំងឡាយ ឧបមាដោយលំពែងស្រួច ខន្ធទាំងឡាយជាកន្លែងសម្រាប់មុតនៃកាមទាំងឡាយនោះ អ្នកពោលនូវសេចក្តីត្រេកអរក្នុងកាមណា សេចក្តីត្រេកអរក្នុងកាមនោះ ជាសេចក្តីមិនត្រេកអររបស់ខ្ញុំទេ ។

លំដាប់នោះ មារមានចិត្តបាបដឹងថា អាឡវិកាភិក្ខុនីស្គាល់អញហើយ ក៏មានសេចក្តីទុក្ខ តូចចិត្ត បាត់អំពីទីនោះទៅ ។

## ចង់ឈ្នះចាញ់គ្នាបានប្រយោជន៍អ្វី

**ជយំ វេរំ បសវតិ  ទុក្ខំ សេតិ បរាជិតោ**
**ឧបសន្តោ សុខំ សេតិ  ហិត្វា ជយបរាជយំ ។**

អ្នកឈ្នះរមែងជួបប្រទះនូវពៀរ អ្នកចាញ់តែងដេកជាទុក្ខ អ្នកដែលស្ងប់រម្ងាប់លះបង់នូវការឈ្នះចាញ់បានហើយ រមែងនៅជាសុខគ្រប់ឥរិយាបថទាំង៤ ។

ព្រះអង្គទ្រង់គង់ប្រថាប់នៅជេតវនារាម
ទ្រង់ប្រារព្ធបរាជ័យរបស់ព្រះបាទកោសល

## ១០-ចាលាសូត្រ

### បិដកលេខ ៣០ ទំព័រ ១២

សាវត្ថីនិទាន ។ គ្រានោះ ចាលាភិក្ខុនី ស្លៀកដណ្តប់ក្នុងបុព្វណ្ហសម័យ ។បេ។ អង្គុយសម្រាកក្នុងវេលាថ្ងៃ ក្រោមម្លប់ឈើមួយ ។

គ្រានោះមារមានចិត្តបាប ចូលទៅរកចាលាភិក្ខុនី ។បេ។ លុះចូលទៅដល់ហើយ បានពោលពាក្យនេះនឹងចាលាភិក្ខុនី ថា ម្នាលភិក្ខុនី នាងមិនគាប់ចិត្តនឹងអ្វី ។ ម្នាលអាវុសោ យើងមិនគាប់ចិត្តនឹងជាតិ ។

**កឹំ នុ ខោ ជាតឹំ ន រោចេសិ**
**ជាតោ កាមានិ ភុញ្ជតិ**
**កោ នុ តំ ឥទមាទបយិ**
**ជាតិ មា រោច ភិក្ខុនីតិ ៕**

ហេតុអ្វីក៏នាងមិនគាប់ចិត្តនឹងជាតិ បុគ្គលមានជាតិ រមែងបរិភោគនូវកាមទាំងឡាយ អ្នកណាបង្គាប់នាងឱ្យប្រកាន់យកនូវ





អំពើនេះថា ម្នាលភិក្ខុនី ចូរនាងកុំគាប់ចិត្តនឹងជាតិដូច្នេះ ។

**ជាតស្ស មរណំ ហោតិ　ជាតោ ទុក្ខានិ ផស្សតិ**
**ពន្ធំ វធំ បរិក្លេសំ　តស្មា ជាតឹំ ន រោចយេ ៕**

ចាលាភិក្ខុនីតបថា សត្វកើតហើយ រមែងមានមរណៈ សត្វកើតហើយ រមែងឃើញនូវទុក្ខទាំងឡាយ គឺការចង ការបៀតបៀន និងសេចក្តីឧបទ្រពផ្សេងៗ ហេតុដូច្នោះ បុគ្គលមិនត្រូវគាប់ចិត្តនឹងការកើតឡើយ ។

**ពុទ្ធោ ធម្មមទេសេសិ　ជាតិយា សមតិក្កមំ**
**សព្វទុក្ខប្បហានាយ　សោ មំ សច្ចេ និវេសយិ ៕**

ព្រះពុទ្ធទ្រង់សម្តែងធម៌ ជាគ្រឿងប្រព្រឹត្តកន្លងនូវការកើត ដើម្បីលះបង់នូវទុក្ខទាំងអស់ ព្រះអង្គញ៉ាំងយើងឱ្យនៅក្នុងសច្ចធម៌ ។

**យេ ច រូបូបគា សត្តា　យេ ច អរូបភាគិនោ**
**និរោធំ អប្បជានន្តា　អាគន្តារោ បុនព្ភវន្តិ ៕**

សត្វទាំងឡាយណា កើតក្នុងរូបភពក្តី សត្វទាំងឡាយណា មានចំណែកក្នុងអរូបភពក្តី សត្វទាំងអស់នោះ កាលបើមិនដឹងនូវនិរោធទេ រមែងមកកាន់ភពថ្មីទៀត ។

លំដាប់នោះ មារមានចិត្តបាបដឹងថា ចាលាភិក្ខុនីស្គាល់អញហើយ ក៏មានសេចក្តីទុក្ខ តូចចិត្ត បាត់អំពីទីនោះទៅ ។

### សារថីហាមសេចក្តីក្រោធ

**យោ វេ ឧប្បតិតំ កោធំ រថំ ភន្តំវ ធារយេ**
**តមហំ សារថឹ ព្រូមិ រស្មិគ្គាហោ ឥតរោ ជនោ។**

នរជនណាហាមនូវសេចក្តីក្រោធដែលកើតឡើងហើយ ដូចជានាយសារថីបញ្ឈប់រថដែលកំពុងតែឆ្ពោះទៅមុខបាន តថាគតហៅនរជននោះថាជាសារថី ជនក្រៅអំពីនេះ គ្រាន់តែជាអ្នកកាន់ខ្សែបង្ហៀរប៉ុណ្ណោះឯង ។

ព្រះអង្គទ្រង់គង់ប្រថាប់នៅអគ្គាឡវចេតិយ
ទ្រង់ប្រារព្ធភិក្ខុមួយអង្គដែលធ្វើឱ្យដាច់ដៃកូនទេវតា



## ១១-វជិរាសូត្រ
### បិដកលេខ ៣០ ទំព័រ ២០

ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយព្រះមានព្រះភាគទ្រង់គង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះ វជិរាភិក្ខុនី ស្លៀកស្បង់ប្រដាប់បាត្រចីវរ ក្នុងបុព្វណ្ហសម័យ ចូលទៅកាន់ក្រុងសាវត្ថីដើម្បីបិណ្ឌបាត លុះត្រាច់ទៅបិណ្ឌបាតក្នុងក្រុងសាវត្ថីហើយ ត្រឡប់មកអំពីបិណ្ឌបាតវិញក្នុងបច្ឆាភត្ត ក៏ដើរទៅកាន់អន្ធវ័ន ដើម្បីសម្រាកក្នុងវេលាថ្ងៃ លុះចូលទៅដល់អន្ធវ័នហើយ ក៏អង្គុយសម្រាកក្នុងវេលាថ្ងៃ ក្រោមម្លប់ឈើមួយ ។

គ្រានោះ មារមានចិត្តបាប មានប្រាថ្នាញាំងភ័យ សេចក្តីតក់ស្លុត និងសេចក្តីព្រឺរោម ឱ្យកើតឡើងដល់វជិរាភិក្ខុនី មានប្រាថ្នាឱ្យនាងឃ្លាតចាកសមាធិ ក៏ចូលទៅរកវជិរាភិក្ខុនី លុះចូលទៅដល់ហើយ បានពោលគាថានឹងវជិរាភិក្ខុនីថា :

**កេនាយំ បកតោ សត្តោ   ក្វចិ សត្តស្ស ការកោ**
**ក្វចិ សត្តោ សមុប្បន្នោ   ក្វចិ សត្តោ និរុជ្ឈតីតិ ៕**

សត្វនេះ បុគ្គលណាតាក់តែងឡើង បុគ្គលអ្នកតាក់តែងសត្វឋិតនៅក្នុងទីណា សត្វកើតឡើង ក្នុងទីណា សត្វរលត់ទៅក្នុងទីណា ។

លំដាប់នោះ វជិរាភិក្ខុនីមានសេចក្តីត្រិះរិះ យ៉ាងនេះថា អ្នកនេះជាអ្វីហ្ន៎ ជាមនុស្ស ឬជាអមនុស្ស (មក ) ពោលគាថាដូច្នេះ ។ ទើបវជិរាភិក្ខុនីមានសេចក្តីចូលចិត្តថា នេះពិតជាមារមានចិត្តបាប ប្រាថ្នាញុំាងភ័យ សេចក្តីតក់ស្លុតនិងសេចក្តីព្រឺរោមឱ្យកើតឡើងដល់អាត្មាអញ មានប្រាថ្នាឱ្យអាត្មាអញឃ្លាតចាកសមាធិ បានជាពោលគាថា ។ លំដាប់នោះ វជិរាភិក្ខុនីដឹងច្បាស់ថា នេះជាមារមានចិត្តបាប ហើយបានពោលគាថាទាំងឡាយនឹងមារមានចិត្តបាបថា :

**កឹំ នុ សត្តោតិ បច្ចេតិ   មារ ទិដ្ឋិគតំ នុ តេ**
**សុទ្ធសង្ខារបុញ្ជោយំ   នយិធ សត្តូបលព្ភតិ ៕**

ម្នាលមារ ទិដ្ឋិរបស់អ្នកយល់ថា សត្វមែនឬ នេះជាគំនរនៃសង្ខារសុទ្ធទេ ក្នុងគំនរនៃសង្ខារសុទ្ធនេះ អ្នករកសត្វមិនឃើញឡើយ [១] ។

**យថា ហិ អង្គសម្ភារា   ហោតិ សទ្ទោ រថោ ឥតិ**
**ឯវំ ខន្ធេសុ សន្តេសុ   ហោតិ សត្តោតិ សម្មុតិ ៕**

ដូចសព្ទដែលបានឈ្មោះថា រថដូច្នេះកើតឡើងបាន ព្រោះបរិបូណ៌ដោយអង្គ [២] យ៉ាងណាមិញ កាលបើខន្ធមានហើយ ការសន្មតថា សត្វដូច្នេះក៏មាន យ៉ាងនោះឯង ។

**ទុក្ខមេវ ហិ សម្ភោតិ   ទុក្ខំ តិដ្ឋតិ វេតិ ច**
**នាញ្ញត្រ ទុក្ខា សម្ភោតិ   នាញ្ញត្រ ទុក្ខា និរុជ្ឈតីតិ ៕**

ព្រោះថាសេចក្តីទុក្ខ រមែងកើតឡើង សេចក្តីទុក្ខ រមែងឋិតនៅផង វិនាសទៅផង វៀរចាកសេចក្តីទុក្ខ ឥតមានធម៌ដទៃកើតឡើង វៀរចាកសេចក្តីទុក្ខ ឥតមានធម៌ដទៃរលត់ទេ ។

លំដាប់នោះ មារមានចិត្តបាបដឹងថា វជិរាភិក្ខុនីស្គាល់អញហើយ ក៏មានសេចក្តីទុក្ខ តូចចិត្ត បាត់អំពីទីនោះទៅ ។

---
១_នេះជាពាក្យបរិយាយតាមបរមត្ថ ។ ២_អង្គរបស់រថនោះមានកង់ ទូក ប្រែកជាដើម។

## ១២-អាយាចនសូត្រ

### បិដកលេខ ៣០ ទំព័រ ២៤

ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់ទើបនឹងបានត្រាស់ដឹងជាដំបូង ទ្រង់គង់នៅក្រោមដើមអជ-បាលនិគ្រោធ ប្របឆ្នេរស្ទឹងនេរញ្ជរា ក្នុងឧរុវេលាប្រទេស ។ គ្រានោះឯង ព្រះមានព្រះភាគទ្រង់ស្តេចទៅគង់ក្នុងទីស្ងាត់សម្ងំនៅ មានព្រះទ័យត្រិះរិះកើតឡើង យ៉ាងនេះថា ធម៌[១] នេះអាត្មាអញបានត្រាស់ដឹងហើយ ជាធម៌ដ៏ជ្រាលជ្រៅ ជាធម៌ដែលសត្វឃើញបានដោយកម្រ ជាធម៌ដែលសត្វត្រាស់ដឹងបានដោយកម្រ ជាធម៌ស្ងប់រម្ងាប់ ជាធម៌ថ្លៃថ្លា ជាធម៌ដែលសត្វមិនគប្បីស្ទង់មើល ដោយសេចក្តីត្រិះរិះបាន ជាធម៌ដ៏ល្អិត ជាធម៌មានតែអ្នកប្រាជ្ញ ទើបត្រាស់ដឹងបាន ឯពួកសត្វនេះ ជាអ្នកត្រេកត្រអាលដោយសេចក្តីអាល័យ[២] ត្រេកអរក្នុងសេចក្តីអាល័យ រីករាយក្នុងសេចក្តីអាល័យ មួយទៀត បដិច្ចសមុប្បាទធម៌ គឺធម៌ជាបច្ច័យនៃគ្នានិងគ្នាណា បដិច្ចសមុប្បាទធម៌នេះ ពួកសត្វជាអ្នកត្រេកត្រអាលដោយសេចក្តី

១-សំដៅយកអរិយសច្ចទាំង ៤ ។ ២-បានដល់តណ្ហាវិចរិតទាំង ១០៨ ។





អាល័យ ត្រេកអរក្នុងសេចក្តីអាល័យ រីករាយក្នុងសេចក្តីអាល័យ ឃើញបានដោយក្រ មួយទៀត ធម៌ណា សម្រាប់រម្ងាប់សង្ខារទាំងពួង សម្រាប់លះបង់ឧបធិទាំងពួង ជាទីអស់ទៅនៃតណ្ហា ជាទីនឿយណាយចាករាគៈ ជាទីរំលត់សេចក្តីទុក្ខ គឺព្រះនិព្វាន ធម៌នេះ ពួកសត្វឃើញបានដោយក្រដូចគ្នា ប្រសិនបើអាត្មាអញសម្តែងធម៌ទៅ ក៏សត្វទាំងឡាយដទៃ មិនគប្បីត្រាស់ដឹងធម៌របស់អាត្មាអញបានទេ អាត្មាអញនឹងមានតែសេចក្តីលំបាកនោះ អាត្មាអញ នឹងមានតែសេចក្តីនឿយព្រួយនោះ (ឥតអំពើ ) ។ បានឮថា ព្រះគាថាជាអស្ចារ្យទាំងឡាយនេះ ដែលមិនធ្លាប់បានស្តាប់មកអំពីកាលមុន ក៏ប្រាកដដល់ព្រះមានព្រះភាគថា :

**កិច្ឆេន មេ អធិគតំ ហលន្ទានិ បកាសិតុំ**
**រាគទោសបរេតេហិ នាយំ ធម្មោ សុសម្ពុធោ ។**

ឥឡូវនេះ អាត្មាអញ មិនគួរប្រកាសធម៌ ដែលអាត្មាអញបានត្រាស់ដឹងហើយ ដោយលំបាកទេ ព្រោះថា ធម៌នេះ សត្វទាំងឡាយដែលត្រូវរាគៈ ទោសៈ គ្របសង្កត់ហើយ មិនងាយត្រាស់ដឹងបានឡើយ ។

**បដិសោតគាមឹ និបុណំ គម្ភីរំ ទុទ្ទសំ អណុំ**
**រាគរតា ន ទក្ខន្តិ តមោខន្ធេន អាវុតាតិ ។**

សត្វទាំងឡាយត្រេកអរ ដោយរាគៈ មានគំនរងងឹត គឺអវិជ្ជាបិទបាំង រមែងមិនឃើញនូវធម៌ដែលប្រព្រឹត្តច្រាសខ្សែទឹក[១] ជាធម៌ល្អិត ជ្រាលជ្រៅ សត្វឃើញបានដោយកម្រ ជាធម៌ដ៏តូចឆ្មារ ។

កាលព្រះមានព្រះភាគ ពិចារណាដូច្នេះហើយ ព្រះទ័យក៏បង្អោនទៅដើម្បីសេចក្តីខ្វល់ខ្វាយតិច មិនបង្អោនទៅដើម្បីនឹងសម្តែងធម៌ឡើយ ។

គ្រានោះ សហម្បតិព្រហ្ម ដឹងនូវសេចក្តីត្រិះរិះក្នុងព្រះហឫទ័យរបស់ព្រះមានព្រះភាគ ដោយចិត្តហើយ ទើបរំពឹងគិតដូច្នេះថា ឱហ្ន៎ សត្វលោកសាបសូន្យមិនខាន ឱហ្ន៎ សត្វលោកវិនាសមិនខាន ដ្បិតថាព្រះហឫទ័យរបស់ព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ បង្អោនទៅដើម្បីសេចក្តីខ្វល់ខ្វាយតិច មិនបង្អោនទៅដើម្បីសម្តែងធម៌ឡើយ ។

គ្រានោះ សហម្បតិព្រហ្ម ក៏បាត់អំពីព្រហ្មលោកមកប្រាកដក្នុងទីចំពោះព្រះភក្ត្រព្រះមានព្រះភាគ ដោយឆាប់រហ័ស ដូចបុរស

១.បានដល់ចតុសច្ចធម៌ ។





មានកម្លាំងលាចេញនូវដៃដែលបត់ចូល ឬបត់ចូលនូវដៃដែលលាចេញ ។ លំដាប់នោះ សហម្បតិព្រហ្ម ធ្វើនូវសំពត់ឧត្តរាសង្គៈ ឆៀងស្មាម្ខាង លុតចុះនូវមណ្ឌល នៃជង្គង់ខាងស្តាំ លើផែនដី ប្រណម្យអញ្ជលី ចំពោះទៅរកព្រះមានព្រះភាគ ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់សម្តែងធម៌ សូមព្រះសុគតទ្រង់សម្តែងធម៌ សត្វទាំងឡាយ ដែលមានធូលី[១] ស្រាលស្តើងក្នុងភ្នែក[២] ក៏មានខ្លះដែរ សត្វទាំងនោះ នឹងសាបសូន្យ ព្រោះមិនបានស្តាប់ធម៌ សត្វទាំងឡាយជាអ្នកត្រាស់ដឹងនូវធម៌គង់មាន ។ សហម្បតិព្រហ្ម បានពោលពាក្យនេះ លុះពោលពាក្យនេះរួចហើយ ទើបពោលពាក្យនេះតទៅទៀតថា

**បាតុរហោសិ មគធេសុ បុព្វេ**
**ធម្មោ អសុទ្ធោ សមលេហិ ចិន្តិតោ**
**អបាបុរេតំ អមតស្ស ទ្វារំ**
**សុណន្តុ ធម្មំ វិមលេនានុពុទ្ធំ ។**

ពីមុនរៀងមក ធម៌ដែលជនទាំងឡាយ អ្នកប្រកបដោយមន្ទិល[៣] តែងគិត ជាធម៌មិនបរិសុទ្ធ កើតប្រាកដក្នុងដែនមគធៈ

១.បានខាងកិលេសមានរាគៈជាដើម ។ ២.បានខាងបញ្ញាចក្ខុ ។ ៣.សំដៅយកគ្រូទាំង ៦

សូមព្រះអង្គបើកនូវទ្វារ [១] នៃព្រះនិព្វាន សត្វទាំងឡាយនឹងស្តាប់នូវធម៌ដែលព្រះពុទ្ធជាអ្នកប្រាសចាកមន្ទិលទ្រង់ត្រាស់ដឹងហើយ ។

**សេលេ យថា បព្វតមុទ្ធនិដ្ឋិតោ**
**យថាបិ បស្សេ ជនតំ សមន្តតោ**
**តថូបមំ ធម្មមយំ សុមេធសោ**
**បាសាទមារុយ្ហ សមន្តចក្ខុ**
**សោកាវតិណ្ណំ ជនតមបេតសោកោ**
**អវេក្ខស្សុ ជាតិជរាភិភូតន្តិ ។**

បុរសឈរនៅលើកំពូលភ្នំសុទ្ធសឹងថ្ម គប្បីឃើញប្រជុំជនដោយជុំវិញ យ៉ាងណាមិញ បពិត្រព្រះអង្គមានបញ្ញាល្អ មានចក្ខុជុំវិញ ប្រាសចាកសេចក្តីសោក សូមព្រះអង្គឡើងកាន់ប្រាសាទដែលសម្រេចដោយធម៌ គឺបញ្ញាដូចជាភ្នំនោះ ហើយពិចារណាមើលនូវប្រជុំជន ដែលលិចចុះក្នុងសេចក្តីសោក ត្រូវជាតិ ជរាគ្របសង្កត់ ។

**ឧដ្ឋេហិ វីរ វិជិតសង្គាម**
**សត្ថវាហ អនណ វិចរ លោកេ**

១-បានខាងអរិយមគ្គ ។





**ទេសេតុ ភគវា ធម្មំ**
**អញ្ញាតារោ ភវិស្សន្តីតិ ។**

បពិត្រព្រះអង្គមានព្យាយាម ទ្រង់ឈ្នះនូវសង្គ្រាម សូមព្រះអង្គក្រោកឡើង បពិត្រព្រះអង្គ ជាអ្នកនាំទៅនូវពពួកសត្វ ព្រះអង្គមិនមានបំណុល សូមទ្រង់ស្តេចទៅក្នុងលោក សូមព្រះមានព្រះភាគ ទ្រង់សម្តែងធម៌ សត្វទាំងឡាយជាអ្នកត្រាស់ដឹងគង់នឹងមាន ។

គ្រានោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវសេចក្តីអារាធនារបស់ព្រហ្មផង ទ្រង់អាស្រ័យនូវសេចក្តីករុណាចំពោះសត្វទាំងឡាយផង ទើបទ្រង់រមិលមើលនូវសត្វលោក ដោយពុទ្ធចក្ខុ ។ កាលដែលព្រះមានព្រះភាគ ទ្រង់រមិលមើលនូវសត្វលោក ដោយពុទ្ធចក្ខុ ទ្រង់បានឃើញសត្វទាំងឡាយ មានភ្នែកប្រកបដោយធូលីតិចខ្លះ មានភ្នែកប្រកបដោយធូលីច្រើនខ្លះ មានឥន្ទ្រិយក្លាខ្លះ មានឥន្ទ្រិយទន់ខ្លះ មានអាការល្អខ្លះ មានអាការអាក្រក់ខ្លះ ជាសត្វដែលឱ្យត្រាស់ដឹងបានដោយងាយខ្លះ ជាសត្វដែលឱ្យត្រាស់ដឹងបានដោយក្រខ្លះ ជាអ្នកឃើញនូវទោសនិងភ័យក្នុងបរលោកខ្លះ ។ ប្រៀបដូចជលជាតិពួកខ្លះ គឺផ្កាព្រលិតក្តី ឈូក

ក្រហមក្តី ឈូកសក្តី ក្នុងគុម្ពព្រលិតក្តី គុម្ពឈូកក្រហមក្តី គុម្ពឈូកសក្តី ដុះឡើងក្នុងទឹក ចម្រើនឡើងក្នុងទឹក លូតលាស់តាមទឹក លិចនៅក្នុងទឹក មានជលជាតិពួកខ្លះ គឺផ្កាព្រលិតក្តី ឈូកក្រហមក្តី ឈូកសក្តី ដុះឡើងក្នុងទឹក ចម្រើនឡើងក្នុងទឹក ឋិតនៅត្រឹមស្មើនឹងទឹក មានជលជាតិពួកខ្លះ គឺផ្កាព្រលិតក្តី ឈូកក្រហមក្តី ឈូកសក្តី ដុះឡើងក្នុងទឹក ចម្រើនឡើងក្នុងទឹក លូតផុតអំពីទឹក មិនទទឹកដោយទឹក មានឧបមាយ៉ាងណាមិញ កាលដែលព្រះមានព្រះភាគ ទ្រង់រមិលមើលនូវសត្វលោក ដោយពុទ្ធចក្ខុ ទ្រង់ឃើញសត្វទាំងឡាយ មានភ្នែកប្រកបដោយធូលីតិចខ្លះ មានភ្នែកប្រកបដោយធូលីច្រើនខ្លះ មានឥន្រ្ទិយក្លាខ្លះ មានឥន្រ្ទិយទន់ខ្លះ មានអាការល្អខ្លះ មានអាការអាក្រក់ខ្លះ ជាសត្វដែលឱ្យត្រាស់ដឹងបានដោយងាយខ្លះ ជាសត្វដែលឱ្យត្រាស់ដឹងបានដោយក្រខ្លះ ជាអ្នកឃើញនូវទោសនិងភ័យ ក្នុងបរលោកខ្លះ លុះទ្រង់ឃើញហើយ បានពោលគាថា តបនឹងសហម្បតិព្រហ្មថា

**អបារុតា តេ អមតស្ស ទ្វារា**

**យេ សោតវន្តោ បមុញ្ចន្តុ សទ្ធំ ។**

ទ្វារនៃព្រះនិព្វាននោះតថាគតបានបើកហើយ សត្វទាំង-ឡាយណា មានសោតប្បសាទ ចូរបញ្ចេញនូវសទ្ធាចុះ ។



**វិហឹសសញ្ញី បគុណំ ន ភាសឹ**

**ធម្មំ បណីតំ មនុជេសុ ព្រហ្មេតិ ។**

ម្នាលព្រហ្ម តថាគតសំគាល់នូវសេចក្តីលំបាក បានជាមិនសម្តែងធម៌ដែលស្ទាត់ ជាធម៌ដ៏ឧត្តម ដល់ពួកមនុស្សទាំងឡាយ ។

គ្រានោះ សហម្បតិព្រហ្មគិតថា អាត្មាអញជាបុគ្គលដែលព្រះមានព្រះភាគ ទ្រង់ធ្វើឱកាសដើម្បីនឹងសម្តែងធម៌ហើយ (លុះគិតដូច្នេះហើយ ) ក៏ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយបាត់អំពីទីនោះទៅ ។

## គុណធម៌ដែលនាំមកនូវសេចក្តីសុខ

**សុខំ យាវ ជរា សីលំ សុខា សទ្ធា បតិដ្ឋិតា**

**សុខោ បញ្ញាបដិលាភោ បាបានំ អករណំ សុខំ។**

សីលនាំសេចក្តីសុខមកឱ្យដរាបដល់ចាស់ជរា សទ្ធាដែលតម្កល់ខ្ជាប់ខ្ជួនហើយនាំសេចក្តីសុខមកឱ្យ ការសម្រេចបាននូវបញ្ញា នាំសេចក្តីសុខមកឱ្យ ការមិនធ្វើនូវបាបទាំងពួង នាំសេចក្តីសុខមកឱ្យ ។

ព្រះអង្គទ្រង់គង់ប្រថាប់នៅព្រះគន្ធកុដិនាព្រៃហិមពាន្ត
ទ្រង់ប្រារព្ធមារាធិរាជដែលមកអារាធនាព្រះអង្គឱ្យគ្រប់គ្រង
រាជសម្បត្តិប្រកបដោយធមិ

# ១៣-ធនញ្ជានីសូត្រ
## បិដកលេខ ៣០ ទំព័រ ៨៣

ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ សម័យនោះឯង នាងព្រាហ្មណី ឈ្មោះធនញ្ជានី (ជាភរិយា) នៃព្រាហ្មណ៍ម្នាក់ ជាភារទ្វាជគោត្រ នាងជ្រះថ្លាក្រៃពេកក្នុងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ។

លំដាប់នោះឯង នាងធនញ្ជានីព្រាហ្មណី កំពុងចាត់ចែងភត្ត ដើម្បីព្រាហ្មណ៍ភារទ្វាជគោត្រ ក៏ភ្លាត់បន្លឺនូវឧទានបីដងថា សូមថ្វាយបង្គំព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ សូមថ្វាយបង្គំព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ អង្គនោះ ។ កាលបើនាងព្រាហ្មណីពោលយ៉ាងនេះហើយ ព្រាហ្មណ៍ភារទ្វាជគោត្រនិយាយនឹងនាងធនញ្ជានីព្រាហ្មណីយ៉ាងនេះថា មេចង្រៃនេះធ្លាប់តែអ៊ីចឹង ៗ ហ៊ានពោលសរសើរសមណៈត្រងោល ក្នុងទីផ្តេសផ្តាស នៃមេចង្រៃ អញនឹងលើកនូវវាទៈ[1] ចំពោះគ្រូរបស់

១-អញនឹងលើកនូវវាទៈ បានសេចក្តីថា អញនឹងសួរដេញដោល ។





ហងឯងនោះ ក្នុងកាលឥឡូវនេះ ។

ធនញ្ជានីពោលថាៈម្នាលព្រាហ្មណ៍ ក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក មនុស្សលោក ក្នុងពពួកសត្វព្រមទាំងសមណព្រាហ្មណ៍ និងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ខ្ញុំមិនដែលឃើញអ្នកណា អាចលើកនូវវាទៈចំពោះព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធនោះបានទេ ម្នាលព្រាហ្មណ៍ តែថា អ្នកចូរទៅចុះ លុះទៅហើយ គង់តែនឹងដឹងទេ ។

គ្រានោះឯង ព្រាហ្មណ៍ភារទ្វាជគោត្រខឹងអន់ចិត្ត ចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ធ្វើសេចក្តីរីករាយជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយនៅក្នុងទីសមគួរ ។ លុះព្រាហ្មណ៍ភារទ្វាជគោត្រ អង្គុយក្នុងទីសមគួរហើយ បានពោលនឹងព្រះមានព្រះភាគ ដោយគាថា ថា :

**កឹស្សុ ឆេត្វា សុខំ សេតិ កឹស្សុ ឆេត្វា ន សោចតិ**
**កិស្សស្ស ឯកធម្មស្ស វធំ រោចេសិ គោតមាតិ ។**

បុគ្គលកាត់បង់នូវអ្វី ទើបដេកជាសុខ បុគ្គលកាត់បង់នូវអ្វីទើបមិនសោកសៅ បពិត្រព្រះគោតម ព្រះអង្គពេញព្រះហឫទ័យនឹងសម្លាប់ធម៌ណា ដែលជាធម៌ឯក ។

ព្រះមានព្រះភាគទ្រង់ត្រាស់តបថា :

**កោធំ ឆេត្វា សុខំ សេតិ  កោធំ ឆេត្វា ន សោចតិ**
**កោធស្ស វិសមូលស្ស  មធុរគ្គស្ស ព្រាហ្មណ**
**វធំ អរិយា បសំសន្តិ  តញ្ហិ ឆេត្វា ន សោចតីតិ ។**

បុគ្គលកាត់បង់នូវសេចក្តីក្រោធ ទើបដេកជាសុខ បុគ្គលកាត់បង់នូវសេចក្តីក្រោធ ទើបមិនសោកសៅ ម្នាលព្រាហ្មណ៍ ពួកព្រះអរិយៈ តែងសរសើរនូវការសម្លាប់សេចក្តីក្រោធ ដែលមានឫសជាពិស មានចុងដ៏ផ្អែម ព្រោះថា បុគ្គលកាត់បង់នូវសេចក្តីក្រោធនោះបានហើយ ទើបមិនសោកសៅ ។

កាលដែល ព្រះមានព្រះភាគ ត្រាស់យ៉ាងនេះហើយ ព្រាហ្មណ៍ភារទ្វាជគោត្រ បានទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ណាស់ បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ណាស់ បពិត្រព្រះគោតមដ៏ចម្រើន ដូចជាបុគ្គលផ្ងារ នូវរបស់ដែលផ្កាប់ បើកបង្ហាញ នូវរបស់ដែលកំបាំង ឬចង្អុលបង្ហាញផ្លូវដល់មនុស្សវង្វេង ឬទ្រោលប្រទីបក្នុងទីងងឹត ដោយគិតថា ពួកមនុស្សមានចក្ខុ នឹងឃើញរូបទាំងឡាយបាន ធម៌ដែលព្រះគោតមដ៏ចម្រើនប្រកាសហើយ ដោយអនេកបរិយាយ ក៏យ៉ាង





នោះដែរ ខ្ញុំព្រះអង្គនេះ សូមដល់នូវព្រះគោតមដ៏ចម្រើនផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹងទីរឭក ខ្ញុំព្រះអង្គសូមបាននូវបព្វជ្ជា សូមបាននូវឧបសម្បទា ក្នុងសំណាក់ព្រះគោតមដ៏ចម្រើន។ ព្រាហ្មណ៍ភារទ្វាជគោត្រ ក៏បានបព្វជ្ជា និងឧបសម្បទាក្នុងសំណាក់ព្រះមានព្រះភាគ ។ លុះភារទ្វាជៈមានអាយុ បានឧបសម្បទាមិនយូរប៉ុន្មាន ចៀសចេញទៅតែម្នាក់ឯង ជាអ្នកមិនប្រមាទ មានព្យាយាមដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន កុលបុត្រទាំងឡាយ ចេញចាកផ្ទះ ចូលទៅកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា (ព្រះភារទ្វាជៈនោះ ) ក៏បានធ្វើឱ្យជាក់ច្បាស់ បានសម្រេច ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯងក្នុងបច្ចុប្បន្ន នូវអនុត្តរធម៌នោះ ដែលជាទីបំផុតនៃព្រហ្មចរិយៈ ហើយដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយៈបាននៅរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើរួចហើយ មគ្គ-ភាវនាកិច្ចដទៃ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ បណ្តាព្រះអរហន្តទាំងឡាយ ព្រះភារទ្វាជៈមានអាយុ ក៏ជាព្រះអរហន្តមួយអង្គដែរ ។

# ១៤-អក្កោសកសូត្រ
## បិដកលេខ ៣០ ទំព័រ ៨៧

សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ ព្រាហ្មណ៍ឈ្មោះ អក្កោសកភារទ្វាជៈ បានឮដំណឹងថា ព្រាហ្មណ៍ភារទ្វាជគោត្រ ចេញចាកផ្ទះចូលទៅកាន់ផ្នួស ក្នុងសំណាក់ព្រះសមណគោតម ក៏ខឹង អន់ចិត្ត ចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ បានជេរគំរាមព្រះមានព្រះភាគដោយវាចាជាអសប្បុរស អាក្រក់។

កាលបើអក្កោសកភារទ្វាជៈ ពោលយ៉ាងនេះហើយ ព្រះមានព្រះភាគ បានត្រាស់នឹងអក្កោសកភារទ្វាជព្រាហ្មណ៍យ៉ាងនេះថា ម្នាលព្រាហ្មណ៍អ្នកសំគាល់ហេតុនោះដូចម្តេច ពួកមិត្តអាមាត្យ ញាតិសាលោហិត ជាភ្ញៀវ ធ្លាប់មករកអ្នកដែរឬ ។ បពិត្រព្រះគោតមដ៏ចម្រើន ជួនកាលពួកមិត្តអាមាត្យ ញាតិសាលោហិត ជាភ្ញៀវធ្លាប់មករកខ្ញុំម្តងៗ ដែរ ។ ម្នាលព្រាហ្មណ៍ អ្នកសំគាល់សេចក្តីនោះដូចម្តេច អ្នកបានរៀបខាទនីយភោជនីយាហារ និង



សាយនីយាហារ ទទួលភ្ញៀវទាំងនោះដែរឬ ។ បពិត្រព្រះគោតមដ៏ចម្រើន ជួនកាលខ្ញុំបានរៀបខាទនីយភោជនីយាហារ និង សាយនីយាហារ ទទួលពួកភ្ញៀវទាំងនោះដែរ ។ ម្នាលព្រាហ្មណ៍ ប្រសិនបើពួកភ្ញៀវទាំងនោះ មិនទទួលយកទេ តើវត្ថុនោះបានទៅអ្នកណាវិញ ។ បពិត្រព្រះគោតមដ៏ចម្រើន ប្រសិនបើពួកភ្ញៀវទាំងនោះ មិនទទួលយកទេ វត្ថុនោះត្រូវបានមកខ្ញុំវិញ ។ ម្នាលព្រាហ្មណ៍ ការជេរទុំះក៏យ៉ាងនោះដែរ អ្នកឯងជេរតថាគត ដែលជាអ្នកមិនជេរ ខឹងតថាគត ដែលជាអ្នកមិនខឹង ប្រកួតប្រកាន់នឹងតថាគត ដែលជាអ្នកមិនប្រកួតប្រកាន់ តថាគត មិនទទួលការប្រទូស្តរបស់អ្នកនោះទេ ម្នាលព្រាហ្មណ៍ ការជេរទុំះត្រូវបានទៅអ្នកវិញ ។ ម្នាលព្រាហ្មណ៍ អ្នកណាជេរតបបុគ្គលដែលជេរ ខឹងតបបុគ្គលដែលខឹង ប្រកួតប្រកាន់តបបុគ្គលដែលប្រកួតប្រកាន់ ម្នាលព្រាហ្មណ៍ បុគ្គលនេះ តថាគតឱ្យឈ្មោះថា ស៊ីជាមួយគ្នា ធ្វើតបបុគ្គលដែលធ្វើហើយ តថាគតនោះ មិនបរិភោគជាមួយនឹងអ្នកទេ មិនធ្វើតបអ្នកវិញទេ ម្នាលព្រាហ្មណ៍ ការជេរនោះត្រូវបានទៅអ្នកវិញ ។ ព្រាហ្មណ៍ពោលថា បរិស័ទព្រមទាំងស្តេច ស្គាល់ព្រះគោតមដ៏ចម្រើនយ៉ាងនេះថា ព្រះសមណគោតម ជាព្រះអរហន្តមែន តែព្រះគោតមដ៏ចម្រើននៅតែខឹង ។

ព្រះមានព្រះភាគត្រាស់ថា :

**អក្កោធស្ស កុតោ កោធោ ទន្តស្ស សមជីវិនោ**
**សម្មទញ្ញា វិមុត្តស្ស ឧបសន្តស្ស តាទិនោ ៗ**

បុគ្គលមិនក្រោធ មានខ្លួនទូន្មានហើយ រស់នៅសមរម្យ មានចិត្តរួចស្រឡះ ព្រោះយល់ត្រូវ ជាអ្នកស្ងប់រម្ងាប់កិលេស មិនញាប់ញ័រដោយលោកធម៌ តើមានក្រោធ ពីណាមក ។

**តស្សេវ តេន បាបិយោ យោ កុទ្ធំ បដិកុជ្ឈតិ**
**កុទ្ធំ អប្បដិកុជ្ឈន្តោ សង្គាមំ ជេតិ ទុជ្ជយំ ៗ**

ព្រោះថាអ្នកណាក្រោធតបបុគ្គលដែលក្រោធហើយ អ្នកនោះឯង នឹងមានសេចក្ដីអាក្រក់ ព្រោះសេចក្ដីក្រោធនោះឯង ឯបុគ្គលមិនក្រោធតបនឹងអ្នកដែលក្រោធ រមែងឈ្នះសង្គ្រាមដែលគេឈ្នះបានដោយក្រ ។

**ឧភិន្នមត្ថំ ចរតិ អត្តនោ ច បរស្ស ច**
**បរំ សង្កុបិតំ ញត្វា យោ សតោ ឧបសម្មតិ ៗ**

អ្នកណាដឹងថា អ្នកដទៃក្រោធនឹងខ្លួន ជាអ្នកមានស្មារតីរម្ងាប់សេចក្ដីក្រោធបាន អ្នកនោះឈ្មោះថា ប្រព្រឹត្តនូវប្រយោជន៍





ដល់ជនទាំងពីរនាក់ គឺខ្លួនឯង និងអ្នកដទៃ ។

**ឧភិន្នំ តិកិច្ឆន្តានំ អត្តនោ ច បរស្ស ច**
**ជនា មញ្ញន្តិ ពាលោតិ យេ ធម្មស្ស អកោវិទាតិ ៗ**

បណ្ដាជនទាំង ២ នាក់ គឺខ្លួនឯង និងអ្នកដទៃ ដែលជាអ្នករក្សាសេចក្ដីសុខ ជនទាំងឡាយណា មិនឈ្លាសក្នុងធម៌ ជនទាំងឡាយនោះ រមែងសំគាល់អ្នកនោះ ថាជាមនុស្សពាល ។

កាលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ អក្កោសកភារទ្វាជព្រាហ្មណ៍ បានទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ណាស់ បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ណាស់ ។បេ។ ខ្ញុំព្រះអង្គនេះ សូមដល់នូវព្រះគោតមដ៏ចម្រើនផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹងទីរឭក ខ្ញុំព្រះអង្គសូមបាននូវ បព្វជ្ជានិងឧបសម្បទា ក្នុងសំណាក់ព្រះគោតមដ៏ចម្រើន ។ អក្កោសកភារទ្វាជព្រាហ្មណ៍ បានបព្វជ្ជានិងឧបសម្បទា ក្នុងសំណាក់ព្រះមានព្រះភាគហើយ ។ លុះអក្កោសកភារទ្វាជៈមានអាយុ បានឧបសម្បទា មិនយូរប៉ុន្មាន ចៀសចេញទៅតែម្នាក់ឯង ជាអ្នកមិនប្រមាទ មានព្យាយាមដុត

កម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន កុលបុត្រទាំងឡាយចេញចាកផ្ទះ ចូលទៅកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា លោកក៏បានធ្វើឱ្យជាក់ច្បាស់ បានសម្រេច ដោយប្រាជ្ញាដ៏ឧត្តមនៃខ្លួនឯង ក្នុងបច្ចុប្បន្ន នូវអនុត្តរធម៌នោះ ដែលជាទីបំផុតនៃព្រហ្មចរិយៈ ហើយដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយៈ បាននៅរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើរួចហើយ មគ្គភាវនាកិច្ចដទៃ ដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។ បណ្តាព្រះអរហន្តទាំងឡាយ ព្រះភារទ្វាជៈមានអាយុ ក៏ជាព្រះអរហន្តមួយអង្គដែរ ។

### នត្ថិ ទោសសមោ គហោ

**អ្នកចាប់ស្មើដោយទោសៈមិនមានឡើយ**

ពស់ចាប់កង្កែបលេប ឆ្មាចាប់កណ្តុរស៊ី ខ្លាចាប់ម្រឹគជាចំណី សេចក្តីខឹងក្រោធចាប់សត្វលោក លេបចូលទៅក្នុងកន្លែងនៃកំហុស ។

ចូរព្យាយាមរម្ងាប់នូវសេចក្តីក្រោធ កុំឱ្យកើតឡើងបានឡើយ បើរម្ងាប់មិនបានក៏សូមឱ្យនៅតែក្នុងចិត្តបានហើយ កុំឱ្យប្រាកដតាមមុខ តាមអាកប្បកិរិយា ឬតាមវាចា ព្រោះបើយើងសម្តែងចេញមកឱ្យប្រាកដ គឺវាជាការឃោសនានូវសេចក្តីអាក្រក់របស់យើងដោយខ្លួនឯង ។✍



## ១៥-កសិសូត្រ

## បិដកលេខ ៣០ ទំព័រ ១១៥

ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគគង់នៅក្នុងព្រាហ្មណគ្រាម ឈ្មោះឯកនាលា ក្នុងទក្ខិណាគិរិជនបទ នាដែនមគធៈ ។ សម័យនោះឯង កសិភារទ្វាជព្រាហ្មណ៍បានតាក់តែងនង្គ័លប្រមាណ ៥០០ ក្នុងវេលាដែលព្រោះស្រូវ ។

លំដាប់នោះឯង ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ហើយស្តេចចូលទៅកាន់ការងាររបស់កសិភារទ្វាជព្រាហ្មណ៍ ។ សម័យនោះឯង ការអង្គាស (លៀងភ្ញៀវ) របស់កសិភារទ្វាជព្រាហ្មណ៍ កំពុងប្រព្រឹត្តទៅ ។ លំដាប់នោះ ព្រះមានព្រះភាគស្តេចចូលទៅកាន់ការអង្គាស លុះចូលទៅដល់ហើយ ក៏ប្រថាប់នៅក្នុងទីសមគួរ ។ កសិភារទ្វាជព្រាហ្មណ៍បានឃើញព្រះមានព្រះភាគ ដែលទ្រង់ឈរបិណ្ឌបាត លុះឃើញហើយ ក៏បានពោលនូវពាក្យនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះសមណៈ ខ្ញុំព្រះអង្គភ្ជួរផង ព្រោះផង លុះខ្ញុំព្រះអង្គភ្ជួរហើយ

ព្រោះហើយ ទើបបរិភោគ បពិត្រព្រះសមណៈ ចំណែកព្រះអង្គចូរភ្ជួរផង ព្រោះផង លុះភ្ជួរហើយ ព្រោះហើយ ចូរបរិភោគចុះ ។ ម្នាលព្រាហ្មណ៍ តថាគតភ្ជួរផង ព្រោះផង លុះតថាគតភ្ជួរហើយ ព្រោះហើយ ទើបបរិភោគដែរ ។ យើងខ្ញុំ មិនឃើញនឹម ឬនង្គ័ល ផាល ឬជន្លួញ ឬគោទាំងឡាយរបស់ព្រះគោតមដ៏ចម្រើនទេ តែថាព្រះគោតមដ៏ចម្រើន ពោលយ៉ាងនេះថា ម្នាលព្រាហ្មណ៍ តថាគតភ្ជួរផង ព្រោះផង លុះតថាគត ភ្ជួរហើយ ព្រោះហើយ ទើបបរិភោគដែរ ។

លំដាប់នោះ កសិភារទ្វាជព្រាហ្មណ៍ បានពោលនឹងព្រះមានព្រះភាគ ដោយគាថា ថា :

**កស្សកោ បដិជានាសិ ន ច បស្សាមិ តេ កសឹ**
**កស្សកោ បុច្ឆិតោ ព្រូហិ កថំ ជានេមុ តំ កសិន្តិ ៕**

ព្រះអង្គប្ដេជ្ញាថាជាអ្នកភ្ជួរ តែថា ខ្ញុំព្រះអង្គមិនដែលឃើញនូវការភ្ជួររបស់ព្រះអង្គសោះ ខ្ញុំព្រះអង្គសូមសួរព្រះអង្គជាអ្នកភ្ជួរ សូមប្រាប់មក ធ្វើដូចម្ដេច នឹងឱ្យយើងខ្ញុំដឹងនូវការភ្ជួរនោះបាន ។

**សទ្ធា ពីជំ តបោ វុដ្ឋិ បញ្ញា មេ យុគនង្គលំ**
**ហិរី ឦសា មនោ យោត្តំ សតិ មេ ផាលបាចនំ ៕**





(ព្រះអង្គត្រាស់ថា ) សទ្ធាជាពូជ តបៈជាភ្លៀង បញ្ញារបស់តថាគតជានឹមនិងនង្គ័ល ហិរិជាយាមនង្គ័ល ចិត្តជាខ្សែ សតិរបស់តថាគត ជាផាលនិងជន្លួញ ។

**កាយគុត្តោ វចីគុត្តោ អាហារេ ឧទរេ យតោ**
**សច្ចំ ករោមិ និទ្ទានំ សោរច្ចំ មេ បមោចនំ ៕**

តថាគតគ្រប់គ្រងកាយ គ្រប់គ្រងវាចា សង្រួមអាហារ សង្រួមផ្ទៃ តថាគតធ្វើនូវការជម្រះស្មៅដោយសច្ចៈ សេចក្ដីត្រេកអរក្នុងព្រះនិព្វាន ទុកជាការឈប់សម្រាករបស់តថាគត ។

**វីរិយំ មេ ធុរធោរយ្ហំ យោគក្ខេមាធិវាហនំ**
**គច្ឆតិ អនិវត្តន្តំ យត្ថ គន្ត្វា ន សោចតិ ៕**

សេចក្ដីព្យាយាមរបស់តថាគត ដូចជាគោអូសនឹម ជាធម្មជាតនាំមកនូវព្រះនិព្វាន ជាទីក្សេមចាកយោគៈ បុគ្គលទៅក្នុងទីណា មិនសោកសៅ សេចក្ដីព្យាយាម រមែងទៅកាន់ទីនោះ ដែលជាទីមិនត្រឡប់មកវិញ ។

**ឯវមេសា កសី កដ្ឋា សា ហោតិ អមតប្ផលា**
**ឯតំ កសឹ កសិត្វាន សព្វទុក្ខា បមុច្ចតីតិ ៕**

ស្រែន៎ុះតថាគតបានភ្ជួរយ៉ាងនេះ ស្រែន៎ុះមាននិព្វានជាផល បុគ្គលភ្ជួរស្រែន៎ុះហើយ រមែងរួចចាកទុក្ខទាំងពួងបាន ។

កសិភារទ្វាជព្រាហ្មណ៍ ក្រាបទូលថា ព្រះគោតមដ៏ចម្រើន ជាអ្នកភ្ជួរដ៏ល្អ ចូរបរិភោគចុះ ព្រោះថា ព្រះគោតមដ៏ចម្រើន ភ្ជួរនូវស្រែ ដែលមានព្រះនិព្វានជាផល ។

ព្រះអង្គត្រាស់ថា តថាគត មិនគួរបរិភោគភោជនដែលបានអំពីការពោលគាថា ដូចជាចម្រៀងទេ ម្នាលព្រាហ្មណ៍ នេះជាធម្មតារបស់ពួកបុគ្គលអ្នកឃើញធម៌អាថ៌ ព្រះពុទ្ធទាំងឡាយ តែងហាមឃាត់នូវភោជន ដែលបានមកពីការពោលគាថា ដូចជាចម្រៀង ម្នាលព្រាហ្មណ៍ កាលបើធម៌គឺការចិញ្ចឹមជីវិតបរិសុទ្ធមានហើយ នេះឯងការចិញ្ចឹមជីវិតរបស់តថាគត ។ ចូរអ្នកទំនុកបម្រុងព្រះខីណាស្រព ដែលមានគុណបរិបូណ៌ ជាអ្នកស្វែងរកនូវគុណដ៏ធំ ជាអ្នករម្ងាប់នូវសេចក្តីរពឹស ដោយបាយនិងទឹកទៀតចុះ ព្រោះថា នោះជាខេត្តរបស់បុគ្គលអ្នកប្រាថ្នានូវបុណ្យ ។

កាលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ កសិភារទ្វាជព្រាហ្មណ៍ បានពោលពាក្យនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ បពិត្រព្រះគោតម





ដ៏ចម្រើន ច្បាស់ពេកណាស់ ។បេ។ ខ្ញុំព្រះអង្គ សូមដល់នូវព្រះរតនត្រ័យ ជាទីពឹងស្មើដោយជីវិត តាំងពីថ្ងៃនេះជាដើមរៀងទៅ ។

## អភិត្ថរេថ កល្យាណេ
## បុគ្គលគួរប្រញាប់ប្រញាល់ធ្វើនូវអំពើល្អ

បើចិត្តចង់ធ្វើល្អកើតឡើងហើយ ត្រូវប្រញាប់ធ្វើឱ្យបានសម្រេចទៅ ប្រយ័ត្នបាបវាមករំខាន ប្រាកដជាលែងបានធ្វើ ។ យើងត្រូវដឹងថា បាបក្នុងសន្តានចិត្តយើងគឺច្រើនណាស់ មានគ្រប់បែបគ្រប់ធុន វាមិនមែនទុកឱកាសឱ្យយើងធ្វើល្អបានងាយៗទេ ហើយត្រូវដឹងទៀតថា អំណាចរបស់បាបខ្លាំងក្លាពេកក្រៃ ទាំងល្បិចកលបោកប្រាស់ គឺនៅពីលើយើងជានិច្ច វាព្រមចុះចាញ់តែជាមួយនឹងអរិយមគ្គប៉ុណ្ណោះ ។✍

## ១៦-ឧទយសូត្រ

### បិដកលេខ ៣០ ទំព័រ ១១៨

សាវត្ថីនិទាន ។ គ្រានោះឯង ព្រះមានព្រះភាគទ្រង់ស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ស្តេចចូលទៅកាន់លំនៅរបស់ឧទយព្រាហ្មណ៍ ។ លំដាប់នោះឯង ឧទយព្រាហ្មណ៍ យកបាយ ដាក់ពេញបាត្រព្រះមានព្រះភាគ ។

ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រ និងចីវរក្នុងបុព្វណ្ហសម័យ ស្តេចចូលទៅកាន់លំនៅរបស់ឧទយព្រាហ្មណ៍អស់វារៈពីរដង ។ ឧទយព្រាហ្មណ៍ ក៏យកបាយដាក់ពេញបាត្រព្រះមានព្រះភាគ ជាគម្រប់ពីរដង ។

ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រ និងចីវរក្នុងបុព្វណ្ហសម័យ ស្តេចចូលទៅកាន់លំនៅរបស់ឧទយព្រាហ្មណ៍ជាគម្រប់បីដង ។ ឧទយព្រាហ្មណ៍ ក៏យកបាយដាក់ពេញបាត្រព្រះមានព្រះភាគ ជាគម្រប់បីដង ហើយពោលពាក្យនេះនឹងព្រះ-មានព្រះភាគថា ព្រះសមណគោតមនេះ ជាអ្នកជាប់ចិត្តក្នុងរសទើបនិមន្តមករឿយៗ ។





ព្រះមានព្រះភាគទ្រង់ត្រាស់តបថា :

**បុនប្បុនំ ចេវ វបន្តិ ពីជំ**<br>
**បុនប្បុនំ វស្សតិ ទេវរាជា**<br>
**បុនប្បុនំ ខេត្តំ កសន្តិ កស្សកា**<br>
**បុនប្បុនំ ធញ្ញមុបេន្តិ រដ្ឋំ ។**

ភ្លៀងបង្អុរចុះរឿយៗ ជនទាំងឡាយ ក៏ព្រោះពូជរឿយៗ អ្នកភ្ជួររាស់ទាំងឡាយ ភ្ជួររាស់ស្រែរឿយៗ តែងនាំស្រូវទៅកាន់ដែនក៏រឿយៗ ។

**បុនប្បុនំ យាចកា យាចយន្តិ**<br>
**បុនប្បុនំ ទានបតី ទទន្តិ**<br>
**បុនប្បុនំ ទានបតី ទទិត្វា**<br>
**បុនប្បុនំ សគ្គមុបេន្តិ ឋានំ ។**

ស្មូមទាំងឡាយ សូមរឿយៗ ម្ចាស់ទានទាំងឡាយ ក៏ឱ្យរឿយៗ លុះម្ចាស់ទានទាំងឡាយ ឱ្យរឿយៗ ហើយ រមែងទៅកាន់ឋានសួគ៌ក៏រឿយៗ ។

**បុនប្បុនំ ខីរណិកា ទុហន្តិ**<br>
**បុនប្បុនំ វច្ឆោ ឧបេតិ មាតរំ**

បុនប្បុនំ ភិលមតិ ផន្ទតិ ច
បុនប្បុនំ គព្ភមុបេតិ មន្ទោ
បុនប្បុនំ ជាយតិ មិយ្យតិ ច
បុនប្បុនំ សីវថិកំ ហរន្តិ ។

អ្នកវិតទឹកដោះគោទាំងឡាយ វិតរឿយៗ កូនគោក៏ចូលទៅរកមេគោរឿយៗ អ្នកល្ងង់ខ្លៅលំបាកផង ញាប់ញ័រផងរឿយៗ តែងចូលទៅកាន់គភ៌ក៏រឿយៗ ទាំងកើតទាំងស្លាប់ក៏រឿយៗ គេនាំទៅកាន់ទីស្មសានក៏រឿយៗ ។

មគ្គញ្ច លទ្ធា អបុនព្ភវាយ
បុនប្បុនំ ជាយតិ ភូរិបញ្ញោតិ ។

ចំណែកអ្នកមានបញ្ញា ដូចជាផែនដី លុះបាននូវមគ្គហើយ មិនកើតក្នុងភពថ្មីទៀត រឿយៗ ឡើយ ។

កាលព្រះមានព្រះភាគ ត្រាស់យ៉ាងនេះហើយ ឧទយ-ព្រាហ្មណ៍ បានពោលពាក្យនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ ។បេ។ សូមព្រះគោតមដ៏ចម្រើន



ចាំទុកនូវខ្ញុំព្រះអង្គថាជាឧបាសក អ្នកដល់នូវព្រះរតនត្រ័យ ជាទីពឹងស្មើដោយជីវិត តាំងពីថ្ងៃនេះជាដើមរៀងទៅ ។

## ឧត្តិដ្ឋេ នប្បមជ្ជេយ្យ
### បព្វជិតមិនគប្បីប្រមាទក្នុងបិណ្ឌបាត
### ដែលខ្លួនត្រូវក្រោកឡើងឈរចាំទទួលឡើយ

បព្វជិតកាលបើធ្វើឱ្យទំនៀមរបស់អ្នកត្រាច់ បិណ្ឌបាតជាប្រក្រតី មានការសាបសូន្យ ហើយស្វែងរកភោជនដែលប្រណីត ឈ្មោះថាមានសេចក្តីប្រមាទក្នុងដុំបាយ ដែលខ្លួនត្រូវក្រោកឡើងឈរចាំទទួល ។

ម្យ៉ាងទៀត បព្វជិតគប្បីពិចារណាថា អាត្មាអញមិនមែនជាបិតា មិនមែនជាញាតិរបស់គេទេ ប៉ុន្តែគេបានប្រគេននូវរបស់ប្រណីតដល់អាត្មាអញ ព្រោះគេត្រូវការបុណ្យច្រើន ដូច្នេះអាត្មាអញត្រូវមានសីលបរិសុទ្ធ និងមិនត្រូវមាននូវសេចក្តីប្រមាទឡើយ ។ ✍

## ១៧_សុភាសិតសូត្រ

### បិដកលេខ ៣០ ទំព័រ ១៥៩

សាវត្ថីនិទាន ។ ក្នុងទីនោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំង-នោះ ទទួលព្រះបន្ទូលព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ព្រះមានព្រះភាគត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ វាចាប្រកបដោយអង្គ ៤ ឈ្មោះថាសុភាសិត មិនមែនទុព្ភាសិតទេ ជាវាចាមិនមានទោសផង ដែលអ្នកប្រាជ្ញមិនតិះដៀលផង ។ វាចាដែលប្រកបដោយអង្គ ៤ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ រមែងពោលពាក្យសុភាសិត មិនពោលពាក្យទុព្ភាសិត ១ ពោលពាក្យជាធម៌ មិនពោលពាក្យមិនជាធម៌ ១ ពោលពាក្យជាទីស្រឡាញ់ មិនពោលពាក្យមិនជាទីស្រឡាញ់ ១ ពោលពាក្យពិត មិនពោលពាក្យកុហក ១ ។ ម្នាលភិក្ខុទាំងឡាយ វាចាប្រកបដោយអង្គ ៤ នេះឯង ឈ្មោះថាសុភាសិត មិនមែនទុព្ភាសិតទេ ជាវាចាមិនមានទោសផង ដែលអ្នកប្រាជ្ញមិនតិះដៀលផង ។





ព្រះមានព្រះភាគ ទ្រង់ត្រាស់ភាសិតនេះហើយ លុះព្រះសុគតជាសាស្តា ទ្រង់ត្រាស់ភាសិតនេះហើយ ក៏ទ្រង់ត្រាស់គាថានេះតទៅទៀតថា :

**សុភាសិតំ ឧត្តមមាហុ សន្តោ**
**ធម្មំ ភណេ នាធម្មន្តំ ទុតិយំ**
**បិយំ ភណេ នាប្បិយន្តំ តតិយំ**
**សច្ចំ ភណេ នាលិកន្តំ ចតុត្ថន្តិ ។**

ពួកសប្បុរស ពោលសុភាសិត ជាពាក្យខ្ពង់ខ្ពស់ (ទី ១) ពោលពាក្យជាធម៌ មិនពោលពាក្យមិនជាធម៌ នោះជាទី ២ ពោលពាក្យជាទីស្រឡាញ់ មិនពោលពាក្យមិនជាទីស្រឡាញ់ នោះជាទី ៣ ពោលពាក្យពិត មិនពោលពាក្យកុហក នោះជាទី ៤ ។

លំដាប់នោះឯង ព្រះវង្គីសៈ មានអាយុ ក្រោកចាកអាសនៈ ហើយធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង ប្រណម្យអញ្ជលី ឆ្ពោះទៅរកព្រះមានព្រះភាគ ហើយពោលពាក្យនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គសូមសម្តែងធម៌ បពិត្រព្រះសុគត ខ្ញុំព្រះអង្គសូមសម្តែងធម៌ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលវង្គីសៈ អ្នកចូរសម្តែងធម៌ចុះ ។

លំដាប់នោះឯង ព្រះវង្គីសៈមានអាយុ បានពោលសរសើរព្រះមានព្រះភាគ ដោយគាថាទាំងឡាយដ៏សមគួរ ក្នុងទីចំពោះព្រះភក្ត្រថា :

**តមេវ វាចំ ភាសេយ្យ យាយត្តានំ ន តាបយេ**
**បរេ ច ន វិហឹសេយ្យ សា វេ វាចា សុភាសិតា ៕**

បុគ្គលមិនធ្វើខ្លួនឱ្យក្ដៅ ដោយវាចាណា គប្បីពោលវាចានោះឯង មួយទៀត បុគ្គលមិនគប្បីបៀតបៀនពួកជនដទៃ (ដោយវាចាណា) វាចានោះឯង ឈ្មោះថាសុភាសិត ។

**បិយវាចមេវ ភាសេយ្យ យា វាចា បដិនន្ទិតា**
**យំ អនាទាយ បាបានិ បរេសំ ភាសតេ បិយំ ៕**

វាចាណា ដែលគេត្រេកអរ បុគ្គលគប្បីពោលនូវវាចានោះ ជាវាចាជាទីស្រឡាញ់ បុគ្គលពោលនូវវាចាណា មិនកាន់យកវាចាដ៏អាក្រក់ ពោលនូវវាចាជាទីស្រឡាញ់ ដល់ជនទាំងឡាយដទៃ (បុគ្គលគប្បីពោលនូវវាចានោះ) ។



**សច្ចំ វេ អមតា វាចា ឯស ធម្មោ សនន្តនោ**
**សច្ចេ អត្ថេ ច ធម្មេ ច អាហុ សន្តោ បតិដ្ឋិតា ៕**

ពាក្យពិតឈ្មោះថាជាពាក្យមិនស្លាប់ ធម៌នេះជាប្រពៃណីមានតាំងពីបុរាណកាលមក ពួកសប្បុរស តាំងនៅហើយក្នុងសច្ចៈដែលជាអត្ថផង ជាធម៌ផង។

**យំ ពុទ្ធោ ភាសតិ វាចំ ខេមំ និព្វានបត្តិយា**
**ទុក្ខស្សន្តកិរិយាយ សា វេ វាចានមុត្តមាតិ ៕**

ព្រះពុទ្ធទ្រង់ពោលវាចាណា ដ៏ក្សេមក្សាន្ត ដើម្បីដល់នូវព្រះនិព្វាន ធ្វើនូវទីបំផុតទុក្ខ (គឺធ្វើនូវវដ្ដទុក្ខឱ្យអស់ទៅ ) វាចានោះឯង ជាវាចាដ៏ខ្ពង់ខ្ពស់ជាងវាចាទាំងឡាយ ។

## ១៨-បុនព្វសុសុត្រ

### បិដកលេខ ៣០ ទំព័រ ២១៨

សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ព្រះមានព្រះភាគទ្រង់ពន្យល់ណែនាំពួកភិក្ខុឱ្យឃើញច្បាស់ ឱ្យកាន់យក ឱ្យអាចហាន ឱ្យរីករាយ ដោយធម្មីកថា ប្រកបដោយព្រះនិព្វាន ។ ពួកភិក្ខុនោះ ក៏ធ្វើឱ្យជាប្រយោជន៍ ធ្វើទុកក្នុងចិត្ត ប្រមូលមកនូវចិត្តទាំងពួង ផ្ទៀងសោតប្បសាទប្រុងស្តាប់ធម៌ ។

គ្រានោះឯង យក្ខិនីឈ្មោះបុនព្វសុមាតា លួងកូនតូច យ៉ាងនេះថា

**តុណ្ហី ឧត្តរិកេ ហោហិ តុណ្ហី ហោហិ បុនព្វសុ**
**យាវាហំ ពុទ្ធសេដ្ឋស្ស ធម្មំ សោស្សាមិ សត្ថុនោ ៕**

ម្នាលនាងឧត្តរា ចូរកូនស្ងៀមទៅ ម្នាលបុនព្វសុ ចូរកូនស្ងៀមទៅ ម៉ែនឹងស្តាប់នូវព្រះធម៌ របស់ព្រះសាស្តាជាព្រះពុទ្ធ ដ៏ប្រសើរសិន ។



**និព្វានំ ភគវា អាហ សព្វគន្ថប្បមោចនំ**
**អតិវេលា ច មេ ហោតិ អស្មិំ ធម្មេ បិយាយនា ៕**

ព្រះមានព្រះភាគ បានសម្តែងនូវព្រះនិព្វាន ថា ជាគ្រឿងរួចចាកគន្ថធម៌ទាំងពួង ម្យ៉ាងទៀត សេចក្តីប្រាថ្នាក្នុងធម៌នោះ របស់ម៉ែខ្លាំងហួសប្រមាណ ។

**បិយោ លោកេ សកោ បុត្តោ បិយោ លោកេ សកោ បតិ**
**តតោ បិយតរំ មយ្ហំ អស្ស ធម្មស្ស មគ្គនា ៕**

កូនរបស់ខ្លួន ក៏ជាទីស្រឡាញ់ក្នុងលោក ប្តីរបស់ខ្លួនក៏ជាទីស្រឡាញ់ក្នុងលោក តែសេចក្តីប្រាថ្នាក្នុងធម៌នោះ ជាទីស្រឡាញ់របស់ម៉ែក្រៃលែងជាងនោះទៅទៀត ។

**ន ហិ បុត្តោ បតិ វាបិ បិយោ ទុក្ខា បមោចយេ**
**យថា សទ្ធម្មស្សវនំ ទុក្ខា មោចេតិ បាណិនំ ៕**

កូនក្តី ប្តីក្តី ដែលជាទីស្រឡាញ់ មិនមែនរំដោះម៉ែឱ្យរួចចាកទុក្ខបានទេ មានតែការស្តាប់នូវព្រះធម៌ ទើបរំដោះសត្វទាំងឡាយឱ្យរួចចាកទុក្ខបាន ។

**លោកេ ទុក្ខបរេតស្មឹ  ជរាមរណសំយុត្តេ**
**ជរាមរណមោក្ខាយ  យំ ធម្មំ អភិសម្ពុធំ**
**តំ ធម្មំ សោតុមិច្ឆាមិ  តុណ្ហី ហោហិ បុនព្វសូតិ ។**

កាលបើសត្វលោកត្រូវសេចក្តីទុក្ខគ្របសង្កត់ ប្រកបដោយជរានិងមរណៈហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដឹងហើយ នូវធម៌ណា ម៉ែចង់ស្តាប់ធម៌នោះ ដើម្បីរួចចាកជរានិងមរណៈ ម្នាលបុនព្វសុ ចូរកូនស្ងៀមទៅ ។

បុនព្វសុកុមារ តបថា :

**អម្ម ន ព្យាហរិស្សាមិ  តុណ្ហីភូតាយមុត្តរា**
**ធម្មមេវ និសាមេហិ  សទ្ធម្មស្សវនំ សុខំ ។**

បពិត្រអ្នកម៉ែ ខ្ញុំមិននិយាយទេ ទាំងនាងឧត្តរានេះក៏ស្ងៀមដែរ សូមអ្នកម៉ែស្តាប់ធម៌ចុះ ការស្តាប់ព្រះសទ្ធម្ម នាំមកនូវសេចក្តីសុខ ។

**សទ្ធម្មស្ស អនញ្ញាយ  អម្ម ទុក្ខំ ចរាមសេ**
**ឯស ទេវមនុស្សានំ  សម្មូឡ្ហានំ បភង្ករោ**
**ពុទ្ធោ អន្តិមសារីរោ  ធម្មំ ទេសេតិ ចក្ខុមាតិ ។**

បពិត្រអ្នកម៉ែ យើងដើរទាំងទុក្ខ ព្រោះមិនបានដឹងនូវ





ព្រះសទ្ធម្ម ព្រះពុទ្ធអង្គនោះ ជាអ្នកធ្វើនូវពន្លឺដល់ទេវតានិងមនុស្សទាំងឡាយដែលវង្វេង ព្រះអង្គមានព្រះសរីរៈជាទីបំផុត មានបញ្ញាចក្ខុ ទ្រង់កំពុងសម្តែងធម៌ ។ (ម៉ែនិងកូនប្រុសបានសម្រេចសោតាបត្តិផល ឯនាងឧត្តរា ជាកូនស្រីក៏មានឧបនិស្ស័យដែរ តែមិនទាន់បានសម្រេច ព្រោះនៅតូចពេក ទទួលធម្មទេសនាមិនបាន ។ អដ្ឋកថា ។) ។

បុនព្វសុមាតាពោលថា :

**សាធុ ខោ បណ្ឌិតោ នាម បុត្តោ ជាតោ ឧរេ សយោ**
**បុត្តោ មេ ពុទ្ធសេដ្ឋស្ស  ធម្មសុទ្ធំ បិយាយតិ ។**

ប្រពៃណាស់ហ្ន៎ កូនកើតហើយ ដេកនៅនាទ្រូងម៉ែ គឺជាបណ្ឌិត កូនរបស់ម៉ែស្រឡាញ់ធម៌ដ៏បរិសុទ្ធរបស់ព្រះពុទ្ធដ៏ប្រសើរ។

**បុនព្វសុ សុខី ហោហិ  អជ្ជាហម្ហិ សមុគ្គតា**
**ទិដ្ឋានិ អរិយសច្ចានិ  ឧត្តរាបិ សុណាតុ មេតិ ។**

ម្នាលបុនព្វសុ ចូរកូនបានសុខស្រួល ម៉ែបានខ្ពង់ខ្ពស់ (ក្នុងសាសនា ) តាំងពីថ្ងៃនេះហើយ ទាំងនាងឧត្តរា ក៏ចូរស្តាប់អរិយសច្ចទាំងឡាយ ដែលម៉ែនិងកូនបានឃើញហើយចុះ ។

## ១៩-អាឡវកសូត្រ
### បិដកលេខ ៣០ ទំព័រ ២៣០

ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងលំនៅរបស់យក្សឈ្មោះអាឡវកៈ ក្នុងដែនអាឡវី ។ គ្រានោះឯង អាឡវកយក្ស ចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ទើបពោលនឹងព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រសមណៈ ចូរលោកចេញទៅ ។ ព្រះមានព្រះភាគទទួលថា ម្នាលអាវុសោ ប្រពៃហើយ ដូច្នេះ ក៏ស្តេចចេញទៅ ។ អាឡវក-យក្ស ពោលថា ម្នាលសមណៈ ចូរលោកមកវិញ ។ ព្រះមានព្រះ-ភាគទទួលថា ម្នាលអាវុសោ ប្រពៃហើយ ដូច្នេះ ក៏ស្តេចចូលមកវិញ ។ អាឡវកយក្ស បានពោលនឹងព្រះមានព្រះភាគ យ៉ាងនេះ អស់វារៈពីរដងថា ម្នាលសមណៈ ចូរលោកចេញទៅ ។ ព្រះមានព្រះភាគក៏ទទួលថា ម្នាលអាវុសោ ប្រពៃហើយ ដូច្នេះក៏ស្តេចចេញទៅ ។ អាឡវកយក្សពោលថា ម្នាលសមណៈ ចូរលោកមកវិញ ។ ព្រះមានព្រះភាគ ទទួលថា ម្នាលអាវុសោ ប្រពៃហើយ ដូច្នេះ ក៏





ស្តេចចូលមកវិញ ។ អាឡវកយក្ស បានពោលនឹងព្រះមានព្រះភាគយ៉ាងនេះជាគម្រប់បីដងថា ម្នាលសមណៈ ចូរលោកចេញទៅវិញ ។ ព្រះមានព្រះភាគ ទទួលថា ម្នាលអាវុសោ ប្រពៃហើយ ដូច្នេះ ក៏ស្តេចចេញទៅ ។ អាឡវកយក្សពោលថា ម្នាលសមណៈ ចូរលោកចូលមកវិញ ។ ព្រះមានព្រះភាគ ទទួលថា ម្នាលអាវុសោ ប្រពៃហើយ ដូច្នេះ ក៏ទ្រង់ចូលមកវិញ ។

អាឡវកយក្ស បានពោលនឹងព្រះមានព្រះភាគ អស់វារៈ ៤ ដងទៀតថា ម្នាលសមណៈ ចូរលោកចេញទៅវិញ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអាវុសោ តថាគតនឹងមិនចេញទៅទេ កិច្ចណាអ្នកឯងត្រូវធ្វើ ចូរអ្នកឯងធ្វើកិច្ចនោះចុះ ។ ម្នាលសមណៈ ខ្ញុំនឹងសួរប្រស្នាចំពោះលោក បើលោកមិនដោះប្រស្នាខ្ញុំទេ ខ្ញុំនឹងបន្សាត់ចិត្តលោក ឬវះហឫទ័យរបស់លោក ពុំនោះសោត ខ្ញុំនឹងចាប់ជើងលោកបោះទៅ ក្នុងត្រើយខាងនាយនៃទន្លេគង្គា ។ ព្រះមានព្រះភាគ ត្រាស់ថា ម្នាលអាវុសោ បុគ្គលណា បន្សាត់ចិត្តតថាគត ឬវះហឫទ័យ ឬក៏ចាប់ជើងគ្រវែងទៅ ក្នុងត្រើយខាងនាយនៃទន្លេគង្គា តថាគត មិនដែលឃើញបុគ្គលនោះសោះ ក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក និងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និង

មនុស្សដ៏សេស ម្នាលអាវុសោ បើដូច្នោះ ចូរអ្នកឯងសួរប្រស្នា ដែលអ្នកឯងប៉ុនប៉ងសួរចុះ ។

អាឡវកយក្សសួរថា :

**កឹសូធ វិត្តំ បុរិសស្ស សេដ្ឋំ**
**កឹសុ សុចិណ្ណំ សុខមាវហាតិ**
**កឹសុ ហវេ សាធុតរំ រសានំ**
**កថំ ជីវី ជីវិតមាហុ សេដ្ឋន្តិ ៕**

អ្វីហ្ន៎ ជាទ្រព្យប្រសើររបស់បុរសក្នុងលោកនេះ អ្វីហ្ន៎ ដែលបុគ្គលសន្សំដោយប្រពៃហើយ នាំសេចក្តីសុខមកឱ្យ របស់អ្វី ដែលមានរសឆ្ងាញ់ វិសេសជាងរសទាំងឡាយ ពួកអ្នកប្រាជ្ញពោលថា បុគ្គលដែលរស់នៅដូចម្តេច ឈ្មោះថារស់នៅប្រសើរ ។

ព្រះមានព្រះភាគត្រាស់តបថា :

**សទ្ធីធ វិត្តំ បុរិសស្ស សេដ្ឋំ**
**ធម្មោ សុចិណ្ណោ សុខមាវហាតិ**
**សច្ចំ ហវេ សាធុតរំ រសានំ**
**បញ្ញាជីវី ជីវិតមាហុ សេដ្ឋន្តិ ៕**



សទ្ធាជាទ្រព្យដ៏ប្រសើរ របស់បុរសក្នុងលោកនេះ សុចរិត-ធម៌ដែលបុគ្គលសន្សំដោយប្រពៃ តែងនាំសេចក្តីសុខមកឱ្យ សច្ចៈហ្នឹងឯងមានរសឆ្ងាញ់វិសេសជាងរសទាំងឡាយ ពួកអ្នកប្រាជ្ញពោលថា បុគ្គលរស់នៅដោយប្រាជ្ញា ឈ្មោះថារស់នៅប្រសើរ ។

អាឡវកយក្សទូលថា :

**កថំសុ តរតិ ឱឃំ　កថំសុ តរតិ អណ្ណវំ**
**កថំសុ ទុក្ខមច្ចេតិ　កថំសុ បរិសុជ្ឈតីតិ ៕**

បុគ្គលឆ្លងអន្លង់បាន ដោយអ្វីហ្ន៎ ឆ្លងសមុទ្របាន ដោយអ្វី បុគ្គលកន្លងសេចក្តីទុក្ខបាន ដោយអ្វី បរិសុទ្ធបាន ដោយអ្វី ។

ព្រះមានព្រះភាគត្រាស់តបថា :

**សទ្ធាយ តរតិ ឱឃំ　អប្បមាទេន អណ្ណវំ**
**វីរិយេន ទុក្ខមច្ចេតិ　បញ្ញាយ បរិសុជ្ឈតីតិ ៕**

បុគ្គលឆ្លងអន្លង់បាន ដោយសទ្ធា ឆ្លងសមុទ្របាន ដោយសេចក្តីមិនប្រមាទ កន្លងសេចក្តីទុក្ខបាន ដោយសេចក្តីព្យាយាម បរិសុទ្ធបាន ដោយប្រាជ្ញា ។

អាឡវកយក្សទូលសួរ :

**កថំសុ លភតេ បញ្ញំ  កថំសុ វិន្ទតេ ធនំ**
**កថំសុ កិត្តឹ បប្បោតិ  កថំ មិត្តានិ គន្ថតិ**
**អស្មា លោកា បរំ លោកំ កថំ បេច្ច ន សោចតីតិ ៕**

បុគ្គលបានប្រាជ្ញាដោយអ្វី បានទ្រព្យដោយអ្វី ដល់នូវសេចក្ដីសរសើរដោយអ្វី ចងពួកមិត្តបានដោយអ្វី បុគ្គលលះលោកនេះទៅកាន់លោកខាងមុខមិនសោកសៅ ក្នុងលោកខាងមុខ ដោយអ្វី ។

ព្រះមានព្រះភាគត្រាស់តបថា :

**សទ្ទហានោ អរហតំ  ធម្មំ និព្វានបត្តិយា**
**សុស្សូសំ លភតេ បញ្ញំ  អប្បមត្តោ វិចក្ខណោ ៕**

បុគ្គលជឿធម៌របស់ព្រះអរហន្តទាំងឡាយ រមែងប្រព្រឹត្តទៅ ដើម្បីដល់ព្រះនិព្វាន បុគ្គលមានប្រាជ្ញាពិចារណា មិនប្រមាទកាលស្ដាប់ដោយប្រពៃ រមែងបាននូវប្រាជ្ញា ។

**បដិរូបការី ធុរវា  ឧដ្ឋាតា វិន្ទតេ ធនំ**
**សច្ចេន កិត្តឹ បប្បោតិ  ទទំ មិត្តានិ គន្ថតិ ៕**

បុគ្គលមានការងារសមតាមកាល មានធុរៈ (មិនទម្លាក់ចោល ) ជាអ្នកតស៊ូ រមែងបាននូវទ្រព្យ បុគ្គលដល់នូវសេចក្ដីសរសើរដោយសច្ចៈ បុគ្គលអ្នកឱ្យ រមែងចងពួកមិត្តបាន ។





**យស្សេតេ ចតុរោ ធម្មា  សទ្ធស្ស ឃរមេសិនោ**
**សច្ចំ ធម្មោ ធិតិ ចាគោ  ស វេ បេច្ច ន សោចតិ[១] ៕**

ធម៌ទាំង ៤ នេះ គឺសច្ចៈ ១ ធម្មៈ(បញ្ញា ) ១ ធិតិ (ព្យាយាមអត់ធន់ ) ១ ចាគៈ (ការបរិច្ចាគ ) ១ របស់បុគ្គលណាដែលមានសទ្ធាហើយ នៅគ្រប់គ្រងផ្ទះ បុគ្គលនោះឯង រមែងមិនសោយសោក ក្នុងលោកខាងមុខ ។

**ឥង្ឃ អញ្ញេបិ បុច្ឆស្សុ  បុថូ សមណព្រាហ្មណេ**
**យទិ សច្ចា ទមា ចាគា ខន្ត្យា ភិយ្យោធ វិជ្ជតីតិ ៕**

បើដូច្នោះ ចូរអ្នកសួរពួកសមណព្រាហ្មណ៍ឯទៀតឱ្យច្រើនគ្នាចុះ ក្រែងមានធម៌ណាក្នុងលោកនេះ វិសេសជាង សច្ចៈ ទមៈ ចាគៈ ខន្តី ទៅទៀត ។

អាឡវកយក្សប្រកាសសេចក្ដីជ្រះថ្លារបស់ខ្លួនថា :

ក្នុងវេលានេះ ខ្ញុំនឹងសួរពួកសមណព្រាហ្មណ៍ច្រើនគ្នា

១.បិដកលេខ ៥៤ ,ទំព័រ ៦៣ , អាឡវកសូត្រ ។

ដូចម្តេចបាន ( ព្រោះ ) ខ្ញុំទើបតែនឹងដឹងប្រយោជន៍បរលោកក្នុងថ្ងៃនេះ ដោយសារព្រះពុទ្ធស្តេចមកគង់ក្នុងដែនអាឡវី ជាប្រយោជន៍ដល់ខ្ញុំ ខ្ញុំទើបតែនឹងដឹងក្នុងថ្ងៃនេះ ទានដែលគេឱ្យចំពោះបុគ្គលណា មានផលច្រើន ខ្ញុំនឹងចេញពីស្រុកមួយ ទៅស្រុកមួយ ចេញពីបុរីមួយ ទៅបុរីមួយ នមស្ការនូវព្រះសម្ពុទ្ធផង ព្រះធម៌ដ៏ប្រសើរផង ។

### យស្ស អច្ចន្តទុស្សីល្យំ

#### ភាពជាអ្នកទ្រុស្តសីលហួសកម្រិត...នៃបុគ្គលណា

ភាពជាអ្នកទ្រុស្តសីលហួសកម្រិតបានគ្របសង្កត់នូវអត្តភាពនៃបុគ្គលណា បុគ្គលនោះ នឹងដល់នូវសេចក្តីវិនាស ដូចជាដើមឈើដែលត្រូវវល្លិជ្រៃរួបរឹត អ៊ីចឹងឯង ។

វាជាការបៀតបៀនខ្លួនឯងដោយពិត ព្រោះការទ្រុស្តសីលគឺជាតួកម្មអាក្រក់ ជាធម្មតានៃកម្មអាក្រក់វាមិនមែនឱ្យផលល្អដល់អ្នកធ្វើឡើយ ដូច្នេះ អ្នកទ្រុស្តសីលគឺជាចោរ តែជាចោរដែលធ្វើនូវសេចក្តីវិនាសឱ្យដល់ខ្លួនឯង ។ ✍



## ២០-សុទត្តសូត្រ

### បិដកលេខ ៣០ ទំព័រ ២២១

សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងសីតវ័នទៀបក្រុងរាជគ្រឹះ ។ សម័យនោះឯង អនាថបិណ្ឌិកគហបតី បានទៅដល់ក្រុងរាជគ្រឹះ ដោយកិច្ចការនីមួយ [១] ។ អនាថបិណ្ឌិកគហបតី បានឮដំណឹងថា ព្រះពុទ្ធកើតឡើងហើយក្នុងលោក ក៏មានប្រាថ្នាដើម្បីចូលទៅជួបនឹងព្រះមានព្រះភាគ ក្នុងខណៈនោះឯង ។ គ្រានោះឯង អនាថបិណ្ឌិកគហបតី មានសេចក្តីត្រិះរិះយ៉ាងនេះថា ថ្ងៃនេះជាកាលមិនគួរដើម្បីចូលទៅជួបព្រះមានព្រះ-ភាគទេ ចាំដល់ថ្ងៃស្អែកអាត្មាអញនឹងចូលទៅជួបព្រះមានព្រះភាគដោយកាលគួរពុំខាន ។ កាលបើសតិតាំងនៅ ក្នុងពុទ្ធគុណហើយគាត់ដេកក្នុងមួយរាត្រី ក្រោកឡើង ៣ ដង ដោយស្មានថាភ្លឺហើយ ។ គ្រានោះឯង អនាថបិណ្ឌិកគហបតី ក៏ចូលទៅរកសីវថិកទ្វារ ( ទ្វារស្មសាន ) ។ ពួកអមនុស្ស ក៏បើក ទ្វារឱ្យ ។

គ្រានោះ កាលអនាថបិណ្ឌិកគហបតី កំពុងចេញទៅអំពី

---

១-កិច្ចការនីមួយក្នុងទីនេះ សំដៅយកការជួញ ។ អដ្ឋកថា ។

នគរ ពន្លឺក៏បាត់ទៅ ងងឹតក៏កើតប្រាកដឡើង សេចក្តីភ័យ តក់ស្លុត និងការព្រឺរោមក៏កើតឡើង ។ គាត់ចង់ត្រឡប់មកអំពីទីនោះវិញ ។ គ្រានោះឯង យក្សឈ្មោះសិវកៈបំបាំងខ្លួនមិនឱ្យឃើញ ធ្វើសំឡេងឱ្យឮឡើងថា ដំរីមួយសែន សេះមួយសែន រថទឹមដោយមេសេះអស្សតរមួយសែន នាងកញ្ញាពាក់កុណ្ឌល ជាវិការៈនៃកែវមណីមួយសែននាក់ ក៏មិនដល់ថ្លៃមួយចំណិតនៃជំហានមួយ ដែលគេចែកឱ្យជាចំណែកដប់ប្រាំមួយ ៗ ដងឡើយ ម្នាលគហបតី ចូរអ្នកឈានទៅមុខចុះ ម្នាលគហបតី ចូរអ្នកឈានទៅមុខចុះ ការឈានទៅមុខរបស់អ្នកប្រសើរជាង ឯការត្រឡប់ថយក្រោយវិញ មិនប្រសើរទេ ។

គ្រានោះឯង ងងឹតបាត់ទៅ ពន្លឺក៏កើតប្រាកដឡើង ដល់អនាថបិណ្ឌិកគហបតី ទាំងសេចក្តីភ័យ ការតក់ស្លុត និងការព្រឺរោម ក៏ស្ងប់រម្ងាប់ទៅ ។ ...

គ្រានោះឯង អនាថបិណ្ឌិកគហបតី ចូលទៅឯសីតវ័ន ។ ក៏សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់តើនឡើង ក្នុងបច្ចូសសម័យនៃរាត្រី ទៅចង្ក្រមក្នុងទីវាលស្រឡះ ។ ព្រះមានព្រះភាគបានទតឃើញអនាថបិណ្ឌិកគហបតី កំពុងមកអំពីចម្ងាយ លុះទតឃើញហើយ ទ្រង់ចុះអំពីទីចង្ក្រមមកគង់លើអាសនៈ ដែលគេ





ក្រាលថ្វាយ ។ លុះព្រះមានព្រះភាគ ទ្រង់គង់ហើយ ក៏ត្រាស់ហៅអនាថបិណ្ឌិកគហបតី យ៉ាងនេះថា ម្នាលសុទត្ត ចូរអ្នកមកអាយ ។ ទើបអនាថបិណ្ឌិកគហបតី ឱនក្បាលទៀបបាទា នៃព្រះមាន-ព្រះភាគក្នុងទីនោះដោយគិតថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅអញចំឈ្មោះ ក៏ក្រាបបង្គំទូលសួរព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ គង់នៅជាសុខទេឬ ។

ព្រះអង្គទ្រង់ត្រាស់ថា :

**សព្វទា វេ សុខំ សេតិ ព្រាហ្មណោ បរិនិព្វុតោ ។**

បុគ្គលជាអ្នកបន្សាត់បង់បាប រំលត់កិលេស រមែងដេកជាសុខសព្វកាល ។

**យោ ន លិម្បតិ កាមេសុ សីតិភូតោ និរូបធិ**
**សព្វា អាសត្តិយោ ឆេត្វា វិនេយ្យ ហទយេ ទរំ**
**ឧបសន្តោ សុខំ សេតិ សន្តឹ បប្បុយ្យ ចេតសាតិ ។**

បុគ្គលណាមានសេចក្តីត្រជាក់ត្រជំ ឥតមានឧបធិក្កិលេស កាត់បង់តណ្ហាទាំងអស់ បន្ទោបង់នូវសេចក្តីក្រវល់ក្រវាយក្នុងហឫទ័យ មិនបានប្រឡាក់ ក្នុងកាមទាំងឡាយ បុគ្គលនោះ រមែងដល់នូវសេចក្តីរម្ងាប់កិលេសដោយចិត្ត មានចិត្តស្ងប់រម្ងាប់ ដេកនៅជាសុខ ។

## ២១. អនាថបិណ្ឌិកសូត្រ

### បិដកលេខ ២៩ ទំព័រ ១៤៥

អនាថបិណ្ឌិកទេវបុត្ត ឋិតនៅក្នុងទីដ៏សមគួរហើយ ទើបពោលនូវគាថាទាំងនេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា :

**ឥទំ ហិតំ ជេតវនំ ឥសិសង្ឃនិសេវិតំ**
**អាវុត្ថំ ធម្មរាជេន បីតិសញ្ជននំ មម ។**

វត្តជេតពននេះ ជាវត្តមានប្រយោជន៍ ដែលពួកឥសី គឺភិក្ខុសង្ឃគង់នៅមិនដាច់ ជាវត្តដែលព្រះសម្ពុទ្ធ ជាធម្មរាជ ទ្រង់គង់នៅ ជាទីញ៉ាំងបីតិឲ្យកើតដល់ខ្ញុំព្រះអង្គ ។

**កម្មំ វិជ្ជា ច ធម្មោ ច សីលំ ជីវិតមុត្តមំ**
**ឯតេន មច្ចា សុជ្ឈន្តិ ន គោត្តេន ធនេន វា ។**

សត្វទាំងឡាយរមែងបរិសុទ្ធដោយអដ្ឋង្គិកមគ្គនេះ គឺ កម្មៈ បានដល់មគ្គចេតនា វិជ្ជា បានដល់សម្មាទិដ្ឋិ និងសម្មាសង្កប្បៈ ធម្មៈ បានដល់សម្មាវាយាមៈ សម្មាសតិនិងសម្មាសមាធិ សីលៈ បានដល់





សម្មាវាចា សម្មាកម្មន្តៈ និងសម្មាអាជីវៈ ឈ្មោះថាជីវិតដ៏ឧត្តម មិនមែនបរិសុទ្ធដោយគោត្រ ឬដោយទ្រព្យទេ ។

**តស្មា ហិ បណ្ឌិតោ បោសោ សម្បស្សំ អត្ថមត្តនោ**
**យោនិសោ វិចិនេ ធម្មំ ឯវំ តត្ថ វិសុជ្ឈតិ ។**

ព្រោះហេតុនោះឯង បុរសជាបណ្ឌិត កាលបើឃើញច្បាស់នូវប្រយោជន៍របស់ខ្លួន គប្បីពិចារណានូវធម៌ដោយឧបាយនៃប្រាជ្ញា (ទើបអាច) បរិសុទ្ធក្នុងអរិយមគ្គនោះបាន យ៉ាងនេះឯង ។

**សារីបុត្តោ វ បញ្ញាយ សីលេន ឧបសមេន ច**
**យោបិ បារគតោ ភិក្ខុ ឯតាវបរមោ សិយាតិ ។**

ព្រះសារីបុត្ត ទើបជាបុគ្គល (ប្រសើរ) ដោយបញ្ញាផង ដោយសីលផង ដោយការស្ងប់រម្ងាប់ផង ទោះជាភិក្ខុណា បានដល់នូវត្រើយគឺព្រះនិព្វាន (ភិក្ខុនោះ) ក៏មានគុណអស់ត្រឹមប៉ុណ្ណោះឯង[១] ។

អនាថបិណ្ឌិកទេវបុត្ត បានពោលគាថានេះ លុះពោលដូច្នេះហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយ ក៏បាត់អំពីទីនោះទៅ ។

---

១. ប្រែតាមអនាថបិណ្ឌិកោវាទសូត្រ ,បិដកលេខ ២៨ , ទំព័រ ២៤៦ ។

# ២២-សិវសូត្រ

## បិដកលេខ ២៩ ទំព័រ ១៥០

ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រាកាលដែលរាត្រីបឋមយាមកន្លងទៅហើយ ទេវបុត្តឈ្មោះ សិវៈ មានរស្មីដ៏រុងរឿង ញុំាងវត្តជេតពនជុំវិញទាំងអស់ ឱ្យភ្លឺស្វាង ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយឋិតនៅក្នុងទីដ៏សមគួរ ។

លុះសិវទេវបុត្ត ឋិតនៅក្នុងទីដ៏សមគួរហើយ បានពោលគាថាទាំងនេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា :

**សព្ភិរេវ សមាសេថ សព្ភិ កុព្វេថ សន្ថវំ**
**សតំ សទ្ធម្មមញ្ញាយ សេយ្យោ ហោតិ ន បាបិយោ ។**

បុគ្គលគួរទាក់ទងជាមួយនឹងពួកសប្បុរសប៉ុណ្ណោះ គួរធ្វើសេចក្តីស្និទ្ធស្នាល ដោយពួកសប្បុរស ព្រោះដឹងច្បាស់នូវព្រះសទ្ធម្ម[១] របស់ពួកសប្បុរស រមែងបានសេចក្តីល្អ មិនមានអាក្រក់ឡើយ ។

១.សំដៅយកសីល ៥ ។





**សព្ភិរេវ សមាសេថ សព្ភិ កុព្វេថ សន្ថវំ**
**សតំ សទ្ធម្មមញ្ញាយ បញ្ញំ លភតិ នាញ្ញតោ ។**

បុគ្គលគួរទាក់ទងជាមួយនឹងពួកសប្បុរសប៉ុណ្ណោះ គួរធ្វើសេចក្តីស្និទ្ធស្នាលដោយពួកសប្បុរស បុគ្គលបានប្រាជ្ញា ព្រោះដឹងច្បាស់នូវព្រះសទ្ធម្ម របស់ពួកសប្បុរស មិនមែនបានអំពីទីដទៃឡើយ ។

**សព្ភិរេវ សមាសេថ សព្ភិ កុព្វេថ សន្ថវំ**
**សតំ សទ្ធម្មមញ្ញាយ សោកមជ្ឈេ ន សោចតិ ។**

បុគ្គលគួរទាក់ទងជាមួយនឹងពួកសប្បុរសប៉ុណ្ណោះ គួរធ្វើសេចក្តីស្និទ្ធស្នាល ដោយពួកសប្បុរស បុគ្គល បានដឹងព្រះសទ្ធម្ម របស់ពួកសប្បុរសហើយ រមែងមិនសោកសៅ ក្នុងកណ្តាលពួកជនអ្នកសោកសៅឡើយ ។

**សព្ភិរេវ សមាសេថ សព្ភិ កុព្វេថ សន្ថវំ**
**សតំ សទ្ធម្មមញ្ញាយ ញាតិមជ្ឈេ វិរោចតិ ។**

បុគ្គលគួរទាក់ទងជាមួយនឹងពួកសប្បុរសប៉ុណ្ណោះ គួរធ្វើសេចក្តីស្និទ្ធស្នាល ដោយពួកសប្បុរស បុគ្គល បានដឹងព្រះសទ្ធម្ម

របស់ពួកសប្បុរសហើយ រមែងរុងរឿងក្នុងកណ្តាលពួកញាតិ ។

**សព្ភិរេវ សមាសេថ   សព្ភិ កុព្វេថ សន្ថវំ**
**សតំ សទ្ធម្មមញ្ញាយ   សត្តា គច្ឆន្តិ សុគ្គតឹ ៗ**

បុគ្គលគួរទាក់ទងជាមួយនឹងពួកសប្បុរសប៉ុណ្ណោះ គួរធ្វើសេចក្តីស្និទ្ធស្នាល ដោយពួកសប្បុរស សត្វទាំងឡាយបានដឹងព្រះសទ្ធម្មរបស់ពួកសប្បុរសហើយ រមែងទៅកាន់សុគតិបាន ។

**សព្ភិរេវ សមាសេថ   សព្ភិ កុព្វេថ សន្ថវំ**
**សតំ សទ្ធម្មមញ្ញាយ   សត្តា តិដ្ឋន្តិ សាតតន្តិ ៗ**

បុគ្គលគួរទាក់ទងជាមួយនឹងពួកសប្បុរសប៉ុណ្ណោះ គួរធ្វើសេចក្តីស្និទ្ធស្នាល ដោយពួកសប្បុរស សត្វទាំងឡាយដឹងព្រះសទ្ធម្មរបស់ពួកសប្បុរសហើយ រមែងឋិតនៅ (ជាសុខ ) អស់កាលយូរ ។

លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកាតបទៅនឹងសិវទេវបុត្តវិញ ដោយគាថា ថា :



**សព្ភិរេវ សមាសេថ   សព្ភិ កុព្វេថ សន្ថវំ**
**សតំ សទ្ធម្មមញ្ញាយ   សព្វទុក្ខា បមុច្ចតីតិ ៗ**

បុគ្គលគួរទាក់ទងជាមួយនឹងពួកសប្បុរសប៉ុណ្ណោះ គួរធ្វើសេចក្តីស្និទ្ធស្នាល ដោយពួកសប្បុរស បុគ្គលដឹងព្រះសទ្ធម្ម របស់ពួកសប្បុរសហើយ រមែងរួចចាកទុក្ខទាំងអស់បាន ។

## **អត្តា ហិ អត្តនោ នាថោ**
### **ខ្លួនហ្នឹងឯងជាទីពឹងរបស់ខ្លួន**

យើងត្រូវកុំភ្លេចថា មានតែខ្លួនយើងប៉ុណ្ណោះ ដែលអាចរំលត់កិលេសឱ្យខ្លួនយើងបាន ដូច្នេះ ទើបយើងមិនត្រូវជាមនុស្សខ្ជិលច្រអូសឥតបានការនោះទេ។

សត្វនៅក្នុងអបាយភូមិ មិនអាចប្រារព្ធនូវ សេចក្តីព្យាយាមដើម្បីការត្រាស់ដឹងសច្ចធម៌បានឡើយ គោ ក្របី ដំរី សេះ សម្រាប់បម្រើក្នុងការងារ ប្រេតមានទុក្ខវេទនាព្រោះស្រេកឃ្លាន ឯចំណែកនរកខ្លាំងក្លាដោយសេចក្តីទុក្ខ... « ម្នាលភិក្ខុទាំងឡាយ នេះជាពេលវេលាដែលអ្នកទាំងឡាយត្រូវប្រារព្ធនូវសេចក្តីព្យាយាម » ។ ✍

## ២៣-ធម្មបទគាថា យមកវគ្គទី ១

### បិដកលេខ ៥២ ទំព័រ ២១

១-ប្រារព្ធព្រះចក្ខុបាលត្ថេរធ្លាប់ធ្វើបាបពីមុនមក

**មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា**
**មនសា ចេ បទុដ្ឋេន ភាសតិ វា ករោតិ វា**
**តតោ នំ ទុក្ខមន្វេតិ ចក្កំវ វហតោ បទំ ។**

ធម៌ទាំងឡាយ មានចិត្តជាប្រធាន មានចិត្តប្រសើរបំផុត (មានចិត្តជាធំ ) សម្រេចអំពីចិត្ត បើបុគ្គលមានចិត្តត្រូវទោស[១] ប្រទូស្តហើយ ពោលក្តី ធ្វើក្តី (រមែងជាទុច្ចរិត ) ព្រោះទុច្ចរិតទាំងនោះ ទុក្ខរមែងជាប់តាមបុគ្គលនោះទៅ ដូចកង់រទេះវិលតាមដានជើងគោដែលកំពុងអូសទៅ ។

២-ប្រារព្ធមដ្ឋកុណ្ឌលីជ្រះថ្លានឹងព្រះសម្មាសម្ពុទ្ធ

**មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា**
**មនសា ចេ បសន្នេន ភាសតិ វា ករោតិ វា**
**តតោ នំ សុខមន្វេតិ ឆាយាវ អនុបាយិនី ។**

---
១-ធម៌ជាទោសឬជាឧបក្កិលេសនៃចិត្តមានអភិជ្ឈាជាដើម ដែលចូលមកធ្វើចិត្តឱ្យវឹកវរ ។





ធម៌ទាំងឡាយ មានចិត្តជាប្រធាន មានចិត្តប្រសើរបំផុត សម្រេចអំពីចិត្ត បើបុគ្គលមានចិត្តជ្រះថ្លា[១] ហើយ ពោលក្តី ធ្វើក្តី ( រមែងជាសុចរិត ) ព្រោះសុចរិតទាំងនោះ សុខរមែងជាប់តាមបុគ្គលនោះទៅ ដូចស្រមោលអន្ទោលតាមប្រាណ ។

៣-ប្រារព្ធព្រះតិស្សត្ថេរជីដូនមួយនឹងព្រះអង្គ

**អក្កោច្ឆិ មំ អវធិ មំ អជិនិ មំ អហាសិ មេ**
**យេ ច តំ ឧបនយ្ហន្តិ វេរំ តេសំ ន សម្មតិ ។**
**អក្កោច្ឆិ មំ អវធិ មំ អជិនិ មំ អហាសិ មេ**
**យេ ច តំ នូបនយ្ហន្តិ វេរំ តេសូបសម្មតិ ។**

ជនទាំងឡាយណា ចងសេចក្តីក្រោធនោះទុកថា អ្នកឯណោះ បានជេរអញ អ្នកឯណោះបានវាយអញ អ្នកឯណោះបានផ្ចាញ់អញ អ្នកឯណោះបានលួចយកទ្រព្យរបស់អញ ទៅហើយ ( ដូច្នេះ ) ពៀររបស់ជនទាំងឡាយនោះ មិនរម្ងាប់ ឡើយ ។

ជនទាំងឡាយណា មិនចងសេចក្តីក្រោធនោះទុកថា អ្នកឯណោះ បានជេរអញ អ្នកឯណោះបានវាយអញ អ្នកឯណោះបានផ្ចាញ់អញ អ្នកឯណោះបានលួចយកទ្រព្យរបស់អញ ទៅហើយ (ដូច្នេះ) ពៀររបស់ជនទាំងឡាយនោះទើបរម្ងាប់បាន ។

---
១-ជ្រះថ្លាដោយគុណមានអនភិជ្ឈាជាដើម ។ អដ្ឋកថា ។

៤. ប្រារព្ធស្ត្រីពីរនាក់ដែលចងពៀរនឹងគ្នា

**ន ហិ វេរេន វេរានិ　　សម្មន្តីធ កុទាចនំ**
**អវេរេន ច សម្មន្តិ　　ឯស ធម្មោ សនន្តនោ ។**

តាំងពីកាលណាមក ក្នុងលោកនេះ ពៀរទាំងឡាយ មិនរម្ងាប់ដោយការចងពៀរឡើយ (ពិតមែន) ពៀរទាំងឡាយតែងរម្ងាប់ដោយការមិនចងពៀរ នេះជាបវេណីធម៌ ។

៥. ប្រារព្ធពួកភិក្ខុនៅក្រុងកោសម្ពីដែលបែកគ្នាជាពីរពួក

**បរេ ច ន វិជានន្តិ　　មយមេត្ថ យមាមសេ**
**យេ ច តត្ថ វិជានន្តិ　　តតោ សម្មន្តិ មេធគា ។**

ជនទាំងឡាយដទៃ (ក្រៅអំពីបណ្ឌិត) តែងមិនដឹងខ្លួនថា យើងទាំងឡាយនឹងវិនាសក្នុងកណ្ដាលនៃពួកនេះ ដូច្នេះឡើយ ចំណែកជនទាំងឡាយណាក្នុងពួកនេះ ដឹងខ្លួនថា យើងទាំងឡាយនឹងវិនាសក្នុងកណ្ដាលនៃពួកនេះ ដូច្នេះ ការឈ្លោះប្រកែកទាំងឡាយ រមែងរម្ងាប់អំពីជនទាំងឡាយនោះ ។

៦. ប្រារព្ធចុល្លកាលនិងមហាកាល

**សុភានុបស្សឹ វិហរន្តំ　　ឥន្ទ្រិយេសុ អសំវុតំ**
**ភោជនម្ហិ អមត្តញ្ញុំ　　កុសីតំ ហីនវីរិយំ**





**តំ វេ បសហតិ មារោ　　វាតោ រុក្ខំវ ទុព្វលំ ។**
**អសុភានុបស្សឹ វិហរន្តំ　　ឥន្ទ្រិយេសុ សុសំវុតំ**
**ភោជនម្ហិ ច មត្តញ្ញុំ　　សទ្ធំ អារទ្ធវីរិយំ**
**តំ វេ នប្បសហតិ មារោ　　វាតោ សេលំវ បព្វតំ ។**

បុគ្គលដែលយល់ឃើញនូវអារម្មណ៍ថាល្អ មិនសង្រួមក្នុងឥន្ទ្រិយទាំងឡាយ មិនដឹងប្រមាណក្នុងភោជន ខ្ជិលច្រអូស មានព្យាយាមធូរថយ កិលេសមារ រមែងគ្របសង្កត់បុគ្គលនោះឯង ដូចខ្យល់ដែលគ្របសង្កត់ដើមឈើទុព្វលដូច្នោះ ។

ឯបុគ្គល ដែលយល់ឃើញនូវអារម្មណ៍ថាមិនល្អ សង្រួមប្រពៃក្នុងឥន្ទ្រិយទាំងឡាយ ដឹងប្រមាណក្នុងភោជន មានសទ្ធាប្រារព្ធព្យាយាម កិលេសមាររមែងគ្របសង្កត់បុគ្គលនោះមិនបាន ដូចខ្យល់គ្របសង្កត់ភ្នំថ្មតាន់មិនបានដូច្នោះឯង ។

៧. ប្រារព្ធទេវទត្តបានសំពត់កាសាវៈ

**អនិក្កសាវោ កាសាវំ　　យោ វត្ថំ បរិទហេស្សតិ**
**អបេតោ ទមសច្ចេន　　ន សោ កាសាវមរហតិ ។**
**យោ ច វន្តកសាវស្ស　　សីលេសុ សុសមាហិតោ**
**ឧបេតោ ទមសច្ចេន　　ស វេ កាសាវមរហតិ ។**

អ្នកណា នៅមានទឹកចត់គឺរាគាទិក្កិលេស (ក្នុងសន្តាន) ជាអ្នកបោះបង់នូវទមៈ (ការទូន្មាននូវឥន្ទ្រិយ) និងសច្ចៈ ហើយស្លៀកដណ្តប់សំពត់កាសាវៈ អ្នកនោះ មិនគួរនឹងស្លៀកដណ្តប់សំពត់កាសាវៈឡើយ ។

លុះតែអ្នកណា មានទឹកចត់គឺរាគាទិក្កិលេស ខ្ជាក់ចោលអស់ហើយ ជាអ្នកមានចិត្តតម្កល់មាំ ក្នុងចតុប្បារិសុទ្ធិសីល ប្រកបដោយទមៈ (ការទូន្មាននូវឥន្ទ្រិយ) និងសច្ចៈ អ្នកនោះឯង ទើបគួរនឹងស្លៀកដណ្តប់សំពត់កាសាវៈបាន ។

៨.ប្រារព្ធសញ្ជ័យជាគ្រូដើមរបស់ព្រះអគ្គសាវ័កទាំងពីរ

**អសារេ សារមតិនោ សារេ ចាសារទស្សិនោ**
**តេ សារំ នាធិគច្ឆន្តិ មិច្ឆាសង្កប្បគោចរា ។**
**សារញ្ច សារតោ ញត្វា អសារញ្ច អសារតោ**
**តេ សារំ អធិគច្ឆន្តិ សម្មាសង្កប្បគោចរា ។**

ជនទាំងឡាយណា សំគាល់នូវធម៌ដែលមិនមានខ្លឹម ថាជាធម៌មានខ្លឹម និងយល់ឃើញក្នុងធម៌ដែលមានខ្លឹម ថាជាធម៌មិនមានខ្លឹមទៅវិញ ជាអ្នកមានតម្រិះខុសជាទីគោចរ ជនទាំង-ឡាយនោះ រមែងមិនបាននូវធម៌ដែលមានខ្លឹមឡើយ ។





ជនទាំងឡាយណា បានដឹងនូវធម៌ដែលមានខ្លឹម ថាជាធម៌មានខ្លឹមផង (ហើយដឹង) នូវធម៌ដែលគ្មានខ្លឹម ថាជាធម៌គ្មានខ្លឹមផង ជាអ្នកមានតម្រិះត្រូវជាទីគោចរ ជនទាំងឡាយនោះ រមែងបាននូវធម៌ដែលមាន ខ្លឹម ។

៩.ប្រារព្ធព្រះនន្ទត្ថេរ បុត្រព្រះនាងមហាបជាបតិគោតមី

**យថា អគារំ ទុច្ឆន្នំ វុដ្ឋី សមតិវិជ្ឈតិ**
**ឯវំ អភាវិតំ ចិត្តំ រាគោ សមតិវិជ្ឈតិ ។**
**យថា អគារំ សុឆន្នំ វុដ្ឋី ន សមតិវិជ្ឈតិ**
**ឯវំ សុភាវិតំ ចិត្តំ រាគោ ន សមតិវិជ្ឈតិ ។**

ផ្ទះដែលប្រក់ខ្ទីខ្ទាហើយ តំណក់ទឹកភ្លៀង រមែងលេចរហូតយ៉ាងណាមិញ ចិត្តដែលបុគ្គលមិនបានអប់រំទុកហើយ រាគៈរមែងចាក់ដោតយ៉ាងនោះឯង ។

ផ្ទះដែលប្រក់ល្អហើយ តំណក់ទឹកភ្លៀង រមែងមិនលេចរហូត យ៉ាងណាមិញ ចិត្តដែលបុគ្គលបានអប់រំទុកល្អហើយ រាគៈរមែងមិនចាក់ដោតបាន យ៉ាងនោះឯង ។

១០.ប្រារព្ធបុរសចុន្ទសូករិកៈ អ្នកមានប្រក្រតីសម្លាប់ជ្រូក

**ឥធ សោចតិ បេច្ច សោចតិ បាបការី ឧភយត្ថ សោចតិ**
**សោ សោចតិ សោ វិហញ្ញតិ ទិស្វា កម្មកិលិដ្ឋមត្តនោ ។**

បុគ្គលអ្នកធ្វើបាប តែងសោកស្តាយក្នុងលោកទាំងពីរ គឺសោកស្តាយក្នុងលោកនេះ ១ ក្នុងលោកខាងមុខ ១ បុគ្គលនោះរមែងសោកស្តាយ ក្តៅក្រហាយ ព្រោះឃើញអំពើសៅហ្មងរបស់ខ្លួន ។

១១.ប្រារព្ធធម្មិកឧបាសក ពេលស្លាប់មានទេវតាមកទទួល

**ឥធ មោទតិ បេច្ច មោទតិ កតបុញ្ញោ ឧភយត្ថ មោទតិ**
**សោ មោទតិ សោ បមោទតិ ទិស្វា កម្មវិសុទ្ធិមត្តនោ ។**

បុគ្គលអ្នកធ្វើបុណ្យទុក រមែងរីករាយក្នុងលោកទាំងពីរ គឺរីករាយក្នុងលោកនេះ ១ រីករាយក្នុងលោកខាងមុខ ១ បុគ្គលនោះ រមែងរីករាយស្រស់ស្រាយ ព្រោះឃើញអំពើបរិសុទ្ធរបស់ខ្លួន ។

១២.ប្រារព្ធទេវទត្តបំបែកសង្ឃ

**ឥធ តប្បតិ បេច្ច តប្បតិ បាបការី ឧភយត្ថ តប្បតិ**
**បាបំ មេ កតន្តិ តប្បតិ ភិយ្យោ តប្បតិ ទុគ្គតឹ គតោ ។**





បុគ្គលអ្នកធ្វើអំពើបាប តែងក្តៅក្រហាយក្នុងលោកទាំងពីរ គឺក្តៅក្រហាយក្នុងលោកនេះ ១ ក្តៅក្រហាយក្នុងលោកខាងមុខ ១ បុគ្គលនោះ រមែងក្តៅក្រហាយដោយឃើញថា បាបអញបានធ្វើហើយ លុះធ្វើមរណកាលទៅកាន់ទុគ្គតិ ក៏រឹងរឹតតែក្តៅក្រហាយដ៏ក្រៃលែង ។

១៣.ប្រារព្ធនាងសុមនាទេវី កូនស្រីពៅរបស់អនាថបិណ្ឌិកសេដ្ឋី

**ឥធ នន្ទតិ បេច្ច នន្ទតិ កតបុញ្ញោ ឧភយត្ថ នន្ទតិ**
**បុញ្ញំ មេ កតន្តិ នន្ទតិ ភិយ្យោ នន្ទតិ សុគតឹ គតោ ។**

បុគ្គលអ្នកធ្វើបុណ្យទុក រមែងត្រេកអរក្នុងលោកទាំងពីរ គឺត្រេកអរក្នុងលោកនេះ ១ ត្រេកអរក្នុងលោកខាងមុខ ១ បុគ្គលនោះ រមែងត្រេកអរដោយគិតថា បុណ្យអញបានធ្វើហើយ លុះធ្វើមរណកាលទៅកាន់សុគតិ ក៏រឹងរឹតតែត្រេកអរដ៏ក្រៃលែង ។

១៤.ប្រារព្ធភិក្ខុពីរអង្គដែលមានធុរៈផ្សេងគ្នា

**ពហុម្បិ ចេ សហិតំ ភាសមានោ**
**ន តក្ករោ ហោតិ នរោ បមត្តោ**
**គោបោវ គាវោ គណយំ បរេសំ**

ន ភាគវា សាមញ្ញស្ស ហោតិ ។
អប្បម្បិ ចេ សហិតំ ភាសមានោ
ធម្មស្ស ហោតិ អនុធម្មចារី
រាគញ្ច ទោសញ្ច បហាយ មោហំ
សម្មប្បជានោ សុវិមុត្តចិត្តោ
អនុបាទិយានោ ឥធ វា ហុរំ វា
ស ភាគវា សាមញ្ញស្ស ហោតិ ។

បើនរជនពោលពាក្យប្រកបដោយប្រយោជន៍ សូម្បីច្រើន តែជាអ្នកប្រមាទ មិនធ្វើតាមពាក្យនោះ រមែងជាអ្នកមិនមានចំណែកនៃសាមញ្ញផលឡើយ ដូចអ្នករក្សាគោ កាលរាប់គោប្រគល់ឱ្យអ្នកដទៃហើយ (ជាអ្នកមិនបានបរិភោគនូវបញ្ចគោរស ) ដូច្នោះឯង ។ បើនរជនពោលពាក្យប្រកបដោយប្រយោជន៍ សូម្បីបន្តិចបន្តួច តែជាអ្នកប្រព្រឹត្តនូវធម៌ដ៏សមគួរដល់ធម៌ បានលះបង់រាគៈ ទោសៈ និងមោហៈ ជាអ្នកដឹងនូវធម៌ ដែលគួរកំណត់តាមហេតុ មានចិត្តដកផុតអំពីសេចក្ដីសៅហ្មង មិនមានសេចក្ដីប្រកាន់មាំ ក្នុងលោកនេះ និងលោកខាងមុខ នរជននោះ រមែងជាអ្នកបានចំណែកនៃសាមញ្ញផល ។





## ២៤-ធម្មបទគាថា អប្បមាទវគ្គទី ២
### បិដកលេខ ៥២ ទំព័រ ២៥

១៥-ប្រារព្ធព្រះនាងសាមាវតី មានប្រក្រតីមិនប្រមាទ

អប្បមាទោ អមតំបទំ បមាទោ មច្ចុនោ បទំ
អប្បមត្តា ន មីយន្តិ យេ បមត្តា យថា មតា
ឯតំ វិសេសតោ ញត្វា អប្បមាទម្ហិ បណ្ឌិតា
អប្បមាទេ បមោទន្តិ អរិយានំ គោចរេ រតា
តេ ឈាយិនោ សាតតិកា និច្ចំ ទឡ្ហបរក្កមា
ផុសន្តិ ធីរា និព្វានំ យោគក្ខេមំ អនុត្តរំ ។

សេចក្ដីមិនប្រមាទ[១] ជាផ្លូវនៃសេចក្ដីមិនស្លាប់[២] សេចក្ដីប្រមាទជាផ្លូវនៃសេចក្ដីស្លាប់ ជនទាំងឡាយ ដែលមិនប្រមាទហើយ ឈ្មោះថា មិនស្លាប់ ជនទាំងឡាយដែលប្រមាទហើយ[៣] ទុកដូចជាមនុស្សស្លាប់ទៅហើយ ។ ពួកបណ្ឌិត បានជ្រាបនូវដំណើរនេះ ដោយប្លែកគ្នា ( ទើបឋិតនៅ ) ក្នុងសេចក្ដីមិនប្រមាទ

១-បានដល់ការប្រុងប្រយ័ត្ន ពាក្យនេះជាឈ្មោះស្មារតីដែលបានតាំងប្រុងជានិច្ច ។ ២-ពាក្យថាមិនស្លាប់នេះជាឈ្មោះព្រះនិព្វាន ព្រោះព្រះនិព្វានមិនមានចាស់ មិនមានស្លាប់ ។ ៣-បានដល់ការមិនប្រុងប្រយ័ត្ន ពាក្យនេះជាឈ្មោះនៃការលះបង់ស្មារតី ។

វិករាយ ក្នុងសេចក្ដីមិនប្រមាទ បណ្ឌិតទាំងនោះ ជាអ្នកត្រេកអរ ក្នុងធម៌ជាទីគោចរ[១] នៃព្រះអរិយបុគ្គលទាំងឡាយ ។ បណ្ឌិតអ្នកមិនប្រមាទទាំងនោះ មានការពិនិត្យជាប្រក្រតី មានព្យាយាមជាប់តគ្នា មានសេចក្ដីប្រឹងប្រែងមាំមួនជានិច្ច ជាអ្នកមានប្រាជ្ញា តែងពាល់ត្រូវនូវព្រះនិព្វានជាទីក្សេមក្សាន្តចាកយោគៈ ជាធម្មគុណដ៏ប្រសើរបំផុត ។

១៦_ប្រារព្ធកុម្ភឃោសកសេដ្ឋី មានប្រក្រតីមិនប្រមាទផងដែរ

**ឧដ្ឋានវតោ សតីមតោ សុចិកម្មស្ស និសម្មការិនោ**
**សញ្ញតស្ស ច ធម្មជីវិនោ អប្បមត្តស្ស យសោភិវឌ្ឍតិ ៕**

យស[២] តែងចម្រើនយ៉ាងក្រៃលែង ដល់បុគ្គលអ្នកមានសេចក្ដីប្រឹងប្រែង មានស្មារតី មានការងារស្អាត (ឥតទោស) ជាអ្នកពិចារណា រួចហើយទើបធ្វើ ជាអ្នកសង្រួម រស់នៅដោយធម៌ មិនមានសេចក្ដីប្រមាទ ។

១៧_ប្រារព្ធព្រះចូឡបន្ថកត្ថេរ បាននូវទីពឹង

**ឧដ្ឋានេនប្បមាទេន សញ្ញមេន ទមេន ច**
**ទីបំ កយិរាថ មេធាវី យំ ឱឃោ នាភិកីរតិ ៕**

១_ពោធិបក្ខិយធម៌ ៣៧ និងលោកុត្តរធម៌ ៩ ហៅថាទីគោចរនៃព្រះអរិយៈ ។ ២_ភាពជាធំ , ភោគសម្បត្តិ , សេចក្ដីរាប់អាន , កិត្តិសព្ទដ៏ពីរោះ គុណធម៌ទាំងនេះហៅថា យស ។





អ្នកប្រាជ្ញ គប្បីសាងនូវកោះ គឺអរហត្តផល ជាកោះដែលជំនន់គឺកិលេសជន់ពន្លិចមិនបាន ដោយសេចក្ដីប្រឹងប្រែងផង ដោយសេចក្ដីមិនប្រមាទផង ដោយការសង្រួមក្នុងចតុប្បារិសុទ្ធិសីលផង ដោយទមៈគឺការទូន្មានឥន្ទ្រិយផង។

១៨_ប្រារព្ធល្បែងលេងនៃជនពាល ប្រកបដោយសេចក្ដីប្រមាទ

**បមាទមនុយុញ្ជន្តិ ពាលា ទុម្មេធិនោ ជនា**
**អប្បមាទញ្ច មេធាវី ធនំ សេដ្ឋំវ រក្ខតិ ៕**
**មា បមាទមនុយុញ្ជេថ មា កាមរតិសន្ថវំ**
**អប្បមត្តោ ហិ ឈាយន្តោ បប្បោតិ វិបុលំ សុខំ ៕**

ពួកជនពាលអប្បឥតប្រាជ្ញា តែងប្រកបរឿយៗ នូវសេចក្ដីប្រមាទ ចំណែកអ្នកប្រាជ្ញ រមែងរក្សាទុកនូវសេចក្ដីមិនប្រមាទ ដូចទ្រព្យយ៉ាងប្រសើរ ។

អ្នកទាំងឡាយ ចូរកុំប្រកបរឿយៗនូវសេចក្ដីប្រមាទ ចូរកុំប្រកបរឿយៗ នូវសេចក្ដីវិករាយ ត្រេកអរក្នុងកាមឡើយ ដ្បិតបុគ្គលអ្នកមិនប្រមាទ ខំសង្កេតពិនិត្យ រមែងបាន សេចក្ដីសុខដ៏ទូលាយ ។

១៩-ប្រារព្ធព្រះមហាកស្សបត្ថេរ ពិចារណាមើលសត្វលោក

**បមាទំ អប្បមាទេន យទា នុទតិ បណ្ឌិតោ**
**បញ្ញាបាសាទមារុយ្ហ អសោកោ សោកិនឹ បជំ**
**បព្វតដ្ឋោវ ភុម្មដ្ឋេ ធីរោ ពាលេ អវេក្ខតិ ។**

កាលណាបណ្ឌិត បន្ទោបង់នូវសេចក្តីប្រមាទ ដោយសេចក្តីមិនប្រមាទ កាលណោះ លោកនឹងឡើងកាន់ប្រាសាទគឺបញ្ញា ជាបុគ្គលមិនសោក រមែងឃើញពួកសត្វដែលមានសោក ។ ធីរជនតែងពិចារណា ឃើញពួកជនពាល ដូចបុគ្គលដែលឈរលើកំពូលភ្នំ ហើយក្រឡេកមើលពួកជនដែលឋិតនៅលើផែនដី ដូច្នោះឯង ។

២០-ប្រារព្ធភិក្ខុពីរអង្គដែលមានបដិបទាផ្សេងគ្នា

**អប្បមត្តោ បមត្តេសុ សុត្តេសុ ពហុជាគរោ**
**អពលស្សំវ សីឃស្សោ ហិត្វា យាតិ សុមេធសោ ។**

បណ្ឌិតមានប្រាជ្ញាមោះមុត កាលពួកបុគ្គលកំពុងប្រមាទ លោកមិនប្រមាទ កាលពួកបុគ្គលកំពុងដេកលក់ លោកភ្ញាក់រឭកច្រើន លោករមែងលះបង់ចោលនូវបុគ្គលបែបនោះ ដូចសេះដែលរត់លឿន បានទៅចោលសេះដែលមានកម្លាំងទន់ទាប ដូច្នោះឯង។



២១-ប្រារព្ធសក្កទេវរាជដែលពីជាតិមុនជាមឃមាណព

**អប្បមាទេន មឃវា ទេវានំ សេដ្ឋតំ គតោ**
**អប្បមាទំ បសំសន្តិ បមាទោ គរហិតោ សទា ។**

មឃវា គឺព្រះឥន្ទ្រ បានដល់នូវភាពជាបុគ្គលប្រសើរបំផុតជាងទេវតា ទាំងឡាយ ព្រោះតែសេចក្តីមិនប្រមាទ អ្នកប្រាជ្ញទាំងឡាយ តែងសរសើរនូវសេចក្តីមិនប្រមាទ ហើយត្មះតិះដៀលនូវសេចក្តីប្រមាទសព្វៗ កាល ។

២២-ប្រារព្ធភិក្ខុមួយអង្គដែលមិនប្រមាទ

**អប្បមាទរតោ ភិក្ខុ បមាទេ ភយទស្សិ វា**
**សញ្ញោជនំ អណុំ ថូលំ ឌហំ អគ្គីវ គច្ឆតិ ។**

ភិក្ខុអ្នកត្រេកអរ ក្នុងសេចក្តីមិនប្រមាទ ឬឃើញភ័យ ក្នុងសេចក្តីប្រមាទ តែងដុតចោលនូវសំយោជនៈ ទាំងតូច ទាំងធំ ដូចភ្លើងឆេះ (កម្ទេចនូវព្រៃ ទាំងព្រៃតូច ទាំងព្រៃធំ) ដូច្នោះឯង ។

២៣-ប្រារព្ធព្រះតិស្សត្ថេរ មានសន្តោសក្នុងបិណ្ឌបាត

**អប្បមាទរតោ ភិក្ខុ បមាទេ ភយទស្សិ វា**
**អភព្វោ បរិហានាយ និព្វានស្សេវ សន្តិកេ ។**

ភិក្ខុអ្នកត្រេកអរ ក្នុងសេចក្ដីមិនប្រមាទ ឬឃើញភ័យ ក្នុងសេចក្ដីប្រមាទ ជាអ្នកមិនគួរនឹងសាបសូន្យចាកនូវគុណធម៌ឡើយ ឈ្មោះថា ឋិតនៅក្នុងទីជិតនៃព្រះនិព្វាន ។

## អក្កោធេន ជិនេ កោធំ

### គប្បីឈ្នះមនុស្សក្រោធដោយការមិនក្រោធ

យើងត្រូវតែសប្បាយចិត្ត នៅត្រង់ដែលថា យើងអាចឈ្នះសេចក្ដីក្រោធរបស់យើងបាន ដោយយើងមិនក្រោធហ្នឹងឯង ។

បើយើងយកឈ្នះខ្លួនឯងបានហើយ អ្នកដទៃមិនមែនជាសត្រូវរបស់យើងទេ អ្វីៗទាំងអស់សុទ្ធតែស្រស់បំព្រង ញញឹមមករកយើងជានិច្ច ។

យើងត្រូវព្យាយាមគ្រប់គ្រងនូវសេចក្ដីក្រោធ បើមិនដូច្នោះទេ នឹងត្រូវសេចក្ដីក្រោធវាចូលមក គ្រប់គ្រងលើយើងជាពិតប្រាកដ ពុំខានឡើយ ។ ✍





## ២៥_ធម្មបទគាថា ចិត្តវគ្គទី ៣

### បិដកលេខ ៥២ ទំព័រ ២៨

២៤_ប្រារព្ធព្រះមេឃិយត្ថេរ មានអកុសលវិតក្កៈ

**ផន្ទនំ ចបលំ ចិត្តំ ទុរក្ខំ ទុន្និវារយំ**
**ឧជុំ ករោតិ មេធាវី ឧសុការោវ តេជនំ**
**វារិជោវ ថលេ ខិត្តោ ឱកមោកតឧព្ភតោ**
**បរិផន្ទតិទំ ចិត្តំ មារធេយ្យំ បហាតវេ ។**

អ្នកប្រាជ្ញតែងធ្វើចិត្តដែលញាប់ញ័រ ឃ្លេងឃ្លោង រក្សាបានដោយកម្រ ហាមឃាត់បានដោយលំបាក ឱ្យជាចិត្តត្រង់បាន ដូចអ្នកធ្វើព្រួញ ពត់ព្រួញឱ្យត្រង់ ។ ចិត្តនេះដែលបុគ្គលលើកឡើងចាកអាល័យគឺកាមគុណ ៥ បោះទៅក្នុងវិបស្សនាកម្មដ្ឋាន ដើម្បីលះបង់នូវវដ្តៈជាទីនៅនៃមារ រមែងញាប់ញ័រ ដូចត្រីដែលគេលើកឡើងចាកទីនៅគឺទឹក បោះទៅលើគោក ដូច្នោះឯង ។

២៥. ប្រារព្ធភិក្ខុមួយអង្គនៅមាតិកគ្រាម

**ទុន្និគ្គហស្ស លហុនោ យត្ថ កាមនិបាតិនោ**
**ចិត្តស្ស ទមថោ សាធុ ចិត្តំ ទន្តំ សុខាវហំ ។**

ការទូន្មានចិត្តដែលសង្កត់សង្កិន បានដោយលំបាក ជាធម្មជាតិរហ័ស មានប្រក្រតីធ្លាក់ចុះទៅតាមសេចក្តីប្រាថ្នា ក្នុងអារម្មណ៍ណាមួយ ( ការទូន្មានចិត្តដូច្នេះ ) រមែងជាគុណញុំាងប្រយោជន៍ឱ្យសម្រេច (ព្រោះថា ) ចិត្តដែលហ្វឹកហ្វឺនបានហើយ រមែងនាំមកនូវសេចក្តីសុខ ។

២៦. ប្រារព្ធភិក្ខុមួយអង្គដែលចង់សឹក

**សុទុទ្ទសំ សុនិបុណំ យត្ថ កាមនិបាតិនំ**
**ចិត្តំ រក្ខេថ មេធាវី ចិត្តំ គុត្តំ សុខាវហំ ។**

អ្នកមានប្រាជ្ញា គួររក្សាចិត្តដែលឃើញដោយកម្រក្រៃពេក ដែលល្អិតពេកណាស់ មានប្រក្រតីធ្លាក់ចុះទៅតាមសេចក្តីប្រាថ្នា ក្នុងអារម្មណ៍ណាមួយ (ព្រោះថា ) ចិត្តដែលគេរក្សាបានហើយ រមែងនាំមកនូវសេចក្តីសុខ ។



២៧. ប្រារព្ធព្រះសង្ឃរក្ខិតត្ថេរ ដែលគិតរាយមាយ

**ទូរង្គមំ ឯកចរំ អសរីរំ គុហាសយំ**
**យេ ចិត្តំ សញ្ញមេស្សន្តិ មោក្ខន្តិ មារពន្ធនា ។**

អ្នកទាំងឡាយណា នឹងសង្រួមចិត្តដែលទៅឆ្ងាយ ជាចិត្តត្រាច់ទៅតែឯង មិនមានសរីរៈ មានគុហាគឺមហាភូតរូប ៤ ជាទីអាស្រ័យនៅ អ្នកទាំងនោះឯង រមែងរួចចាកចំណងនៃមារ ។

២៨. ប្រារព្ធព្រះចិត្តហត្ថត្ថេរ បួសសឹក៧

**អនវដ្ឋិតចិត្តស្ស សទ្ធម្មំ អវិជានតោ**
**បរិប្លវប្បសាទស្ស បញ្ញា ន បរិបូរតិ ។**
**អនវស្សុតចិត្តស្ស អនន្វាហតចេតសោ**
**បុញ្ញបាបប្បហីនស្ស នត្ថិ ជាគរតោ ភយំ ។**

ប្រាជ្ញា រមែងមិនបរិបូណ៌ដល់បុគ្គលដែលមានចិត្តមិនខ្ជាប់-ខ្ជួន មិនដឹងច្បាស់នូវព្រះសទ្ធម្ម មានសេចក្តីជ្រះថ្លាអណ្តែតទៅ ។

ភ័យរមែងមិនមានដល់បុគ្គល អ្នកមានចិត្តមិនទទឹកដោយរាគៈ មានចិត្តដែលទោសខ្ទាំងខ្ទប់មិនបាន មានបុណ្យ និងបាបបានលះចោលហើយ ភ្ញាក់រឭកជានិច្ច ។

២៩. ប្រារព្ធពួកភិក្ខុអ្នកចម្រើនវិបស្សនា

**កុម្ភូបមំ កាយមិមំ វិទិត្វា**

**នគរូបមំ ចិត្តមិទំ ឋបេត្វា**

**យោធេថ មារំ បញ្ញាវុធេន**

**ជិតញ្ច រក្ខេ អនិវេសនោ សិយា ។**

បុគ្គលគប្បីដឹងច្បាស់នូវកាយនេះថា ដូចជាឆ្នាំង គប្បីបិទនូវចិត្តនេះឱ្យដូចជាបិទទ្វារនគរ គប្បីច្បាំងនូវមារដោយអាវុធ គឺបញ្ញា គប្បីរក្សាទុកនូវធម៌ ដែលខ្លួនឈ្នះហើយ មិនគប្បីជាអ្នកជំអក់នៅ ( ក្នុងធម៌នោះ ) ឡើយ ។

៣០. ប្រារព្ធព្រះបូតិគត្តតិស្សត្ថេរ កើតដំបៅពេញរាងកាយ

**អចិរំ វតយំ កាយោ  បឋវឹ អធិសេស្សតិ**

**ឆុឌ្ឌោ អបេតវិញ្ញាណោ  និរត្ថំវ កលិង្គរំ ។**

ឱហ្ន៎ មិនយូរប៉ុន្មានទេតើ កាយនេះ តែមានវិញ្ញាណទៅប្រាសហើយ គេនឹងយកទៅបោះបង់ចោល មុខជានឹងដេកស្តូកស្តឹងនៅលើផែនដី ដូចជាអង្កត់អុស រកប្រយោជន៍គ្មានឡើយ ។





៣១. ប្រារព្ធនាយគោបាល ឈ្មោះនន្ទៈ ត្រូវស្លាប់ដោយគេប្រហារ

**ទិសោ ទិសំ យន្តំ កយិរា  វេរី វា បន វេរិនំ**

**មិច្ឆាបណិហិតំ ចិត្តំ  បាបិយោ នំ តតោ ករេ ។**

ចោរក្រឡេកឃើញចោរផងគ្នា ឬក៏បុគ្គលមានពៀរក្រឡេកឃើញបុគ្គលមានពៀរផងគ្នា គប្បីធ្វើនូវសេចក្តីវិនាសណាមួយដល់គ្នា ឯចិត្តដែលបុគ្គលតាំងទុកខុសហើយ រមែងធ្វើបុគ្គលនោះ ឱ្យអាក្រក់ក្រៃលែងជាងសេចក្តីវិនាសនោះទៅទៀត ។

៣២. ប្រារព្ធសោរេយ្យត្ថេរ បានជាព្រះអរហន្ត

**ន តំ មាតា បិតា កយិរា អញ្ញេ វាបិ ច ញាតកា**

**សម្មាបណិហិតំ ចិត្តំ  សេយ្យសោ នំ តតោ ករេ ។**

មាតាបិតា មិនគប្បីធ្វើហេតុនោះបាន ឬជនទាំងឡាយដទៃជាញាតិមិនគប្បីធ្វើនូវហេតុនោះបាន ចំណែកខាងចិត្ត ដែលបុគ្គលតាំងទុកត្រូវហើយ រមែងធ្វើបុគ្គលនោះ ឱ្យប្រសើរជាងហេតុនោះបាន ។

# ២៦_ធម្មបទគាថា បុប្ផវគ្គទី ៤

## បិដកលេខ ៥២ ទំព័រ ៣០

៣៣_ប្រារព្ធភិក្ខុ ៥០០ អង្គ ខ្វល់ខ្វាយពីរឿងផែនដី

**កោ ឥមំ បឋវឹ វិជេស្សតិ យមលោកញ្ច ឥមំ សទេវកំ**
**កោ ធម្មបទំ សុទេសិតំ កុសលោ បុប្ផមិវ បចេស្សតិ ។**
**សេក្ខោ បឋវឹ វិជេស្សតិ យមលោកញ្ច ឥមំ សទេវកំ**
**សេក្ខោ ធម្មបទំ សុទេសិតំ កុសលោ បុប្ផមិវ បចេស្សតិ ។**

អ្នកណានឹងដឹងច្បាស់នូវផែនដី គឺអត្តភាពនេះ និងយមលោក គឺអបាយភូមិ ៤ និងមនុស្សលោកនេះ ព្រមទាំងទេវលោកបាន អ្នកណានឹងជ្រើសរើសនូវចំណែកនៃធម៌ ដែលព្រះតថាគតសម្តែងប្រពៃហើយ ដូចមាលាការដែលឈ្លាសវៃ ជ្រើសរើសនូវផ្កាដូច្នោះ ។

ព្រះសេក្ខបុគ្គល នឹងដឹងច្បាស់នូវផែនដីគឺអត្តភាពនេះ និងយមលោក គឺអបាយភូមិ ៤ និងមនុស្សលោកនេះ ព្រមទាំងទេវលោកបាន ព្រះសេក្ខបុគ្គល នឹងជ្រើសរើសនូវចំណែកនៃធម៌ ដែលព្រះតថាគតសម្តែងប្រពៃហើយ ដូចមាលាការ ដែលឈ្លាសវៃ ជ្រើសរើសនូវផ្កាដូច្នោះឯង ។

៣៤_ប្រារព្ធភិក្ខុមួយអង្គពិចារណាថ្ងៃបណ្តើរកូន

**ផេណូបមំ កាយមិមំ វិទិត្វា**
**មរីចិធម្មំ អភិសម្ពុធានោ**
**ឆេត្វាន មារស្ស បបុប្ផកានិ**
**អទស្សនំ មច្ចុរាជស្ស គច្ឆេ ។**

ភិក្ខុ កាលដឹងច្បាស់នូវកាយនេះថា ដូចជាដុំពពុះទឹក ដឹងច្បាស់នូវកាយនេះថាមានសភាពដូចជាថ្ងៃបណ្តើរកូន គប្បីកាត់នូវកម្រងផ្កាជារបស់មារគឺវដ្តៈ ៣ ទៅកាន់ស្ថានទីដែលមច្ចុរាជមើលមិនឃើញ ។

៣៥_ប្រារព្ធវិឌូឌភៈ និងបរិវារត្រូវស្លាប់ដោយទឹកជំនន់

**បុប្ផានិ ហេវ បចិនន្តំ ព្យាសត្តមនសំ នរំ**
**សុត្តំ គាមំ មហោឃោវ មច្ចុ អាទាយ គច្ឆតិ ។**

មច្ចុគឺសេចក្តីស្លាប់ តែងកៀរយកទៅនូវនរជន អ្នកមានចិត្តជាប់ជំពាក់ក្នុងអារម្មណ៍ផ្សេងៗ កំពុងជ្រើសរើសនូវផ្កាគឺកាមគុណ

៥ នោះឯង ដូចទឹកជំនន់ធំ ដែលកួចយកអ្នកស្រុកកំពុងដេកលក់ទៅ ដូច្នោះឯង ។

៣៦_ប្រារព្ធនាងបតិបូជិកា នាងមានអាយុខ្លីក្នុងឋានមនុស្ស

**បុប្ផានិ ហេវ បចិនន្តំ ព្យាសត្តមនសំ នរំ**
**អតិត្តំយេវ កាមេសុ អន្តកោ កុរុតេ វសំ ៕**

អ្នកធ្វើទីបំផុត (នៃជីវិត) គឺមច្ចុរាជ តែងក្រុងសត្វដែលមានចិត្តជាប់ជំពាក់ក្នុងអារម្មណ៍ផ្សេងៗ កំពុងជ្រើសរើសនូវផ្កាគឺកាមគុណ ៥ មិនឆ្អែតឆ្អន់ក្នុងកាមទាំងឡាយនោះឯង ឱ្យនៅក្នុងអំណាចរបស់ខ្លួន ។

៣៧_ប្រារព្ធកោសិយសេដ្ឋីដែលកំណាញ់ ព្រះមោគ្គល្លាននិមន្តប្រោស

**យថាបិ ភមរោ បុប្ផំ វណ្ណគន្ធំ អហេឋយំ**
**បលេតិ រសមាទាយ ឯវំ គាមេ មុនី ចរេ ៕**

ភមរជាតិ មិនធ្វើផ្កាឈើដែលមានពណ៌និងក្លិនឱ្យវិនាសទេ ក្រេបយកតែរសហើយ ហើរទៅ យ៉ាងណាមិញ អ្នកប្រាជ្ញ គប្បីត្រាច់ទៅក្នុងស្រុក ក៏យ៉ាងនោះឯង ។





៣៨_ប្រារព្ធបាដិកាជីវក ពោលពាក្យចាក់ដោតដល់ឧបាសិកាម្នាក់

**ន បរេសំ វិលោមានិ ន បរេសំ កតាកតំ**
**អត្តនោ វ អវេក្ខេយ្យ កតានិ អកតានិ ច ៕**

ពាក្យចាក់ដោតទាំងឡាយរបស់ជនដទៃ បុគ្គលមិនគួរធ្វើទុកក្នុងចិត្តទេ កិច្ចដែលធ្វើហើយ និងមិនទាន់ធ្វើហើយរបស់ជនដទៃ (ដែលមិនមែនជាមុខការរបស់ខ្លួន) បុគ្គលមិនគួរពិនិត្យមើលទេ បុគ្គលគួរពិនិត្យពិចារណា តែកិច្ចការទាំងឡាយដែលធ្វើហើយ និងមិនទាន់ធ្វើហើយ របស់ខ្លួនតែម្យ៉ាង ។

៣៩_ប្រារព្ធឆត្តបាណិឧបាសក ជាព្រះអនាគាមី ទ្រទ្រង់នូវព្រះត្រៃបិដក

**យថាបិ រុចិរំ បុប្ផំ វណ្ណវន្តំ អគន្ធកំ**
**ឯវំ សុភាសិតា វាចា អផលា ហោតិ អកុព្វតោ ៕**
**យថាបិ រុចិរំ បុប្ផំ វណ្ណវន្តំ សគន្ធកំ**
**ឯវំ សុភាសិតា វាចា សផលា ហោតិ សុកុព្វតោ ៕**

ផ្កាឈើមានទ្រង់ទ្រាយល្អ មានពណ៌ (ល្អ) តែគ្មានក្លិន (ក្រអូប) (រមែងមិនក្រអូបដល់អ្នកដែលទ្រទ្រង់) ដូចម្ដេចមិញ វាចាជាសុភាសិត រមែងគ្មានផលដល់អ្នកដែលមិនធ្វើតាមដូច្នោះ។

ផ្កាឈើដែលមានទ្រង់ទ្រាយល្អ មានពណ៌ មានក្លិន (រមែងក្រអូបដល់អ្នកដែលទ្រទ្រង់ ) ដូចម្តេចមិញ វាចាជាសុភាសិតរមែងមានផលដល់អ្នកដែលធ្វើតាមដោយគោរព ដូច្នោះឯង ។

៤០.ប្រារព្ធឧបាសិកាវិសាខា សម្រេចក្នុងបុណ្យតាមប្រាថ្នា

**យថាបិ បុប្ផរាសិម្ហា　　កយិរា មាលាគុណេ ពហូ**
**ឯវំ ជាតេន មច្ចេន　　កត្តព្វំ កុសលំ ពហុំ ។**

មាលាការចេះធ្វើសំណុំនៃកម្រងផ្កាអំពីគំនរនៃផ្កា (ផ្សេងៗគ្នា ) ឱ្យច្រើនបាន យ៉ាងណាមិញ សត្វដែលកើតមកហើយតែងស្លាប់ទៅវិញជាធម្មតា គួរធ្វើកុសលឱ្យច្រើន យ៉ាងនោះឯង ។

៤១.ប្រារព្ធចំពោះបញ្ហានៃព្រះអានន្ទត្ថេរ ដែលទូលសួរអំពីក្លិន

**ន បុប្ផគន្ធោ បដិវាតមេតិ**
**ន ចន្ទនំ តគរមល្លិកា វា**
**សតញ្ច គន្ធោ បដិវាតមេតិ**
**សព្វា ទិសា សប្បុរិសោ បវាយតិ ។**
**ចន្ទនំ តគរំ វាបិ　　ឧប្បលំ អថ វស្សិកី**
**ឯតេសំ គន្ធជាតានំ　　សីលគន្ធោ អនុត្តរោ ។**





ក្លិនផ្កាឈើ ផ្សាយទៅច្រាសខ្យល់ មិនបាន ក្លិនខ្លឹមចន្ទន៍ក្តី ក្លិនខ្លឹមក្រស្នាក្តី ក្លិនផ្កាម្លិះរួតក្តី ក៏ផ្សាយទៅច្រាសខ្យល់ មិនបាន ចំណែកក្លិនរបស់សប្បុរសទាំងឡាយ រមែងផ្សាយទៅច្រាសខ្យល់បាន ព្រោះសប្បុរស រមែងផ្សាយទៅបានគ្រប់ទិស ។ ក្លិននៃសីលជាគុណជាតិប្រសើរបំផុតជាងគន្ធជាតិទាំងនេះគឺ ខ្លឹមចន្ទន៍ ខ្លឹមក្រស្នា ផ្កាឧប្បល ផ្កាម្លិះលា ។

៤២.ប្រារព្ធការថ្វាយបិណ្ឌបាតដល់ព្រះមហាកស្សបត្ថេរ

**អប្បមត្តោ អយំ គន្ធោ　　យ្វាយំ តគរចន្ទនី**
**យោ ច សីលវតំ គន្ធោ　　វាតិ ទេវេសុ ឧត្តមោ ។**

ក្លិនក្រស្នា និងក្លិនចន្ទន៍ណា ក្លិននេះ ក្រអូបមានប្រមាណតិចទេ ចំណែកក្លិននៃបុគ្គលមានសីលទាំងឡាយណា ក្លិននោះទើបក្រអូបលើសលប់ ផ្សាយទៅក្នុងទេវលោក និងមនុស្សលោកបាន ។

៤៣.ប្រារព្ធការបរិនិព្វានរបស់ព្រះគោធិកត្ថេរ

**តេសំ សម្បន្នសីលានំ　　អប្បមាទវិហារិនំ**
**សម្មទញ្ញា វិមុត្តានំ　　មារោ មគ្គំ ន វិន្ទតិ ។**

មារាធិរាជ (ទុកជាខំស្វែងរក ) ក៏មិនជួបនូវផ្លូវរបស់លោកអ្នកមានសីលបរិបូណ៌ មានប្រក្រតីនៅដោយសេចក្តីមិនប្រមាទ បានរួចផុតស្រឡះហើយ (ចាកធម៌ជាគ្រឿងសៅហ្មង ) ព្រោះដឹងច្បាស់តាមហេតុ។

៤៤_ប្រារព្ធគរហទិន្នៈសាវ័ករបស់និគ្រន្ថ មិនដឹងគុណព្រះសង្ឃ

**យថា សង្ការធានស្មឹំ ឧជ្ឈិតស្មឹំ មហាបថេ**
**បទុមំ តត្ថ ជាយេថ សុចិគន្ធំ មនោរមំ**
**ឯវំ សង្ការភូតេសុ អន្ធភូតេ បុថុជ្ជនេ**
**អតិរោចតិ បញ្ញាយ សម្មាសម្ពុទ្ធសាវកោ ៕**

ផ្កាឈូក ទុកជាកើតក្នុងគំនរសំរាម ដែលគេចាក់ចោលក្បែរផ្លូវធំនោះ ក៏គង់មានក្លិនក្រអូប ជាទីរីករាយនៃចិត្តបានដូចម្តេចមិញ សាវ័ករបស់ព្រះសម្មាសម្ពុទ្ធ ទោះបីកើតនៅក្នុងសមាគមនៃពួកជនដែលដូចជាគំនរសំរាមក៏ដោយ ក៏នៅតែរុងរឿងលើសបុថុជ្ជនទាំងឡាយដែលងងឹតសូន្យឈឹង ដោយបញ្ញា (របស់ខ្លួន ) ដូច្នោះឯង ។





## ២៧_ធម្មបទគាថា ពាលវគ្គទី ៥
### បិដកលេខ ៥២ ទំព័រ ៣៤

៤៥_ប្រារព្ធព្រះបាទបសេនទិកោសលចង់បានប្រពន្ធគេ ផ្ទំមិនលក់

**ទីឃា ជាគរតោ រត្តិ ទីឃំ សន្តស្ស យោជនំ**
**ទីឃោ ពាលាន សំសារោ សទ្ធម្មំ អវិជានតំ ៕**

រាត្រីវែង ចំពោះតែអ្នកភ្ញាក់រឭក ( អ្នកដេកមិនលក់ ) យោជន៍វែង ចំពោះតែអ្នកនឿយហត់ សង្សារវដ្តវែង ចំពោះតែបុគ្គលពាលមិនដឹងច្បាស់នូវព្រះសទ្ធម្ម ។

៤៦_ប្រារព្ធសទ្ធិវិហារិករបស់ព្រះមហាកស្សបត្ថេរ ក្រោធនឹងគ្រូ

**ចរញ្ចេ នាធិគច្ឆេយ្យ សេយ្យំ សទិសមត្តនោ**
**ឯកចរិយំ ទឡ្ហំ កយិរា នត្ថិ ពាលេ សហាយតា ៕**

បុគ្គល កាលស្វះស្វែងរកកល្យាណមិត្ត បើមិនបានមិត្តដ៏ប្រសើរជាងខ្លួន ឬមិត្តដែលស្មើនឹងខ្លួនទេ គប្បីប្រព្រឹត្តនៅតែម្នាក់ឯង ឱ្យខ្ជាប់ខ្ជួនវិញ ព្រោះថាសហាយតា[១] មិនមានក្នុងបុគ្គល

១_ចូឡសីល,មជ្ឈិមសីល,មហាសីល,កថាវត្ថុ១០ ,ធុតង្គគុណ១៣ ,វិបស្សនាគុណ ,មគ្គ ៤,ផល ៤ ,វិជ្ជា ៣,អភិញ្ញា ៦ ,ហៅថា សហាយតាគុណ ។

ពាលឡើយ ។

៤៧.ប្រារព្ធអានន្ទសេដ្ឋី ប្រដៅកូនឱ្យកំណាញ់

**បុត្តា មត្ថិ ធនមត្ថិ ឥតិ ពាលោ វិហញ្ញតិ**

**អត្តា ហិ អត្តនោ នត្ថិ កុតោ បុត្តា កុតោ ធនំ ។**

ជនពាលតែងព្រួយលំបាក ដោយសេចក្ដីសំគាល់ថា កូនទាំងឡាយរបស់អញមាន ទ្រព្យរបស់អញមាន តាមដែលពិត សូម្បីខ្លួនរបស់ខ្លួនក៏មិនមាន[១] ចំណង់បើកូនទាំងឡាយ នឹងរាប់ថាមានអំពីណាបាន ទ្រព្យនឹងរាប់ថា មានអំពីណាបាន ។

៤៨.ប្រារព្ធចោរពីរនាក់ជាសម្លាញ់នឹងគ្នា ចោរម្នាក់បានជាបណ្ឌិត

**យោ ពាលោ មញ្ញតី ពាល្យំ បណ្ឌិតោ វាបិ តេន សោ**

**ពាលោ ច បណ្ឌិតមានី ស វេ ពាលោតិ វុច្ចតិ ។**

អ្នកណា ជាមនុស្សពាល ហើយដឹងនូវភាពនៃខ្លួនថាជាពាល អ្នកនោះនឹងទៅជាបណ្ឌិតបានខ្លះ ដោយហេតុដែលដឹងខ្លួនថាជាពាលនោះឯង ឯអ្នកណា ជាមនុស្សពាល មានសេចក្ដីប្រកាន់ថា ខ្លួនជាបណ្ឌិត អ្នកនោះ ឈ្មោះថាជាមនុស្សពាលដោយពិត ។

១.ព្រោះមិនអាចនឹងការពារនូវសេចក្ដីទុក្ខបាន ។ អដ្ឋកថា ។





៤៩.ប្រារព្ធព្រះឧទាយីដែលមិនដឹងព្រះសទ្ធម្ម

**យាវជីវម្បិ ចេ ពាលោ បណ្ឌិតំ បយិរុបាសតិ**

**ន សោ ធម្មំ វិជានាតិ ទព្វី សូបរសំ យថា ។**

មនុស្សពាល បើចូលទៅអង្គុយជិតអ្នកប្រាជ្ញ សូម្បីអស់មួយជីវិត ក៏ឥតមានដឹងរសធម៌អ្វីឱ្យច្បាស់លាស់ឡើយ ដូចវែកដែលមិនដឹងរសសម្ល ។

៥០.ប្រារព្ធភិក្ខុ ៣០ អង្គ និមន្តមកពីដែនបាវាចូលគាល់ព្រះអង្គ

**មុហុត្តមបិ ចេ វិញ្ញូ បណ្ឌិតំ បយិរុបាសតិ**

**ខិប្បំ ធម្មំ វិជានាតិ ជិវ្ហា សូបរសំ យថា ។**

វិញ្ញូជន បើចូលទៅអង្គុយជិតអ្នកប្រាជ្ញ សូម្បីតែមួយរំពេច គេរមែងដឹងរសធម៌ដោយឆាប់រហ័ស ដូចអណ្ដាតដឹងនូវរសសម្ល។

៥១.ប្រារព្ធបុរសកើតឃ្លង់ ព្រោះមានបាបកម្មចាស់

**ចរន្តិ ពាលា ទុម្មេធា អមិត្តេនេវ អត្តនា**

**ករោន្តា បាបកំ កម្មំ យំ ហោតិ កដុកប្ផលំ ។**

ពួកជនពាលមិនមានប្រាជ្ញា មានខ្លួនដូចជាសត្រូវ តែងត្រាច់ទៅធ្វើនូវកម្មដ៏លាមក ដែលជាអំពើមានផលក្ដៅក្រហាយ ។

៥២-ប្រារព្ធអ្នកស្រែម្នាក់ មានគ្រោះព្រោះជាន់ដានចោរ

**ន តំ កម្មំ កតំ សាធុ   យំ កត្វា អនុតប្បតិ**
**យស្ស អស្សុមុខោ រោទំ   វិបាកំ បដិសេវតិ ។**

បុគ្គលធ្វើកម្មណាហើយ រមែងក្តៅក្រហាយជាខាងក្រោយ មានមុខទទឹកជោកដោយទឹកភ្នែក ស្រែកយំ ទទួលផលនៃកម្មណា កម្មនោះដែលគេធ្វើហើយ ឈ្មោះថាជាកម្មមិនល្អឡើយ ។

៥៣-ប្រារព្ធសុមនមាលាការ ថ្វាយផ្កាម្លិះដល់ព្រះអង្គ

**តញ្ច កម្មំ កតំ សាធុ   យំ កត្វា នានុតប្បតិ**
**យស្ស បតីតោ សុមនោ   វិបាកំ បដិសេវតិ ។**

បុគ្គលធ្វើកម្មណាហើយ រមែងមិនក្តៅក្រហាយតាមក្រោយ ដល់នូវសេចក្តីពេញចិត្ត មានចិត្តល្អ ទទួលផលនៃកម្មណា កម្មដែលគេធ្វើហើយនោះឯង ឈ្មោះថាជាកម្មល្អ ។

៥៤-ប្រារព្ធឧប្បលវណ្ណាថេរី ត្រូវនន្ទមាណពប្រទូស្ត (រំលោភ)

**មធុវា មញ្ញតី ពាលោ   យាវ បាបំ ន បច្ចតិ**
**យទា ច បច្ចតី បាបំ   អថ (ពាលោ)ទុក្ខំ និគច្ឆតិ ។**





បាបមិនទាន់ឱ្យផលត្រឹមណា ជនពាល តែងសំគាល់នូវបាបនោះថា ដូចទឹកឃ្មុំ លុះដល់កាលណាបាបឱ្យផល ជនពាលទើបប្រទះនូវសេចក្តីទុក្ខក្នុងកាលណោះ ។

៥៥-ប្រារព្ធជម្ពុកាជីវកម្នាក់ប្រព្រឹត្តវត្តបោកប្រាស់អ្នកស្រុក

**មាសេ មាសេ កុសគ្គេន   ពាលោ ភុញ្ជេថ ភោជនំ**
**ន សោ សង្ខាតធម្មានំ   កល្លំ អគ្ឃតិ សោឡសឹ ។**

ជនពាល ទុកជាបរិភោគភោជនដោយចុង[១] ស្បូវរាល់ៗខែ ជនពាលនោះ ក៏មិនដល់មួយចំណិតនៃចំណែកទី ១៦ (ដែលគេច្រៀក ១៦ លើក) របស់បុគ្គលទាំងឡាយ ដែលមានធម៌បានដឹង ឬមានធម៌បានពិចារណាហើយ (រាប់តាំងពីព្រះសោតាបន្នឡើងទៅ) នោះឡើយ ។

៥៦-ប្រារព្ធអហិប្រេត មានបុព្វកម្មដុតកុដិព្រះបច្ចេកពុទ្ធ

**ន ហិ បាបំ កតំ កម្មំ   សជ្ជុខីរំវ មុច្ចតិ**
**ឌហន្តំ ពាលមន្វេតិ   ភស្មាច្ឆន្នោវ បាវកោ ។**

កម្មលាមក ដែលជនពាលធ្វើហើយ មិនទាន់ឱ្យផលនោះក៏

---

១-បានសេចក្តីថា យកចុងស្បូវទៅចាក់ភោជន ហើយយកមកលិទ្ធនឹងចុងអណ្តាត ចំពោះគាថានេះ ព្រះសម្ពុទ្ធទ្រង់សម្តែងប្រារព្ធនឹងជម្ពុកាជីវក ដែលជាអ្នកប្រព្រឹត្តបរិភោគបែបនេះជាវត្ត ក្នុងពេលដែលមហាជននាំភោជនមកបូជា ។

ដូចជាទឹកដោះស្រស់ ដែលគេទើបតែរីតក្នុងខណៈនោះ មិនទាន់ប្រែក្លាយដូច្នោះ បាបកម្មនោះ រមែងតាមដុតបុគ្គលពាល ដូចរងើកភ្លើងដែលបិទបាំងទុកដោយផេះដូច្នោះឯង ។

៥៧.ប្រារព្ធសដ្ឋីកូដប្រេត មានបុព្វកម្មប្រហារព្រះបច្ចេកពុទ្ធ

**យាវទេវ អនត្ថាយ ញត្តំ ពាលស្ស ជាយតិ**
**ហន្តិ ពាលស្ស សុក្កំសំ មុទ្ធំ អស្ស វិបាតយំ ។**

ការចេះដឹង កើតឡើងដល់បុគ្គលពាល គ្រាន់តែដើម្បីសេចក្តីវិនាសប៉ុណ្ណោះ រមែងញ៉ាំងក្បាលគឺបញ្ញាឱ្យធ្លាក់ចុះ បំផ្លិច-បំផ្លាញ ចំណែកនៃធម៌ស គឺកុសលរបស់បុគ្គលពាលនោះឯង ។

៥៨.ប្រារព្ធព្រះសុធម្មត្ថេរ ដែលមិនល្អពីខាងដើម

**អសន្តំ ភាវមិច្ឆេយ្យ បុរេក្ខារញ្ច ភិក្ខុសុ**
**អាវាសេសុ ច ឥស្សរិយំ បូជា បរកុលេសុ ច**
**មមេវ កត មញ្ញន្តុ គិហិបព្វជិតា ឧភោ**
**មមេវ អតិវសា អស្សុ កិច្ចាកិច្ចេសុ កិស្មិចិ**
**ឥតិ ពាលស្ស សង្កប្បោ ឥស្សា មានោ ច វឌ្ឍតិ ។**

ភិក្ខុពាល រមែងប្រាថ្នានូវសេចក្តីសរសើរ ដែលមិនមាន (ក្នុងខ្លួន )ផង នូវភាពមានអ្នកហែហម គឺជាប្រមុខ ក្នុងពួកភិក្ខុផង នូវភាពជាឥស្សរៈក្នុងអាវាសទាំងឡាយផង នូវការបូជាទាំងឡាយក្នុងត្រកូលនៃជនទាំងឡាយដទៃផង ។ ភិក្ខុពាល តែងមានសេចក្តីត្រិះរិះថា គ្រហស្ថ និងបព្វជិតទាំង ២ ពួក ចូរសំគាល់នូវកិច្ចដែលមនុស្សដទៃធ្វើហើយថាជាកិច្ចរបស់អញវិញ អំណាចដ៏ក្រៃលែងរបស់អញ ចូរមានក្នុងកិច្ច តូច ធំ កិច្ចណាមួយក៏ដោយ (កាលបើយ៉ាងនេះ ) ឥស្សា និងមានះ រមែងចម្រើន (ដល់ភិក្ខុពាលនោះឯង ) ។

៥៩.ប្រារព្ធព្រះតិស្សត្ថេរ មានប្រក្រតីនៅក្នុងព្រៃ

**អញ្ញា ហិ លាភូបនិសា អញ្ញា និព្វានគាមិនី**
**ឯវមេតំ អភិញ្ញាយ ភិក្ខុ ពុទ្ធស្ស សាវកោ**
**សក្ការំ នាភិនន្ទេយ្យ វិវេកមនុព្រូហយេ ។**

បដិបទា អាស្រ័យនូវលាភផ្សេង បដិបទា ជាដំណើរទៅកាន់ព្រះនិព្វានផ្សេង ភិក្ខុជាសាវ័ករបស់ព្រះពុទ្ធដឹងច្បាស់នូវហេតុនោះយ៉ាងនេះហើយ មិនគួរត្រេកអរចំពោះសក្ការៈឡើយ គប្បីញ៉ាំងវិវេកឱ្យចម្រើនដោយលំដាប់ ។

## ២៨-ធម្មបទគាថា បណ្ឌិតវគ្គទី ៦

### បិដកលេខ ៥២ ទំព័រ ៣៧

៦០-ប្រារព្ធព្រះរាធត្ថេរ ជាបុគ្គលងាយប្រដៅ

**និធីនំវ បវត្តារំ យំ បស្សេ វជ្ជទស្សិនំ**
**និគ្គយ្ហវាទឹ មេធាវឹ តាទិសំ បណ្ឌិតំ ភជេ**
**តាទិសំ ភជមានស្ស សេយ្យោ ហោតិ ន បាបិយោ ។**

បុគ្គលគួរឃើញនូវអ្នកប្រាជ្ញណា ដែលជាអ្នកពោលសង្កត់សង្កិន ចង្អុលប្រាប់ទោស ថាដូចជាបុគ្គលអ្នកប្រាប់កំណប់ទ្រព្យឱ្យដូច្នោះ គួរគប់អ្នកប្រាជ្ញបែបនោះដែលជាបណ្ឌិត (ព្រោះថា )កាលបុគ្គលគប់អ្នកប្រាជ្ញបែបនោះហើយ រមែងមានសេចក្ដីគាប់ប្រសើរឥតមានទោសដ៏លាមកឡើយ ។

៦១-ប្រារព្ធភិក្ខុពីរអង្គ ជាបុគ្គលមិនងាយប្រដៅ

**ឱវទេយ្យានុសាសេយ្យ អសព្ភា ច និវារយេ**
**សតំ ហិ សោ បិយោ ហោតិ អសតំ ហោតិ អប្បិយោ ។**

បណ្ឌិតគួរទូន្មានប្រៀនប្រដៅ គួរហាមឃាត់នូវជនទាំង-ឡាយចាកអំពើអសប្បុរស បណ្ឌិតនោះ រមែងជាទីស្រឡាញ់របស់





សប្បុរសតែម្យ៉ាង មិនជាទីស្រឡាញ់នៃអសប្បុរសឡើយ ។

៦២-ប្រារព្ធព្រះឆន្នត្ថេរ ជេរព្រះអគ្គសាវ័កទាំងពីរអង្គ

**ន ភជេ បាបកេ មិត្តេ ន ភជេ បុរិសាធមេ**
**ភជេថ មិត្តេ កល្យាណេ ភជេថ បុរិសុត្តមេ ។**

បុគ្គលមិនគួរគប់មិត្តអាក្រក់ មិនគួរគប់បុរសថោកទាប គួរគប់តែមិត្តដែលល្អ គួរគប់តែបុរសជាន់ខ្ពស់ ។

៦៣-ប្រារព្ធព្រះមហាកប្បិនត្ថេរ ឧទានថា « សុខហ្ន៎ »

**ធម្មប្បីតិ សុខំ សេតិ វិប្បសន្នេន ចេតសា**
**អរិយប្បវេទិតេ ធម្មេ សទា រមតិ បណ្ឌិតោ ។**

បុគ្គលដែលមានសេចក្ដីឆ្អែតក្នុងធម៌ មានចិត្តជ្រះថ្លាហើយ រមែងដេកជាសុខ បណ្ឌិតរមែងត្រេកអរក្នុងធម៌ដែលព្រះអរិយៈប្រកាសទុកហើយ គ្រប់ពេល ។

៦៤-ប្រារព្ធបណ្ឌិតសាមណេរទូន្មានខ្លួនបានសម្រេច

**ឧទកញ្ហិ នយន្តិ នេត្តិកា**
**ឧសុការា នមយន្តិ តេជនំ**

ឧទកំ នយន្តិ នេត្តិកា
តេជនំ នមយន្តិ ឧសុការា
ទារុំ នមយន្តិ តច្ឆកា
អត្តានំ ទមយន្តិ បណ្ឌិតា ។

ធម្មតាអ្នកបង្ហូរទឹក តែងបង្ហូរទឹកទៅ អ្នកធ្វើព្រួញ តែងពត់ព្រួញ (ឱ្យត្រង់ ) អ្នកចាំងឈើ តែងចាំងឈើ ឯបណ្ឌិតទាំងឡាយ តែងទូន្មានខ្លួន (ដូច្នោះឯង ) ។

៦៥.ប្រារព្ធព្រះលកុណ្តកភទ្ទិយត្ថេរមិនក្រោធខឹង

សេលោ យថា ឯកឃនោ វាតេន ន សមីរតិ
ឯវំ និន្ទាបសំសាសុ ន សមិញ្ជន្តិ បណ្ឌិតា ។

ភ្នំថ្មតាន់ មិនកម្រើកព្រោះខ្យល់ ដូចម្តេចមិញ បណ្ឌិតទាំងឡាយ ក៏មិនរំភើបញាប់ញ័រ ព្រោះពាក្យតិះដៀល និងពាក្យសរសើរ (ជាដើម ) ដូច្នោះឯង ។

៦៦.ប្រារព្ធមាតារបស់នាងកាណាញ៉ាំងកូនឱ្យស្តាប់ធម៌

យថាបិ រហទោ គម្ភីរោ វិប្បសន្នោ អនាវិលោ
ឯវំ ធម្មានិ សុត្វាន វិប្បសីទន្តិ បណ្ឌិតា ។

អន្លង់ទឹកដែលជ្រៅ រមែងថ្លាមិនល្អក់យ៉ាងណា បណ្ឌិតទាំងឡាយ បានស្តាប់ធម៌ទេសនាហើយ រមែងជ្រះថ្លាស៊ប់សួនយ៉ាងនោះ ។





៦៧.ប្រារព្ធភិក្ខុ ៥០០ អង្គ ចាំវស្សានៅស្រុកវេរញ្ជា

សព្វត្ថ វេ សប្បុរិសា វជន្តិ
ន កាមកាមា លបយន្តិ សន្តោ
សុខេន ផុដ្ឋា អថ វា ទុខេន
ន ឧច្ចាវចំ បណ្ឌិតា ទស្សយន្តិ ។

ពួកសប្បុរស តែងលះ (ឆន្ទរាគ ) ក្នុងធម៌ទាំងពួង ពួកលោកអ្នកស្ងប់ រមែងមិនរអែរអ្វូវ ព្រោះសេចក្តីប្រាថ្នាក្នុងកាម ពួកបណ្ឌិត បើសេចក្តីសុខ ឬទុក្ខពាល់ត្រូវហើយ រមែងមិនសំដែងអាការឡើងចុះឡើយ ។

៦៨.ប្រារព្ធព្រះធម្មិកត្ថេរ តាំងនៅក្នុងធម៌ជាទីពឹង

ន អត្តហេតុ ន បរស្ស ហេតុ
ន បុត្តមិច្ឆេ ន ធនំ ន រដ្ឋំ
ន ឥច្ឆេយ្យ អធម្មេន សមិទ្ធិមត្តនោ
ស សីលវា បញ្ញវា ធម្មិកោ សិយា ។

បណ្ឌិតមិនគួរធ្វើអាក្រក់ ព្រោះហេតុនៃខ្លួន មិនគួរធ្វើអាក្រក់ ព្រោះហេតុនៃអ្នកដទៃ មិនគួរប្រាថ្នាកូន មិនគួរប្រាថ្នាទ្រព្យ មិនគួរប្រាថ្នារដ្ឋ មិនគួរប្រាថ្នាសេចក្តីសម្រេចដើម្បីខ្លួនដោយហេតុមិនមែនជាធម៌ឡើយ លោកគួរជាអ្នកមានសីល មាន

ប្រាជ្ញាប្រកបដោយធម៌ ។

៦៩-ប្រារព្ធការស្តាប់ធម៌របស់អ្នកក្រុងសាវត្ថី

**អប្បកា តេ មនុស្សេសុ យេ ជនា បារគាមិនោ**
**អថាយំ ឥតរា បជា តីរមេវានុធាវតិ ។**
**យេ ច ខោ សម្មទក្ខាតេ ធម្មេ ធម្មានុវត្តិនោ**
**តេ ជនា បារមេស្សន្តិ មច្ចុធេយ្យំ សុទុត្តរំ ។**

បណ្តាមនុស្សទាំងឡាយ ពួកជនណា ដែលឆ្លងដល់ត្រើយ គឺព្រះនិព្វាន ពួកជននោះ មានប្រមាណតិច ចំណែកពួកសត្វក្រៅពីនេះ រមែងស្ទុះទៅកាន់ត្រើយ (គឺសក្កាយទិដ្ឋិ) ។

ជនទាំងឡាយណា ប្រព្រឹត្តដ៏សមគួរតាមធម៌ ក្នុងធម៌ដែលតថាគតសម្តែងទុកហើយដោយប្រពៃ ជនទាំងនោះ នឹងឆ្លងនូវលំនៅនៃមច្ចុដែលមិនងាយនឹងឆ្លងបាន ហើយដល់នូវត្រើយ គឺព្រះនិព្វាន ។

៧០-ប្រារព្ធភិក្ខុអាគន្តុកៈ ៥០០ អង្គ មកគាល់ព្រះពុទ្ធ

**កណ្ហំ ធម្មំ វិប្បហាយ សុក្កំ ភាវេថ បណ្ឌិតោ**
**ឱកា អនោកមាគម្ម វិវេកេ យត្ថ ទូរមំ**
**តត្រាភិរតិមិច្ឆេយ្យ ហិត្វា កាមេ អកិញ្ចនោ**





**បរិយោទបេយ្យ អត្តានំ ចិត្តក្លេសេហិ បណ្ឌិតោ ។**
**យេសំ សម្ពោធិយង្គេសុ សម្មា ចិត្តំ សុភាវិតំ**
**អាទានប្បដិនិស្សគ្គេ អនុបាទាយ យេ រតា**
**ខីណាសវា ជុតិមន្តោ តេ លោកេ បរិនិព្វុតា ។**

បណ្ឌិតគួរលះបង់ធម៌ខ្មៅចេញ ញ៉ាំងធម៌ស ឱ្យចម្រើនឡើង (ដោយវិធី) ចេញចាកអាល័យគឺកាមគុណ ហើយឈមទៅរកព្រះនិព្វាន ជាធម៌មិនមានអាល័យ គប្បីលះបង់កាមទាំងឡាយចេញ ជាអ្នកមិនមានកង្វល់ ប្រាថ្នានូវសេចក្តីត្រេកអរ ក្នុងវិវេកដែលពួកសត្វត្រេកអរបានដោយក្រនោះ បណ្ឌិតគួរញ៉ាំងខ្លួនឱ្យផូរផង់ចាកគ្រឿងសៅហ្មងចិត្ត ។

ចិត្តដែលបណ្ឌិតទាំងឡាយណា បានអប់រំល្អហើយ ក្នុងអង្គនៃធម៌ដែលជាគ្រឿងត្រាស់ដឹងទាំងឡាយ ឬបណ្ឌិតទាំងឡាយណា មិនប្រកាន់មាំ ត្រេកអរតែក្នុងការលះនូវសេចក្តីប្រកាន់មាំ បណ្ឌិតទាំងឡាយនោះៗ រមែងជាអ្នកអស់អាសវៈ មានសេចក្តីរុងរឿង បរិនិព្វានក្នុងលោក ។

## ២៩_ធម្មបទគាថា អរហន្តវគ្គទី ៧

### បិដកលេខ ៥២ ទំព័រ ៤០

៧១_ប្រារព្ធបញ្ហារបស់ពេទ្យជីវក ទូលសួរព្រះអង្គអំពីអាពាធ

**គតទ្ធិនោ វិសោកស្ស    វិប្បមុត្តស្ស សព្វធិ**
**សព្វគន្ថប្បហីនស្ស    បរិឡាហោ ន វិជ្ជតិ ។**

សេចក្ដីក្ដៅក្រហាយ រមែងមិនមានដល់អ្នកដែលមានផ្លូវឆ្ងាយ បានទៅដល់ហើយ មិនមានសេចក្ដីសោក រួចស្រឡះចាកធម៌ទាំងពួង (មានខន្ធជាដើម ) មានកិលេសជាគ្រឿងចាក់ស្រែះទាំងពួងលះបង់ហើយ ។

៧២_ប្រារព្ធព្រះមហាកស្សបត្ថេរដូចរាជហង្ស

**ឧយ្យុញ្ជន្តិ សតីមន្តោ    ន និកេតេ រមន្តិ តេ**
**ហំសាវ បល្លលំ ហិត្វា    ឱកមោកំ ជហន្តិ តេ ។**

ព្រះខីណាស្រពទាំងឡាយ មានស្មារតី រមែងខ្វល់ខ្វាយ[១] លោកមិនត្រេកអរក្នុងទីនៅអាស្រ័យ លះបង់ចោលស្រឡះនូវ

១_ខ្វល់ខ្វាយក្នុងគុណដែលខ្លួនបានហើយ ឬក្នុងឈាននិងវិបស្សនា ដោយកិច្ច គឺរំពឹងចូលចេញ អធិដ្ឋាន ឬពិចារណាមិនមានសម្រាក ។ អដ្ឋកថា ។





អាល័យទាំងអស់ ដូចហង្សលះបង់ភក់ហើយទៅ ដូច្នោះឯង ។

៧៣_ប្រារព្ធព្រះពេឡដ្ឋសីសត្ថេរ មិនសន្សំកិលេស

**យេសំ សន្និច្ចយោ នត្ថិ    យេ បរិញ្ញាតភោជនា**
**សុញ្ញតោ អនិមិត្តោ ច    វិមោក្ខោ យេស គោចរោ**
**អាកាសេវ សកុន្តានំ    គតិ តេសំ ទុរន្នយា ។**

ពួកជនណា មិនមានសេចក្ដីសន្សំ ពួកជនណា កំណត់ដឹងភោជនហើយ ជនណា មានសុញ្ញតវិមោក្ខ អនិមិត្តវិមោក្ខ និង (អប្បណិហិតវិមោក្ខ ) ជាគោចរ គតិគឺដំណើររបស់ពួកជននោះ ៗ គេកម្រដឹងបាន ដូចដំណើរនៃពួកសត្វស្លាបឰដ៏អាកាស ដូច្នោះ ។

៧៤_ប្រារព្ធព្រះអនុរុទ្ធត្ថេរ មិនពោលពាក្យសូមអាហារអ្នកស្រុក

**យស្សាសវា បរិក្ខីណា    អាហារេ ច អនិស្សិតោ**
**សុញ្ញតោ អនិមិត្តោ ច    វិមោក្ខោ យស្ស គោចរោ**
**អាកាសេវ សកុន្តានំ    បទន្តស្ស ទុរន្នយំ ។**

ជនណា អស់អាសវៈហើយ ទាំងមិនអាស្រ័យ (តណ្ហា និងទិដ្ឋិ ) ក្នុងអាហារ ជនណា មានសុញ្ញតវិមោក្ខ អនិមិត្តវិមោក្ខ និង (អប្បណិហិតវិមោក្ខ )ជាគោចរ ដានជើងរបស់ជននោះ គេកម្រដឹងបាន ដូចដានជើងនៃពួកសត្វស្លាបឰដ៏អាកាស ដូច្នោះ ។

៧៥-ប្រារព្ធព្រះមហាកច្ចាយនត្ថេរដែលព្រះឥន្ទ្រជ្រះថ្លា

**យស្សិន្ទ្រិយានិ សមថង្គតានិ**

**អស្សា យថា សារថិនា សុទន្តា**

**បហីនមានស្ស អនាសវស្ស**

**ទេវាបិ តស្ស បិហយន្តិ តាទិនោ ។**

ឥន្ទ្រិយទាំងឡាយ របស់អ្នកណា ដល់នូវការស្ងប់រម្ងាប់ ដូច សេះដែលនាយសារថី ហ្វឹកហ្វឺនល្អហើយ សូម្បីទេវតាទាំងឡាយ ក៏ស្រឡាញ់អ្នកនោះឯង ដែលជាអ្នកមានមានះលះបង់ហើយ មិនមានអាសវៈ ជាបុគ្គលមានចិត្តនឹងធឹងមិនញាប់ញ័រ ។

៧៦-ប្រារព្ធព្រះសារីបុត្តមានចិត្តដូចផែនដី

**បឋវីសមោ នោ វិរុជ្ឈតិ**

**ឥន្ទខីលូបមោ តាទិ សុព្វតោ**

**រហទោវ អបេតកទ្ទមោ**

**សំសារា ន ភវន្តិ តាទិនោ ។**

ភិក្ខុមានចិត្តដូចផែនដី មិនក្រោធ មានវត្តល្អ មានចិត្តនឹង-ធឹងដូចសសរគោល មានចិត្តថ្លា ដូចអន្លង់ប្រាសចាកភក់ សង្សារទាំងឡាយរបស់ភិក្ខុបែបនោះ រមែងមិនមាន ។





៧៧-ប្រារព្ធសាមណេរបែកព្រះនេត្រ ហើយមានចិត្តស្ងប់រម្ងាប់

**សន្តំ តស្ស មនំ ហោតិ សន្តា វាចា ច កម្ម ច**

**សម្មទញ្ញា វិមុត្តស្ស ឧបសន្តស្ស តាទិនោ ។**

ចិត្តស្ងប់ វាចាស្ងប់ និងកាយកម្មស្ងប់ រមែងមានដល់លោកអ្នកដែលមានចិត្តផុតស្រឡះហើយ ព្រោះដឹងដោយប្រពៃ ជាអ្នកស្ងប់រម្ងាប់មានគោលជំហររឹងប៉ឹង ។

៧៨-ប្រារព្ធព្រះសារីបុត្ត ក្នុងរឿងមិនជឿអ្នកដទៃ

**អស្សទ្ធោ អកតញ្ញូ ច សន្ធិច្ឆេទោ ច យោ នរោ**

**ហតាវកាសោ វន្តាសោ ស វេ ឧត្តមបោរិសោ ។**

នរជនណា មិនជឿអ្នកដទៃផង ដឹងព្រះនិព្វានដែលបច្ច័យធ្វើមិនបានផង កាត់នូវគ្រឿងតគីវដ្តៈផង មានឱកាស (គឺការកើតក្នុងភពថ្មី ) បានកម្ចាត់បង់ហើយផង មានសេចក្តីប្រាថ្នាខ្ជាក់ចោលហើយផង នរជននោះ ជាឧត្តមបុរស ។

៧៩-ប្រារព្ធព្រះរេវតត្ថេរ មានប្រក្រតីនៅក្នុងព្រៃ

**គាមេ វា យទិ វា រញ្ញេ និន្នេ វា យទិ វា ថលេ**

**យត្ថ អរហន្តោ វិហរន្តិ តំ ភូមិរាមណេយ្យកំ ។**

ព្រះអរហន្តទាំងឡាយ នៅក្នុងទីណា ទោះជាស្រុកក្តី ព្រៃក្តី ទីទាបក្តី ទីទួលក្តី ទីនោះៗឯង គឺជាភូមិឋានមនោរម្យ ។

៨០-ប្រារព្ធស្ត្រីម្នាក់ដែលធ្វើឱ្យភិក្ខុនៅក្នុងព្រៃមានក្តីសង្វេគ

**រមណីយានិ អរញ្ញានិ យត្ថ ន រមតី ជនោ**

**វីតរាគា រមេស្សន្តិ ន តេ កាមគវេសិនោ ។**

ជន (អ្នកស្វែងរកកាម) រមែងមិនត្រេកអរក្នុងព្រៃដែលគួររីករាយទេ ព្រះខីណាស្រពដែលមានរាគៈទៅប្រាសហើយ ទើបត្រេកអរក្នុងព្រៃនោះ ព្រោះលោកជាអ្នកមិនស្វែងរកកាម ។

## អ្នកមិនប្រមាទ បីដូចដួងចន្ទរះបំភ្លឺលោក

**យោ ច បុព្វេ បមជ្ជិត្វា បច្ឆា សោ នប្បមជ្ជតិ**

**សោមំ លោកំ បភាសេតិ អព្ភា មុត្តោវ ចន្ទិមា។**

អ្នកណាប្រមាទហើយកាលពីពេលមុន លុះដល់ក្រោយមកជាអ្នកមិនប្រមាទ អ្នកនោះរមែងញ៉ាំងនូវលោកនេះឱ្យភ្លឺស្វាង ដូចជាព្រះចន្ទចេញផុតស្រឡះចាកពពក ដូច្នោះឯង ។

ព្រះអង្គទ្រង់គង់ប្រថាប់នៅជេតវនារាម

ទ្រង់ប្រារព្ធព្រះសម្មជ្ជនត្ថេរស្តាប់តាមឱវាទរបស់ព្រះរេវតៈ





# ៣០-ធម្មបទគាថា សហស្សវគ្គទី ៨

## បិដកលេខ ៥២ ទំព័រ ៤៣

៨១-ប្រារព្ធពេជ្ឈឃាតពុកមាត់ក្រហម ស្តាប់ព្រះធម៌

**សហស្សមបិ ចេ វាចា អនត្ថបទសញ្ហិតា**

**ឯកំ អត្ថបទំ សេយ្យោ យំ សុត្វា ឧបសម្មតិ ។**

បើវាចា សូម្បី ១ ពាន់ម៉ាត់ ជាវាចាប្រកបដោយបទឥតប្រយោជន៍ (វាចានោះ ពុំប្រសើរឡើយ )បទមានប្រយោជន៍ណា សូម្បីតែ ១ បទដែលបុគ្គលស្តាប់ហើយស្ងប់រម្ងាប់បាន (បទនោះ) ឈ្មោះថា ប្រសើរជាង ។

៨២-ប្រារព្ធពាហិយៈ ស្លៀកសំបកឈើ ស្តាប់ព្រះធម៌

**សហស្សមបិ ចេ គាថា អនត្ថបទសញ្ហិតា**

**ឯកំ គាថាបទំ សេយ្យោ យំ សុត្វា ឧបសម្មតិ ។**

បើគាថា សូម្បី ១ ពាន់ ជាគាថា ប្រកបដោយបទឥតប្រយោជន៍ ( គាថានោះ ពុំប្រសើរឡើយ ) បទនៃគាថាណា សូម្បីតែ ១ បទដែលបុគ្គលស្តាប់ហើយស្ងប់រម្ងាប់បាន (បទនៃគាថា

នោះ ) ឈ្មោះថា ប្រសើរជាង ។

៨៣_ប្រារព្ធនាងកុណ្ឌលកេសី ស្តាប់ព្រះធម៌

**យោ ច គាថា សតំ ភាសេ អនត្ថបទសញ្ហិតា**
**ឯកំ ធម្មបទំ សេយ្យោ យំ សុត្វា ឧបសម្មតិ ។**
**យោ សហស្សំ សហស្សេន សង្គាមេ មានុសេ ជិនេ**
**ឯកញ្ច ជេយ្យមត្តានំ ស វេ សង្គាមជុត្តមោ ។**

អ្នកណា គប្បីពោលគាថាមួយរយ ជាគាថា ប្រកបដោយបទឥតប្រយោជន៍ (គាថាដែលអ្នកនោះពោលហើយនោះពុំប្រសើរឡើយ )បទនៃធម៌ណា សូម្បីតែ ១ បទដែលបុគ្គលស្តាប់ហើយស្ងប់រម្ងាប់បាន (ធម្មបទនោះ ) ឈ្មោះថា ប្រសើរជាង ។

អ្នកណា គប្បីឈ្នះពួកមនុស្សក្នុងសង្គ្រាមអស់មួយពាន់ៗដង (គឺមួយលាន ) (អ្នកនោះ មិនឈ្មោះថាជាអ្នកឈ្នះដ៏ប្រសើរឡើយ ) ចំណែកអ្នកណាឈ្នះខ្លួនឯងម្នាក់បាន អ្នកនោះឈ្មោះថាជាមនុស្សខ្ពង់ខ្ពស់ គឺជាអ្នកច្បាំងដ៏ពូកែក្រៃលែងក្នុងសង្គ្រាម ។

៨៤_ប្រារព្ធអនត្ថបុច្ឆកព្រាហ្មណ៍ អ្នកលេងល្បែងស៊ីសង

**អត្តា ហវេ ជិតំ សេយ្យោ យា ចាយំ ឥតរា បជា**
**អត្តទន្តស្ស បោសស្ស និច្ចំ សញ្ញតចារិនោ**





**នេវ ទេវោ ន គន្ធព្វោ ន មារោ សហ ព្រហ្មុនា**
**ជិតំ អបជិតំ កយិរា តថារូបស្ស ជន្តុនោ ។**

ខ្លួនហ្នឹងឯងដែលបុគ្គលឈ្នះហើយ ប្រសើរជាង ចំណែកពួកសត្វក្រៅពីនេះ ដែលបុគ្គលឈ្នះហើយ មិនប្រសើរឡើយ (ព្រោះ ) កាលបើបុរសមានខ្លួនទូន្មានហើយ ជាអ្នកប្រព្រឹត្តសង្រួមជានិច្ច ទេវតា គន្ធព្វ មារ ព្រមទាំងព្រហ្ម មិនគប្បីធ្វើនូវជម្នះរបស់សត្វមានសភាពដូច្នោះឱ្យ ត្រឡប់ចាញ់វិញបានឡើយ ។

៨៥_ប្រារព្ធព្រាហ្មណ៍ម្នាក់ជាឪពុកធំរបស់ព្រះសារីបុត្ត

**មាសេ មាសេ សហស្សេន យោ យជេថ សតំ សមំ**
**ឯកញ្ច ភាវិតត្តានំ មុហុត្តមបិ បូជយេ**
**សាយេវ បូជនា សេយ្យោ យញ្ចេ វស្សសតំ ហុតំ ។**

អ្នកណាបូជា (លោកិយមហាជន ) ដោយទ្រព្យមួយពាន់រាល់ៗ ខែ អស់ ១ រយឆ្នាំគត់ ចំណែកឯការបូជាចំពោះបុគ្គលដែលមានខ្លួនអប់រំហើយតែ ១ នាក់ សូម្បីតែមួយរំពេច ការបូជានោះឯងប្រសើរជាងការបូជារបស់អ្នកដែលបូជាអស់ ១ រយឆ្នាំនោះ ការបូជាអស់ ១០០ ឆ្នាំ នឹងប្រសើរអ្វីទៅ ។

៨៦-ប្រារព្ធក្មួយព្រះសារីបុត្ត ជាអ្នកបម្រើភ្លើង

**យោ ច វស្សសតំ ជន្តុ អគ្គឹ បរិចរេ វនេ**
**ឯកញ្ច ភាវិតត្តានំ មុហុត្តមបិ បូជយេ**
**សាយេវ បូជនា សេយ្យោ យញ្ចេ វស្សសតំ ហុតំ ៕**

ជនណាបម្រើភ្លើងក្នុងព្រៃអស់ ១០០ ឆ្នាំ ចំណែកឯការបូជាចំពោះបុគ្គលដែលមានខ្លួនអប់រំហើយតែ ១ នាក់ សូម្បីតែមួយរំពេច ការបូជានោះឯង ប្រសើរជាងការបូជារបស់ជននោះការបូជាភ្លើងអស់ ១០០ ឆ្នាំ មិនប្រសើរឡើយ ។

៨៧-ប្រារព្ធព្រាហ្មណ៍ម្នាក់ ជាអ្នកបូជាយញ្ញ

**យង្កិញ្ចិ យិដ្ឋំ វ ហុតំ វ លោកេ**
**សំវច្ឆរំ យជេថ បុញ្ញបេក្ខោ**
**សព្វំបិ តំ ន ចតុភាគមេតិ**
**អភិវាទនា ឧជុគតេសុ សេយ្យោ ៕**

បុគ្គលអ្នកប្រាថ្នាបុណ្យ គប្បីបូជាគ្រឿងសក្ការបូជា ធំតូចណាមួយក្នុងលោកអស់មួយឆ្នាំ ការបូជាទាំងអស់នោះឯង រមែងមិនដល់នូវចំណែកទី ៤ នៃការអភិវាទ ចំពោះលោកទាំងឡាយដែលប្រព្រឹត្តត្រង់ហើយ (ដូច្នេះការអភិវាទចំពោះបុគ្គលដែលមានដំណើរត្រង់ មានព្រះសោតាបន្នជាដើមឡើងទៅ) ប្រសើរជាង។



៨៨-ប្រារព្ធអាយុវឌ្ឍនកុមារ មានការចម្រើនដោយអាយុ

**អភិវាទនសីលិស្ស និច្ចំ វុឌ្ឍាបចាយិនោ**
**ចត្តារោ ធម្មា វឌ្ឍន្តិ អាយុ វណ្ណោ សុខំ ពលំ ៕**

ធម៌ ៤ ប្រការគឺ អាយុ ១ វណ្ណៈ ១ សុខៈ ១ ពលៈ ១ រមែងចម្រើនដល់អ្នកដែលមានសេចក្ដីឱនកាយថ្វាយបង្គំជាប្រក្រតី មានសេចក្ដីកោតក្រែង ដល់បុគ្គលដែលចម្រើនជាងខ្លួន អស់កាលជានិច្ច ។

៨៩-ប្រារព្ធសង្កិច្ចសាមណេរ ញ៉ាំងពួកចោរឱ្យជ្រះថ្លា

**យោ ច វស្សសតំ ជីវេ ទុស្សីលោ អសមាហិតោ**
**ឯកាហំ ជីវិតំ សេយ្យោ សីលវន្តស្ស ឈាយិនោ ៕**

បុគ្គលណា រស់នៅមួយរយឆ្នាំ ជាមនុស្សទ្រុស្តសីល មានចិត្តមិនបានតម្កល់ខ្ជាប់ ឯការរស់នៅសូម្បីតែមួយថ្ងៃ របស់លោកដែលមានសីលមានការពិនិត្យពិចារណា ជាប្រក្រតី ប្រសើរជាង (ការរស់នៅរបស់បុគ្គលនោះ) ។

៩០-ប្រារព្ធព្រះខានុកោណ្ឌញ្ញត្ថេរ ញ៉ាំងពួកចោរឱ្យជ្រះថ្លា

**យោ ច វស្សសតំ ជីវេ ទុប្បញ្ញោ អសមាហិតោ**
**ឯកាហំ ជីវិតំ សេយ្យោ បញ្ញវន្តស្ស ឈាយិនោ ៕**

បុគ្គលណា រស់នៅមួយរយឆ្នាំ ជាមនុស្សមិនមានប្រាជ្ញា មានចិត្តមិនបានតម្កល់ខ្ជាប់ ឯការរស់នៅសូម្បីតែមួយថ្ងៃរបស់លោកដែលមានប្រាជ្ញា មានការពិនិត្យពិចារណា ជាប្រក្រតី ប្រសើរជាង (ការរស់នៅរបស់បុគ្គលនោះ) ។

៩១.ប្រារព្ធសប្បទាសត្ថេរ បានសម្រេចព្រះអរហត្តផល

**យោ ច វស្សសតំ ជីវេ កុសីតោ ហីនវីរិយោ**
**ឯកាហំ ជីវិតំ សេយ្យោ វីរិយំ អារភតោ ទឡ្ហំ ។**

បុគ្គលណា រស់នៅមួយរយឆ្នាំ ជាមនុស្សខ្ជិល (មានចិត្តងុលងប់ក្នុងអកុសលវិតក្កៈ) មានព្យាយាមថោកថយ ឯការរស់នៅសូម្បីតែមួយថ្ងៃ របស់លោកដែលប្រារព្ធនូវសេចក្ដីព្យាយាមមាំមួន ប្រសើរជាង (ការរស់នៅរបស់បុគ្គលនោះ)។

៩២.ប្រារព្ធព្រះនាងបដាចារាថេរីឃើញធម៌

**យោ ច វស្សសតំ ជីវេ អបស្សំ ឧទយព្វយំ**
**ឯកាហំ ជីវិតំ សេយ្យោ បស្សតោ ឧទយព្វយំ ។**

បុគ្គលណា រស់នៅមួយរយឆ្នាំ មិនឃើញការកើតឡើងនិងការវិនាសទៅ (នៃបញ្ចក្ខន្ធ) ឯការរស់នៅសូម្បីតែមួយថ្ងៃ របស់





លោកដែលឃើញ ការកើតឡើងនិងការវិនាសទៅ (នៃបញ្ចក្ខន្ធ) ប្រសើរជាង (ការរស់នៅរបស់បុគ្គលនោះ)។

៩៣.ប្រារព្ធព្រះនាងកិសាគោតមីថេរីឃើញអមតមហានិព្វាន

**យោ ច វស្សសតំ ជីវេ អបស្សំ អមតំ បទំ**
**ឯកាហំ ជីវិតំ សេយ្យោ បស្សតោ អមតំ បទំ ។**

បុគ្គលណា រស់នៅមួយរយឆ្នាំ មិនឃើញអមតមហានិព្វាន ឯការរស់នៅសូម្បីតែមួយថ្ងៃ របស់លោកដែលឃើញអមតមហា-និព្វានប្រសើរជាង (ការរស់នៅរបស់បុគ្គលនោះ) ។

៩៤.ប្រារព្ធព្រះនាងពហុបុត្តិកាថេរីឃើញលោកុត្តរធម៌៩ ប្រការ

**យោ ច វស្សសតំ ជីវេ អបស្សំ ធម្មមុត្តមំ**
**ឯកាហំ ជីវិតំ សេយ្យោ បស្សតោ ធម្មមុត្តមំ ។**

បុគ្គលណា រស់នៅមួយរយឆ្នាំ មិនឃើញធម៌ដ៏ខ្ពង់ខ្ពស់ (គឺលោកុត្តរធម៌ ៩ យ៉ាង) ឯការរស់នៅសូម្បីតែមួយថ្ងៃ របស់លោកដែលឃើញធម៌ដ៏ខ្ពង់ខ្ពស់ ប្រសើរជាង (ការរស់នៅរបស់បុគ្គលនោះ) ។

## ៣១_ធម្មបទគាថា បាបវគ្គទី ៩

### បិដកលេខ ៥២ ទំព័រ ៤៦

៩៥_ប្រារព្ធចូឡេកសាដកព្រាហ្មណ៍ ច្បាំងឈ្នះសេចក្តីកំណាញ់

**អភិត្ថរេថ កល្យាណេ បាបា ចិត្តំ និវារយេ**
**ទន្ធំ ហិ ករតោ បុញ្ញំ បាបស្មឹ រមតី មនោ ។**

បុគ្គលគួរប្រញាប់ប្រញាល់ធ្វើអំពើល្អ គួរឃាត់ចិត្តចាកបាប ព្រោះថា កាលបើបុគ្គលធ្វើបុណ្យយឺតយូរ ចិត្តរមែងត្រេកអរក្នុងបាប ។

៩៦_ប្រារព្ធព្រះសេយ្យសកត្ថេរ ប្រព្រឹត្តកម្មមិនគួរដល់សមណៈ

**បាបញ្ចេ បុរិសោ កយិរា ន នំ កយិរា បុនប្បុនំ**
**ន តម្ហិ ឆន្ទំ កយិរាថ ទុក្ខោ បាបស្ស ឧច្ចយោ ។**

បើបុរសធ្វើបាប កុំធ្វើបាបនោះរឿយៗឡើយ កុំគប្បីធ្វើសេចក្តីពេញចិត្តក្នុងបាបនោះ (ព្រោះថា) ការសន្សំបាប តែងនាំសេចក្តីទុក្ខមកឱ្យ ។





៩៧_ប្រារព្ធនាងលាជទេវធីតា ប្រាថ្នាធ្វើបុណ្យនឹងព្រះមហាកស្សបត្ថេរ

**បុញ្ញញ្ចេ បុរិសោ កយិរា កយិរាថេនំ បុនប្បុនំ**
**តម្ហិ ឆន្ទំ កយិរាថ សុខោ បុញ្ញស្ស ឧច្ចយោ ។**

បើបុរសធ្វើបុណ្យ គួរធ្វើបុណ្យនោះឱ្យរឿយៗ គួរធ្វើសេចក្តីពេញចិត្តក្នុងបុណ្យនោះ (ព្រោះថា) ការសន្សំបុណ្យ តែងនាំសេចក្តីសុខមកឱ្យ ។

៩៨_ប្រារព្ធអនាថបិណ្ឌិកសេដ្ឋីនាំទេវតាចូលគាល់ព្រះសម្មាសម្ពុទ្ធ

**បាបោបិ បស្សតី ភទ្រំ យាវ បាបំ ន បច្ចតិ**
**យទា ច បច្ចតី បាបំ អថ(បាបោ)បាបានិ បស្សតិ ។**
**ភទ្រោបិ បស្សតី បាបំ យាវ ភទ្រំ ន បច្ចតិ**
**យទា ច បច្ចតី ភទ្រំ អថ(ភទ្រោ)ភទ្រានិ បស្សតិ ។**

បាប មិនទាន់ឱ្យផលត្រឹមណា មនុស្សធ្វើបាប ក៏នៅឃើញតែសេចក្តីចម្រើនត្រឹមនោះ (ឃើញបាបថាល្អ) លុះកាលណាបាបឱ្យផល មនុស្សធ្វើបាប ទើបឃើញបាប ថាអាក្រក់ក្នុងកាលនោះ ។

អំពើល្អ មិនទាន់ឱ្យផលត្រឹមណា មនុស្សធ្វើល្អ នៅឃើញតែបាបត្រឹមនោះ (ឃើញអំពើល្អថាអាក្រក់) លុះកាលណាអំពើល្អឱ្យផល មនុស្សធ្វើល្អ ទើបឃើញអំពើល្អ ថាល្អ ក្នុងកាលនោះ។

៩៩.ប្រារព្ធភិក្ខុមួយអង្គ មើលងាយបាបថាមានប្រមាណតិច

**មាវមញ្ញេថ បាបស្ស  ន មន្តំ អាគមិស្សតិ**
**ឧទពិន្ទុនិបាតេន  ឧទកុម្ភោបិ បូរតិ**
**អាបូរតិ ពាលោ បាបស្ស  ថោកំ ថោកំបិ អាចិនំ ៕**

បុគ្គល មិនគួរមើលងាយបាបថា មានប្រមាណតិច នឹងមិនឱ្យផលដូច្នេះឡើយ ប្រៀបដូចក្អមទឹក រមែងពេញបានដោយតំណក់ទឹកដែលធ្លាក់ចុះ យ៉ាងណា បុគ្គលពាល កាលសន្សំបាបសូម្បីបន្តិចម្តងៗ គង់ពេញបានដោយបាប យ៉ាងនោះដែរ ។

១០០.ប្រារព្ធសេដ្ឋីជើងឆ្មា មើលងាយបុណ្យថាមានប្រមាណតិច

**មាវមញ្ញេថ បុញ្ញស្ស  ន មន្តំ អាគមិស្សតិ**
**ឧទពិន្ទុនិបាតេន  ឧទកុម្ភោបិ បូរតិ**
**អាបូរតិ ធីរោ បុញ្ញស្ស  ថោកំ ថោកំបិ អាចិនំ ៕**

បុគ្គល មិនគួរមើលងាយបុណ្យថា មានប្រមាណតិច នឹងមិនឱ្យផលដូច្នេះឡើយ ប្រៀបដូចក្អមទឹក រមែងពេញបានដោយតំណក់ទឹកដែលធ្លាក់ចុះ យ៉ាងណា អ្នកមានប្រាជ្ញា កាលសន្សំបុណ្យបន្តិចម្តងៗ គង់ពេញបានដោយបុណ្យ យ៉ាងនោះ ។





១០១.ប្រារព្ធនាយពាណិជ ចៀសវាងផ្លូវដែលមានចោរ

**វាណិជោវ ភយំ មគ្គំ  អប្បសត្ថោ មហទ្ធនោ**
**វិសំ ជីវិតុកាមោវ  បាបានិ បរិវជ្ជយេ ៕**

បុគ្គលគួរចៀសវាងបាបទាំងឡាយ ឱ្យដូចពាណិជ ដែលមានទ្រព្យច្រើន តែមានគ្នាតិច ចៀសវាងផ្លូវដែលគួរឱ្យខ្លាច ឬដូចជាបុរសដែលប្រាថ្នានឹងរស់នៅ ចៀសវាងថ្នាំពិសដូច្នោះដែរ ។

១០២.ប្រារព្ធព្រានកុក្កុដមិត្រ និងកូនស្រីលោកសេដ្ឋីក្រុងរាជគ្រឹះ

**បាណិម្ហិ ចេ វណោ នាស្ស ហរេយ្យ បាណិនា វិសំ**
**នាព្វណំ វិសមន្វេតិ  នត្ថិ បាបំ អកុព្វតោ ៕**

បើដំបៅមិនមានក្នុងបាតដៃទេ បុគ្គលគប្បីនាំយកថ្នាំពិសដោយបាតដៃ ថ្នាំពិស តែងមិនជ្រាបចូលទៅកាន់បាតដៃដែលគ្មានដំបៅ យ៉ាងណា បាប រមែងមិនមានដល់បុគ្គលអ្នកមិនធ្វើ យ៉ាងនោះដែរ ។

១០៣.ប្រារព្ធព្រានសុនខឈ្មោះកោកៈ ប្រទូស្តនឹងភិក្ខុអ្នកមានសីល

**យោ អប្បទុដ្ឋស្ស នរស្ស ទុស្សតិ**
**សុទ្ធស្ស បោសស្ស អនង្គណស្ស**

**តមេវ ពាលំ បច្ចេតិ បាបំ**
**សុខុមោ រជោ បដិវាតំវ ខិត្តោ ៕**

បុគ្គលណា ប្រទូស្តចំពោះអ្នកមិនប្រទូស្តតប ជាសត្វស្អាតមិនមានកិលេសដូចជាទីទួល បាបរមែងត្រឡប់មករកបុគ្គលពាលនោះវិញដូចធូលីល្អិត ដែលបុគ្គលបាចសាចទៅកាន់ទីច្រាសខ្យល់។

១០៤-ប្រារព្ធព្រះតិស្សត្ថេរជាមួយនឹងជាងច្នៃកែវមណី

**គព្ភមេកេ ឧប្បជ្ជន្តិ    និរយំ បាបកម្មិនោ**
**សគ្គំ សុគតិនោ យន្តិ    បរិនិព្វន្តិ អនាសវា ៕**

ពួកជនខ្លះ កើតក្នុងគភ៌មនុស្ស ពួកអ្នកមានអំពើអាក្រក់ទៅកាន់នរក ពួកអ្នកមានអំពើជាហេតុនៃសុគតិ រមែងទៅកាន់ឋានសួគ៌ (ចំណែក) ពួកអ្នកមិនមានអាសវៈ រមែងបរិនិព្វាន ។

១០៥-ប្រារព្ធជនបីនាក់ ធ្លាប់ធ្វើបាបកម្មពីមុនមក ត្រូវទទួលផល

**ន អន្តលិក្ខេ ន សមុទ្ទមជ្ឈេ**
**ន បព្វតានំ វិវរំ បវីសំ**
**ន វិជ្ជតី សោ ជគតិប្បទេសោ**
**យត្រដ្ឋិតោ មុច្ចេយ្យ បាបកម្មា ៕**





បុគ្គលអ្នកធ្វើបាបកម្មហើយ ទោះបីរត់គេចចូលទៅឰដ៏អាកាសក្តី ក្នុងកណ្តាលសមុទ្រក្តី កាន់ចន្លោះភ្នំទាំងឡាយក្តី ក៏មិនគប្បីគេចរួចចាកបាបកម្មនោះបានឡើយ ព្រោះប្រទេសលើផែនដីដែលបុគ្គលឋិតនៅហើយ គប្បីរួចចាកបាបកម្មបាននោះ មិនមានសោះឡើយ ។

១០៦-ប្រារព្ធព្រះបាទសុប្បពុទ្ធ ត្រូវផែនដីស្រូប ព្រោះប្រទូសរ៉ាយនឹង ព្រះពុទ្ធ

**ន អន្តលិក្ខេ ន សមុទ្ទមជ្ឈេ**
**ន បព្វតានំ វិវរំ បវិស្ស**
**ន វិជ្ជតី សោ ជគតិប្បទេសោ**
**យត្រដ្ឋិតំ នប្បសហេយ្យ មច្ចុ ៕**

បុគ្គលទៅ ឰដ៏អាកាសក្តី ក្នុងកណ្តាលសមុទ្រក្តី កាន់ចន្លោះភ្នំទាំងឡាយក្តី ក៏មិនរួចចាកសេចក្តីស្លាប់បាន ព្រោះប្រទេសលើផែនដី ដែលបុគ្គលឋិតនៅហើយ សេចក្តីស្លាប់គ្របសង្កត់មិនបាននោះ មិនដែលមានឡើយ ។

## ៣២_ធម្មបទគាថា ទណ្ឌវគ្គទី ១០

### បិដកលេខ ៥២ ទំព័រ ៤៩

១០៧_ប្រារព្ធឆព្វគ្គិយភិក្ខុ វាយប្រហារបៀតបៀនដល់ពួកភិក្ខុដទៃ

**សព្វេ តសន្តិ ទណ្ឌស្ស សព្វេ ភាយន្តិ មច្ចុនោ**
**អត្តានំ ឧបមំ កត្វា ន ហនេយ្យ ន ឃាតយេ ។**

សត្វទាំងឡាយគ្រប់ប្រាណ តែងតក់ស្លុតនឹងអាជ្ញា សត្វទាំងឡាយ តែងខ្លាចចំពោះសេចក្តីស្លាប់គ្រប់ៗរូប បុគ្គលគួរធ្វើខ្លួនឱ្យជាឧបមា ហើយមិនគួរប្រហារ ដោយខ្លួនឯង មិនគួរប្រើគេឱ្យប្រហារឡើយ ។

១០៨_ប្រារព្ធឆព្វគ្គិយភិក្ខុ ទះតប់ភិក្ខុដទៃដោយដៃ

**សព្វេ តសន្តិ ទណ្ឌស្ស សព្វេសំ ជីវិតំ បិយំ**
**អត្តានំ ឧបមំ កត្វា ន ហនេយ្យ ន ឃាតយេ ។**

សត្វទាំងឡាយគ្រប់ប្រាណ តែងតក់ស្លុតនឹងអាជ្ញា (ព្រោះថា) ជីវិតជាទីស្រឡាញ់របស់សត្វទាំងពួង បុគ្គលគួរធ្វើខ្លួនឱ្យជាឧបមា ហើយមិនគួរប្រហារ ដោយខ្លួនឯង មិនគួរប្រើគេឱ្យប្រហារឡើយ ។





១០៩_ប្រារព្ធពួកក្មេងៗ នាំគ្នាយកឈើវាយសម្លាប់ពស់

**សុខកាមានិ ភូតានិ យោ ទណ្ឌេន វិហឹសតិ**
**អត្តនោ សុខមេសានោ បេច្ច សោ ន លភតេ សុខំ ។**
**សុខកាមានិ ភូតានិ យោ ទណ្ឌេន ន ហឹសតិ**
**អត្តនោ សុខមេសានោ បេច្ច សោ លភតេ សុខំ ។**

ជនណា ស្វែងរកសេចក្តីសុខ ដើម្បីខ្លួន តែបៀតបៀនសត្វទាំងឡាយ ដែលប្រាថ្នាសេចក្តីសុខ ដោយអាជ្ញា ជននោះលះលោកនេះទៅហើយ នឹងមិនបានសេចក្តីសុខឡើយ ។

ជនណា ស្វែងរកសេចក្តីសុខ ដើម្បីខ្លួន តែមិនបៀតបៀនសត្វទាំងឡាយ ដែលប្រាថ្នាសេចក្តីសុខ ដោយអាជ្ញា ជននោះលះលោកនេះទៅហើយ រមែងបានសេចក្តីសុខ ។

១១០_ប្រារព្ធព្រះកោណ្ឌធានត្ថេរ ពោលពាក្យអាក្រក់ដល់ភិក្ខុដទៃ

**មាវោច ផរុសំ កញ្ចិ វុត្តា បដិវទេយ្យុ តំ**
**ទុក្ខា ហិ សារម្ភកថា បដិទណ្ឌា ផុសេយ្យុ តំ ។**
**សចេ នេរេសិ អត្តានំ កំសោ ឧបហតោ យថា**
**ឯស បត្តោសិ និព្វានំ សារម្ភោ តេ ន វិជ្ជតិ ។**

អ្នកកុំនិយាយពាក្យអាក្រក់នឹងអ្នកណាមួយឡើយ ជនទាំង-ឡាយដែលអ្នកស្តីថាឱ្យហើយ គេគប្បីស្តីថាតបមកអ្នកវិញ ព្រោះថា ការពោលពាក្យប្រណាំងប្រជែង ជាហេតុនាំឱ្យកើតទុក្ខ អាជ្ញាតប ត្រូវបានធ្លាក់ចុះមកប៉ះពាល់ដល់អ្នកវិញ ។

បើអ្នកធ្វើខ្លួនមិនឱ្យញាប់ញ័រ ដូចរគាំងដែលចៀរមាត់ចេញហើយ (រមែងមិនលាន់ឮសូរ ) ដូច្នោះ អ្នកនុ៎ះជាបុគ្គលដល់នូវព្រះនិព្វាន ការប្រណាំងប្រជែង មិនមានដល់អ្នកឡើយ ។

១១១-ប្រារព្ធឧបោសថសីលរបស់ឧបាសិកាទាំងឡាយ

**យថា ទណ្ឌេន គោបាលោ  គាវោ បាចេតិ គោចរំ**
**ឯវំ ជរា ច មច្ចុ ច  អាយុំ បាចេន្តិ បាណិនំ ។**

គង្វាលគោ រមែងកៀងគោទៅកាន់ទីគោចរដោយអាជ្ញា ដូចម្តេចមិញ ជរានិងមច្ចុ តែងកៀងអាយុរបស់សត្វទាំងឡាយដូច្នោះឯង ។

១១២-ប្រារព្ធអជគរប្រេត មានបុព្វកម្មដុតព្រះគន្ធកុដិ

**អថ បាបានិ កម្មានិ  ករំ ពាលោ ន ពុជ្ឈតិ**
**សេហិ កម្មេហិ ទុម្មេធោ  អគ្គិទឌ្ឍោវ តប្បតិ ។**





បុគ្គលពាល កាលធ្វើអំពើអាក្រក់ទាំងឡាយ រមែងមិនភ្ញាក់ខ្លួនឡើយ ( លុះកាលជាខាងក្រោយ ) បុគ្គលអប្បប្រាជ្ញានោះទើបក្តៅក្រហាយ ដោយសារកម្មរបស់ខ្លួនឯង ដូចជាត្រូវភ្លើងឆេះ ។

១១៣-ប្រារព្ធព្រះមហាមោគ្គល្លានត្ថេរ មានបុព្វកម្មវាយសម្លាប់ឪពុកម្តាយ

**យោ ទណ្ឌេន អទណ្ឌេសុ  អប្បទុដ្ឋេសុ ទុស្សតិ**
**ទសន្នមញ្ញតរំ ឋានំ  ខិប្បមេវ និគច្ឆតិ**
**វេទនំ ផរុសំ ជានឹ  សរីរស្ស វ ភេទនំ**
**គរុកំ វាបិ អាពាធំ  ចិត្តក្ខេបំ វ បាបុណេ**
**រាជតោ វា ឧបសគ្គំ  អព្ភក្ខានំ វ ទារុណំ**
**បរិក្ខយំ វ ញាតីនំ  ភោគានំ វ បភង្គុណំ**
**អថវស្ស អគារានិ  អគ្គិ ឌហតិ បាវកោ**
**កាយស្ស ភេទា ទុប្បញ្ញោ  និរយំ សោ ឧបបជ្ជតិ ។**

បុគ្គលណា ប្រទូស្តដោយអាជ្ញា ចំពោះបុគ្គលទាំងឡាយដែលមិនមានអាជ្ញាប្រទូស្ត បុគ្គលនោះ រមែងដល់នូវហេតុនៃសេចក្តីទុក្ខណាមួយ ក្នុងហេតុ ១០ យ៉ាង ដោយទាន់ហន់ គឺគប្បីដល់នូវវេទនាដ៏អាក្រក់ ១ សេចក្តីវិនាសទ្រព្យ ១ បែកធ្លាយសរីរៈ ១ អាពាធជាទម្ងន់ ១ ក្រឡកចិត្ត (ឆ្កួត )១ រឹបជាន់អំពី

ស្តេច ១ ពោលពាក្យបង្កាច់ដ៏អាក្រក់ ១ អស់ពួកញាតិរលីង ១ ពុកផុយភោគសម្បត្តិទាំងឡាយ ១ ទាំងភ្លើងនឹងឆេះបំផ្លាញនូវផ្ទះរបស់បុគ្គលនោះ ១ បុគ្គលមិនមានប្រាជ្ញានោះ លុះបែកធ្លាយរាងកាយ រមែងទៅកើតក្នុងនរក ។

១១៤_ប្រារព្ធភិក្ខុមួយអង្គស្លៀកតែស្បង់ ព្រោះក្រោធនឹងព្រះអង្គដែលទ្រង់ទូន្មានឱ្យសន្តោស

**ន នគ្គចរិយា ន ជដា ន បង្កា**
**នានាសកា ថណ្ឌិលសាយិកា វា**
**រជោជល្លំ ឧក្កុដិកប្បធានំ**
**សោធេន្តិ មច្ចំ អវិតិណ្ណកង្ខំ ៕**

ការប្រព្រឹត្តអាក្រាតកាយ ទុកសក់ ដេកលើភក់ មិនបរិភោគបាយ ដេកលើផែនដី ប្រឡាក់ខ្លួនដោយធូលី ព្យាយាមអង្គុយច្រហោង (ទាំងអស់នេះ ) មិនអាចជម្រះសត្វដែលមិនទាន់ឆ្លងផុតសេចក្តីសង្ស័យ ឱ្យបរិសុទ្ធបានឡើយ ។

១១៥_ប្រារព្ធសន្តតិមហាមាត្យ សម្រេចព្រះអរហត្តផល បរិនិព្វាន

**អលង្កតោ ចេបិ សមំ ចរេយ្យ**
**សន្តោ ទន្តោ និយតោ ព្រហ្មចារី**



**សព្វេសុ ភូតេសុ និធាយ ទណ្ឌំ**
**សោ ព្រាហ្មណោ សោ សមណោ ស ភិក្ខុ ៕**

បើបុគ្គលណា ស្អិតស្អាងរាងកាយហើយ (ដោយគ្រឿងអម្ពរ ) តែមានការប្រព្រឹត្តស្មើ ជាអ្នកស្ងប់រម្ងាប់ ទូន្មាននូវឥន្ទ្រិយជាបុគ្គលទៀង (ចំពោះមគ្គផល ) មានប្រក្រតីប្រព្រឹត្តធម៌ដ៏ប្រសើរ ទម្លាក់ចោលនូវអាជ្ញាក្នុងសត្វទាំងពួងចេញហើយ បុគ្គលនោះហៅថាព្រាហ្មណ៍ក៏បាន ថាសមណៈក៏បាន ថាភិក្ខុក៏បាន ។

១១៦_ប្រារព្ធបិលោតិកត្ថេរ ទូន្មានខ្លួន កុំឱ្យចង់សឹក

**ហិរីនិសេធោ បុរិសោ      កោចិ លោកស្មិ វិជ្ជតិ**
**យោ និទ្ទំ អបពោធេតិ      អស្សោ ភទ្រោ កសាមិវ ៕**
**អស្សោ យថា ភទ្រោ កសានិវិដ្ឋោ**
**អាតាបិនោ សំវេគិនោ ភវាថ**
**សទ្ធាយ សីលេន ច វីរិយេន ច**
**សមាធិនា ធម្មវិនិច្ឆយេន ច**
**សម្បន្នវិជ្ជាចរណា បតិស្សតា**
**បហស្សថ ទុក្ខមិទំ អនប្បកំ ៕**

បុរសអ្នកកម្ចាត់បង់នូវអកុសលវិតក្កៈ ដោយសេចក្តីខ្មាសបាប មានតិចក្នុងលោក បុគ្គលណាបន្ទោបង់នូវការដេកលក់ ដូច

សេះល្អមិនឱ្យរំពាត់ត្រូវខ្លួន បុគ្គលនោះ រកបានដោយក្រ ។

សេះល្អ ដែលនាយសារថីទូន្មាន ដោយរំពាត់ តក់ស្លុតយ៉ាងណា អ្នកទាំងឡាយ ចូរជាបុគ្គលមានព្យាយាម មានសេចក្ដីតក់ស្លុត យ៉ាងនោះឯង បើអ្នកទាំងឡាយ ប្រកបព្រមដោយសទ្ធាផង សីលផង ព្យាយាមផង សមាធិផង និងធម្មវិនិច្ឆ័យផង ជាអ្នកមានវិជ្ជា និងចរណៈដ៏បរិបូណ៌ មានស្មារតីតម្កល់មាំ រមែងលះបង់ទុក្ខ មានប្រមាណច្រើននេះ បានមិនខាន ។

១១៧_ប្រារព្ធសុខសាមណេរ ទូន្មានខ្លួនបានសម្រេចព្រះអរហត្តផល

**ឧទកំ ហិ នយន្តិ នេត្តិកា**
**ឧសុការា នមយន្តិ តេជនំ**
**ទារុំ នមយន្តិ តច្ឆកា**
**អត្តានំ ទមយន្តិ សុព្វតា ។**

ធម្មតាអ្នកបង្ហូរទឹក តែងបង្ហូរទឹក អ្នកធ្វើព្រួញ តែងពត់ព្រួញ (ឱ្យត្រង់ ) អ្នកចាំង តែងចាំងឈើ អ្នកមានវត្តល្អ តែងទូន្មានខ្លួន ។





## ៣៣_ធម្មបទគាថា ជរាវគ្គទី ១១

### បិដកលេខ ៥២ ទំព័រ ៥២

១១៨_ប្រារព្ធពួកស្រីៗ ស្រវឹងស្រា នាំគ្នារាំមុខព្រះអង្គ

**កោ នុ ហាសោ កិមានន្ទោ និច្ចំ បជ្ជលិតេ សតិ**
**អន្ធការេន ឱនទ្ធា បទីបំ ន គវេសថ ។**

កាលបើលោកសន្និវាស ត្រូវភ្លើងមានរាគៈ ជាដើម ឆេះទ្រលោមជានិច្ច ម្ដេចក៏សើច ម្ដេចក៏ត្រេកត្រអាល អ្នកទាំងឡាយត្រូវងងឹត គឺអវិជ្ជារួបរឹតហើយ (ម្ដេចឡើយ ) ក៏មិនស្វែងរកប្រទីបគឺប្រាជ្ញា (ដើម្បីកម្ចាត់នូវសេចក្ដីងងឹតនោះចេញ ) ។

១១៩_ប្រារព្ធនាងសិរិមារូបស្អាត ស្លាប់ទៅនៅសាកសពឱ្យពិចារណា

**បស្ស ចិត្តកតំ ពិម្ពំ អរុកាយំ សមុស្សិតំ**
**អាតុរំ ពហុសង្កប្បំ យស្ស នត្ថិ ធុវំ ឋិតិ ។**

អត្តភាពណា មិនទៀងទាត់ ឋិតថេរ អ្នកចូរមើលអត្តភាព ( នោះ ) ដែលកុសលាកុសលកម្ម ធ្វើឱ្យវិចិត្រហើយ ជាកាយពាសពេញដោយដំបៅ ដែលឆ្អឹងបីរយកំណាត់ ផ្គុំគ្នាហើយ ជា

អត្តភាព ក្តៅក្រហាយជានិច្ច ជាទីរំពឹងត្រិះរិះយ៉ាងខ្លាំងនៃជនទាំងឡាយ ។

១២០.ប្រារព្ធព្រះនាងឧត្តរាថេរី មានព្រះជន្ម ១២០ ឆ្នាំ ដើរដួល

**បរិជិណ្ណមិទំ រូបំ  រោគនិឌ្ឌំ បភង្គុណំ**
**ភិជ្ជតិ បូតិ សន្ទេហោ  មរណន្តំ ហិ ជីវិតំ ៕**

រូបនេះគ្រាំគ្រាអស់ហើយ ជាទីសំណាក់នៃរោគ ជារបស់ពុកផុយ កាយរបស់ខ្លួនជារបស់ស្អុយ នឹងបែកធ្លាយទៅវិញ ព្រោះថា ជីវិតមានសេចក្តីស្លាប់ជាទីបំផុត ។

១២១.ប្រារព្ធពួកភិក្ខុ ៥០០ អង្គ និមន្តចូលព្រៃខ្មោច

**យានិមានិ អបត្ថានិ  អលាពូនេវ សារទេ**
**កាបោតកានិ អដ្ឋីនិ  តានិ ទិស្វាន កា រតិ ៕**

ឆ្អឹងទាំងឡាយណា មានសម្បុរដូចសត្វព្រាប ដែលគេចោលហើយ ដូចផ្លែឃ្លោកក្នុងសរទកាល សេចក្តីត្រេកអរអ្វីហ្ន៎ (របស់អ្នកទាំងឡាយ) ព្រោះតែឃើញឆ្អឹងទាំងឡាយនោះ ។

១២២.ប្រារព្ធព្រះនាងរូបនន្ទាថេរី ស្រវឹងនឹងរូបខ្លួនឯងស្អាត

**អដ្ឋីនំ នគរំ កតំ  មំសលោហិតលេបនំ**
**យត្ថ ជរា ច មច្ចុ ច  មានោ មក្ខោ ច ឱហិតោ ៕**

សេចក្តីគ្រាំគ្រា សេចក្តីស្លាប់ សេចក្តីប្រកាន់ខ្លួននិងសេចក្តីលុបគុណ ប្រជុំចុះក្នុងសរីរៈណា (សរីរៈនោះ) ដែលកុសលា-កុសលកម្មធ្វើហើយ ឱ្យជានគររបស់ឆ្អឹងទាំងឡាយ បិទបូកលាបដោយសាច់និងឈាម ។

១២៣.ប្រារព្ធព្រះនាងមល្លិកាទេវីអស់ព្រះជន្ម ឯព្រះរាជាទ្រង់ជរា

**ជីរន្តិ វេ រាជរថា សុចិត្តា**
**អថោ សរីរម្បិ ជរំ ឧបេតិ**
**សតញ្ច ធម្មោ ន ជរំ ឧបេតិ**
**សន្តោ ហវេ សព្ភិ បវេទយន្តិ ៕**

រាជរថទាំងឡាយ ដ៏វិចិត្រល្អ រមែងគ្រាំគ្រា សូម្បីសរីរៈក៏ដល់នូវសេចក្តីគ្រាំគ្រាដូចគ្នា រីឯធម៌របស់សប្បុរស មិនចូលដល់ការចាស់ជរាឡើយ សប្បុរសទាំងឡាយតែងប្រឹក្សាជាមួយពួកសប្បុរសផងគ្នា ។

១២៤-ប្រារព្ធព្រះលោឡុទាយិត្ថេរ មានបញ្ញាអន់ថយ

**អប្បស្សុតាយំ បុរិសោ ពលិពទ្ទោវ ជីរតិ**
**មំសានិ តស្ស វឌ្ឍន្តិ បញ្ញា តស្ស ន វឌ្ឍតិ ។**

បុរសអ្នកមិនមានការចេះដឹងនេះ តែងចាស់ (ឥតអំពើ ) ដូចគោបម្រើ សាច់របស់វាតែងចម្រើនឡើង តែប្រាជ្ញារបស់វាមិនចម្រើនឡើយ ។

១២៥-ប្រារព្ធបឋមពោធិកាល ដែលព្រះអានន្ទត្ថេរទូលសួរ

**អនេកជាតិសំសារំ សន្ធាវិស្សំ អនិព្វិសំ**
**គហការំ គវេសន្តោ ទុក្ខា ជាតិ បុនប្បុនំ ។**
**គហការក ទិដ្ឋោសិ បុន គេហំ ន កាហសិ**
**សព្វា តេ ផាសុកា ភគ្គា គហកូដំ វិសង្ខតំ**
**វិសង្ខារគតំ ចិត្តំ តណ្ហានំ ខយមជ្ឈគា ។**

កាលតថាគតកំពុងតែស្វះស្វែងរកជាងធ្វើផ្ទះ គឺតណ្ហា អ្នកធ្វើផ្ទះគឺអត្តភាព មិនទាន់បានជួបប្រទះនៅឡើយ (តថាគត ) ក៏អន្ទោលទៅកាន់សង្សារវដ្ត មានជាតិដ៏ច្រើន សេចក្តីកើតជាទុក្ខរឿយៗ ។





នែជាងផ្ទះ អ្នកធ្វើផ្ទះគឺអត្តភាព តថាគតឃើញហើយ អ្នកនឹងធ្វើផ្ទះ (របស់តថាគត ) ទៀតមិនបានឡើយ ឆ្អឹងជំនីរគឺកិលេសរបស់អ្នកទាំងអស់តថាគតកាច់បំបាក់អស់ហើយ ដំបូលផ្ទះគឺអវិជ្ជា តថាគតកម្ចាត់ចោលហើយ ចិត្តរបស់តថាគត ដល់ព្រះនិព្វានដែលប្រាសចាកសង្ខារហើយ តថាគត បានដល់ធម៌ជាគ្រឿងក្ស័យតណ្ហាទាំងឡាយហើយ ។

១២៦-ប្រារព្ធសេដ្ឋីបុត្ត មានទ្រព្យច្រើនហើយប្រព្រឹត្តអបាយមុខ

**អចរិត្វា ព្រហ្មចរិយំ អលទ្ធា យោព្វនេ ធនំ**
**ជិណ្ណកោញ្ចាវ ឈាយន្តិ ខីណមច្ឆេវ បល្លលេ ។**
**អចរិត្វា ព្រហ្មចរិយំ អលទ្ធា យោព្វនេ ធនំ**
**សេន្តិ ចាបាតិខីណាវ បុរាណានិ អនុត្ថុនំ ។**

ជនពាលទាំងឡាយ មិនប្រព្រឹត្តព្រហ្មចរិយធម៌ មិនបានទ្រព្យ ក្នុងកាលខ្លួននៅជាកំលោះក្រមុំ រមែងសញ្ជប់សញ្ជឹង ដូចសត្វក្រៀលចាស់សំកុកនៅក្នុងភក់ដែលអស់ត្រីហើយ ដូច្នោះឯង។

ជនពាលទាំងឡាយ មិនប្រព្រឹត្តព្រហ្មចរិយធម៌ មិនបានទ្រព្យ ក្នុងកាលខ្លួននៅជាកំលោះក្រមុំ រមែងដេកថ្ងូរ សោកស្តាយទ្រព្យចាស់ទាំងឡាយ ដូចព្រួញដែលផុតចាកខ្សែបន្ទោះដូច្នោះ ។

(ព្រួញដែលផុតហើយពីខ្សែបន្ទោះ ទៅតាមកម្លាំង រួចហើយក៏ធ្លាក់ចុះ កាលដែលមិនមានអ្នកណាចាប់វា លើកឡើងទេ វាក៏ត្រូវជាចំណីនៃសត្វកណ្ដៀរក្នុងទីនោះឯង យ៉ាងណា បុគ្គលពាលល្ងង់ខ្លៅទាំងនោះ ក៏យ៉ាងនោះដែរ កាលដែលវ័យទាំង ៣ កន្លងទៅហើយ ក៏ចូលដល់មរណៈ ព្រោះការដែលមិនអាចលើកខ្លួនឯងឡើងបាន ក្នុងកាលឥឡូវនេះ ។ មុនពេលស្លាប់ បុគ្គលពាល មានតែការសោកសៅ នឹកដល់ការដែលខ្លួនធ្លាប់ស៊ី ធ្លាប់ផឹក ធ្លាប់រាំ ធ្លាប់ច្រៀង ធ្លាប់ប្រគំជាដើម ក្នុងកាលមុនប៉ុណ្ណោះ) ។

## ជាតិមនុស្សថ្លៃមិនគប្បីធ្វើអំពើថោក

**ហីនំ ធម្មំ ន សេវេយ្យ បមាទេន ន សំវសេ**
**មិច្ឆាទិដ្ឋឹ ន សេវេយ្យ ន សិយា លោកវឌ្ឍនោ។**

បុគ្គលមិនគួរសេពនូវធម៌ដ៏ថោកទាប មិនគួរនៅរួមជាមួយសេចក្ដីប្រមាទ មិនគួរសេពនូវមិច្ឆាទិដ្ឋិ មិនគួរជាមនុស្សចង្អៀតលោកឡើយ ។

ព្រះអង្គទ្រង់គង់ប្រថាប់នៅជេតវនារាម ទ្រង់ប្រារព្ធភិក្ខុកំលោះមួយអង្គ
ដែលឈ្លោះគ្នាជាមួយនឹងចៅស្រីរបស់ឧបាសិកាវិសាខា



## ៣៤-ធម្មបទគាថា អត្តវគ្គទី ១២
### បិដកលេខ ៥២ ទំព័រ ៥៥

១២៧-ប្រារព្ធពោធិរាជកុមារ មានបុព្វកម្មមិនរក្សាខ្លួនទុកក្នុងគុណធម៌

**អត្តានញ្ចេ បិយំ ជញ្ញា រក្ខេយ្យ នំ សុរក្ខិតំ**
**តិណ្ណំ អញ្ញតរំ យាមំ បដិជគ្គេយ្យ បណ្ឌិតោ ។**

បើបណ្ឌិតដឹងថា ខ្លួនជាទីស្រឡាញ់ គួររក្សាខ្លួននោះឱ្យល្អ គួរស្ងួនគ្រងខ្លួនទុកក្នុងវ័យទាំង ៣ វ័យណាមួយ ។

១២៨-ប្រារព្ធព្រះឧបនន្ទសក្យបុត្តិយ៍ ប្រដៅតែគេ មិនប្រដៅខ្លួនឯង

**អត្តានមេវ បឋមំ បតិរូបេ និវេសយេ**
**អថញ្ញមនុសាសេយ្យ ន កិលិស្សេយ្យ បណ្ឌិតោ ។**

បណ្ឌិត គួរតម្កល់ខ្លួនទុក ក្នុងគុណដ៏សមគួរជាមុនសិន ហើយសឹមប្រៀនប្រដៅអ្នកដទៃជាខាងក្រោយ (ធ្វើយ៉ាងនេះ)នឹងមិនគប្បីសៅហ្មងឡើយ ។

១២៩.ប្រារព្ធព្រះបធានិកតិស្សត្ថេរ ប្រដៅតែគេ មិនប្រដៅខ្លួនឯង

**អត្តានញ្ចេ តថា កយិរា យថញ្ញមនុសាសតិ**
**សុទន្តោ វត ទមេថ អត្តា ហិ កិរ ទុទ្ទមោ ។**

បុគ្គលប្រៀនប្រដៅអ្នកដទៃ យ៉ាងណា ត្រូវធ្វើខ្លួនឱ្យបាន យ៉ាងនោះដែរ អ្នកដែលទូន្មានខ្លួនល្អហើយ ទើបគួរទូន្មានអ្នកដទៃបាន ព្រោះថា ខ្លួនហ្នឹងឯង ដែលទូន្មានបានដោយលំបាក ។

១៣០.ប្រារព្ធមាតារបស់ព្រះកុមារកស្សបត្ថេរ មានខ្លួនឯងជាទីពឹង

**អត្តា ហិ អត្តនោ នាថោ កោ ហិ នាថោ បរោ សិយា**
**អត្តនា ហិ សុទន្តេន នាថំ លភតិ ទុល្លភំ ។**

ខ្លួនហ្នឹងឯងជាទីពឹងរបស់ខ្លួន អ្នកដទៃជាទីពឹងដូចម្ដេចបាន ព្រោះបុគ្គលមានខ្លួនហ្វឹកហ្វឺនល្អហើយ រមែងបាននូវទីពឹង ដែលគេបានដោយកម្រ ។

១៣១.ប្រារព្ធមហាកាលឧបាសក មានបុព្វកម្មសម្លាប់ប្ដីគេ ប្លន់យកប្រពន្ធ

**អត្តនា វ កតំ បាបំ អត្តជំ អត្តសម្ភវំ**
**អភិមត្ថតិ ទុម្មេធំ វជិរំវម្ហយំ មណឹ ។**





បាប កើតអំពីខ្លួន មានខ្លួនជាដែនកើត ដែលខ្លួនធ្វើហើយ តែងញាំញីមនុស្សឥតប្រាជ្ញា ដូចពេជ្រសម្រាប់កាត់កែវមណី ដែលកើតអំពីថ្ម ដូច្នោះឯង ។

១៣២.ប្រារព្ធភិក្ខុទេវទត្តដែលប្រព្រឹត្តអាក្រក់ខ្លាំងក្លាដោយប្រការផ្សេងៗ

**យស្ស អច្ចន្តទុស្សីល្យំ មាលុវា សាលមិវោត្ថតំ**
**ករោតិ សោ តថត្តានំ យថា នំ ឥច្ឆតី ទិសោ ។**

ភាពជាអ្នកទ្រុស្តសីលហួសហេតុ[1] គ្របសង្កត់ ( នូវអត្ត-ភាព ) របស់បុគ្គលណា ដូចវល្លិដែលរួបរឹតនូវដើមសាលៈ បុគ្គលនោះ ឈ្មោះថា ធ្វើខ្លួនឱ្យដូចជាចោរដែលប្រាថ្នាធ្វើខ្លួនឯង ឱ្យវិនាសដូច្នោះ ។

១៣៣.ប្រារព្ធភិក្ខុទេវទត្តព្យាយាមបំបែកសង្ឃ

**សុករានិ អសាធូនិ អត្តនោ អហិតានិ ច**
**យំ វេ ហិតញ្ច សាធុញ្ច តំ វេ បរមទុក្ករំ ។**

កម្មទាំងឡាយណា មិនល្អផង មិនជាប្រយោជន៍ដល់ខ្លួន

---

១.បើគ្រហស្ថ ចាប់តាំងអំពីកើតមក ធ្វើតែអកុសលកម្មបថទាំង ១០ បើបព្វជិតគិតអំពីថ្ងៃដែលបានឧបសម្បទាមក ត្រូវគរុកាបត្តិ យ៉ាងនេះឈ្មោះថា ភាពជាអ្នកទ្រុស្តសីលហួសហេតុ ។

ឯងផង កម្មទាំងនោះជនពាលធ្វើបានដោយងាយ កម្មណាជាប្រយោជន៍ផង ល្អផង កម្មនោះឯងជនពាលធ្វើបានដោយលំបាក។

១៣៤_ប្រារព្ធព្រះកាលត្ថេរ ហាមឧបដ្ឋាយិកាមិនឱ្យស្តាប់ធម៌ព្រះពុទ្ធ

**យោ សាសនំ អរហតំ អរិយានំ ធម្មជីវិនំ**
**បដិក្កោសតិ ទុម្មេធោ ទិដ្ឋឹ និស្សាយ បាបិកំ**
**ផលានិ កដ្ឋកស្សេវ អត្តឃញ្ញាយ ផល្លតិ ។**

បុគ្គលណាអប្បប្រាជ្ញា អាស្រ័យទិដ្ឋិដ៏លាមក ហាមឃាត់ពាក្យប្រៀនប្រដៅរបស់ព្រះអរិយបុគ្គលទាំងឡាយ ជាព្រះអរហន្តដ៏ប្រសើរ ដែលលោកមានប្រក្រតីរស់នៅដោយធម៌ ការហាមឃាត់របស់បុគ្គលនោះ រមែងចេញផល ដើម្បីសម្លាប់ខ្លួនឯង ដូចផ្លែឫស្សី (ចេញមកសម្លាប់ដើម) ដូច្នោះឯង ។

១៣៥_ប្រារព្ធចូឡកាលឧបាសក រួចខ្លួនពីការចោទប្រកាន់ថាជាចោរ

**អត្តនា ហិ កតំ បាបំ អត្តនា សង្កិលិស្សតិ**
**អត្តនា អកតំ បាបំ អត្តនា ហិ វិសុជ្ឈតិ**
**សុទ្ធិ អសុទ្ធិ បច្ចត្តំ នាញ្ញោ អញ្ញំ វិសោធយេ ។**

អ្នកធ្វើបាបដោយខ្លួនឯង រមែងសៅហ្មងខ្លួនឯង អ្នកមិនធ្វើបាបដោយខ្លួនឯង តែងបរិសុទ្ធស្អាតខ្លួនឯង សេចក្តីបរិសុទ្ធ និងមិនបរិសុទ្ធជារបស់ចំពោះខ្លួន អ្នកដទៃនឹងធ្វើអ្នកដទៃ ឱ្យបរិសុទ្ធពុំបានឡើយ ។

១៣៦_ប្រារព្ធព្រះអត្តទត្ថត្ថេរ ប្រឹងប្រែងបដិបត្តិធម៌បានសម្រេច

**អត្តទត្ថំ បរត្ថេន ពហុនាបិ ន ហាបយេ**
**អត្តទត្ថមភិញ្ញាយ សទត្ថបសុតោ សិយា ។**

បុគ្គល កុំគប្បីធ្វើប្រយោជន៍ខ្លួនឱ្យវិនាស ព្រោះប្រយោជន៍របស់អ្នកដទៃ សូម្បីច្រើន បើដឹងច្បាស់នូវប្រយោជន៍របស់ខ្លួនហើយ គប្បីខ្វល់ខ្វាយក្នុងប្រយោជន៍របស់ខ្លួន (នោះ) ។

ចប់

## នាមពុទ្ធបរិស័ទអ្នកមានឧបការៈ
## ក្នុងការខារធម្មទាន

| | |
|---|---|
| ១. ឧបាសក សំរ៉ង វណ្ណ៍ | ២. ឧបាសក យន្ត សួន |
| ៣. ឧបាសក គួង លាងផេង | ៤. ឧបាសក មួង យេន |
| ៥. លោកគ្រូ រស់ សូផាត | ៦. ឧបាសក អ៊ិត ប្រាំង |
| ៧. នាង ជា សុណាវី | ៨. នាង យុន សូនីម៉ា |
| ៩. ឧបាសិកា ហួនចាន់បូជា | ១០.ឧបាសក វ៉ាន់ ខុនណា |
| ១១. ឧបាសក គុយ សុធន | ១២.ឧបាសក ជឹង វ៉េងអ៊ាវ |
| ១៣. ឧបាសក ជឹម ជំនិត | ១៤.ឧបាសក ហាយ ចំរើន |
| ១៥. ឧបាសិកា ប៊ុត ម៉ាលី | ១៦.ឧបាសិកា ហាយ ច័ន្ទធរី |
| ១៧. លោកគ្រូ ជូ ប៊ុនយូ | ១៨.លោកគ្រូ លាក់ តុង |
| ១៩. ឧបាសក ង៉ូវ គា | ២០.ឧបាសក ម៉ៅ ផុន |

≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈



# I
## ស្ថានីយវិទ្យុ ផ្សព្វផ្សាយព្រះធម៌ព្រះពុទ្ធសាសនា
## ដោយសហគមន៍ធម្មទាន នៃពុទ្ធបរិស័ទ

| ខេត្ត~ក្រុង | វេលាផ្សាយ | ស្ថានីយវិទ្យុ |
|---|---|---|
| រាជធានីភ្នំពេញ | -04h50 mn<br>-05h00 mn<br>-05h30 mn<br>-12h10 mn<br>-18h00 mn<br>-19h00 mn<br>-20h00 mn<br>-20h30 mn | -FM 98 MHz<br>-FM 99 MHz<br>-FM 96 MHz<br>-FM 96 MHz<br>-FM 95 MHz<br>-AM 918 KHz<br>-FM 98 MHz<br>-FM 96 MHz |
| ក្រុងព្រះសីហនុ | -06h00 mn<br>-13h00 mn | -FM 92 MHz<br>-FM 92 MHz |
| ខេត្តបាត់ដំបង | -05h30 mn<br>-06h00 mn<br>-18h00 mn<br>-18h30 mn<br>-19h30 mn | -FM103.2MHz<br>-FM 92.7MHz<br>-FM 91 MHz<br>-FM 92.7MHz<br>-FM103.2MHz |

**សុខា សទ្ធម្មទេសនា**

ការសម្តែងនូវព្រះសទ្ធម្ម នាំមកនូវសេចក្តីសុខ។

**សុខោ បុញ្ញស្ស ឧច្ចយោ**

ការសន្សំបុណ្យ នាំមកនូវសេចក្តីសុខ ។

# II

## ស្ថានីយវិទ្យុ ផ្សព្វផ្សាយព្រះធម៌ព្រះពុទ្ធសាសនា
## ដោយសហគមន៍ធម្មទាន នៃពុទ្ធបរិស័ទ

| ខេត្ត-ក្រុង | វេលាផ្សាយ | ស្ថានីយវិទ្យុ |
|---|---|---|
| ក្រុងប៉ៃលិន | -18h00 mn | -FM 90.5 MHz |
| ខេត្តសៀមរាប | -05h00 mn<br>-18h30 mn | -FM 98 MHz<br>-FM 100.5 MHz |
| ខេត្តពោធិ៍សាត់ | -06h00 mn | -FM 98.5 MHz |
| ខេត្តកំពត | -05h00 mn<br>-18h30 mn | -FM 93.25 MHz<br>-FM 103.5 MHz |
| ខេត្តព្រះវិហារ | -18h30 mn | -FM 99 MHz |
| ខេត្តបន្ទាយមានជ័យ | -05h20 mn<br>-17h00 mn | -FM 96.5 MHz |
| ខេត្តស្វាយរៀង | -05h30 mn | -FM103.75MHz |

**បោះពុម្ព ៣០.០០០ ក្បាល**

**សម្រាប់ជាធម្មទាន**

**ក្នុងតម្លៃ ២០.១០០ ដុល្លារ**

**រោងពុម្ពមិត្តភាព កម្ពុជា-ជប៉ុន**



## សៀវភៅដែលរៀបរៀងដោយ

### ✍ ខ្ញុំព្រះករុណា ខ្ញុំបាទ ប៊ុត-សាវង្ស ✍

១. ជំនួយសតិភាគទី ១១
២. ជំនួយសតិភាគទី ១ ដល់ភាគទី ១០
៣. មនុស្សជាមួយនឹងការងារ
៤. សិក្ខាបទមនុស្សល្អ
៥. ពរ ៤ ប្រការ
៦. ព្រះពុទ្ធភាសិត ៤៣ គាថា
៧. ខ្លឹមសារគួរយល់ដឹង
៨. ព្រះពុទ្ធសាសនា
៩. កូនមាសឪពុក
១០. ម៉ែ !!!
១១. វិធីរម្ងាប់សេចក្តីក្រោធ
១២. សុខចិត្ត និងគុណភាពនៃជីវិត
១៣. មេរៀនជីវិត
១៤. ពាក្យពេចន៍ម៉ែឪ
១៥. បទពិចារណា
១៦. ពន្លឺធម៌ព្រះពុទ្ធ
១៧. បារមីភាគទី ១ និងខ្លឹមសារខ្លីៗ

# ជំណឹងអនុមោទនា

## ព.ស.២៥៤៩

ចំនួនគម្ពីរព្រះត្រ័យបិដកដែលពុទ្ធបរិស័ទជូនមកសម្រាប់ធ្វើជាធម្មទាន តម្កល់ទុកតាមវត្តនានា ចាប់ពី ព.ស.២៥៤៥ មកមានចំនួន ១៥៩ ចប់ ។

ចាប់ពីថ្ងៃ ១ រោច ខែអស្សុជ ព.ស.២៥៤៨ មកដល់
ថ្ងៃ ៧កើត ខែជេស្ឋ ព.ស.២៥៤៩ (រយៈពេល ៧ ខែ ២២ ថ្ងៃ)
ក្រៅអំពីពេលរៀននៅវត្តឧណ្ណាលោម និងវត្តសំពៅមាស
ខ្ញុំព្រះករុណា ខ្ញុំបាទ សម្តែងព្រះធម៌ទេសនាបាន ៤៤៥ បុណ្យ
បានប្រាក់បូជាព្រះធម៌ចំនួន ៣៨៦.៦៨០.០០០៛
(បីរយសែសិបប្រាំមួយលាន ប្រាំមួយរយប៉ែតសិបពាន់រៀល)
និង ១២.៣៤៨ ដុល្លារអាមេរិក
សរុបទាំងអស់ត្រូវជា ៩៩.០១៨ ដុល្លារអាមេរិក
ក្នុងនោះបានបន្ថែមប្រាក់បច្ច័យបួនចំនួន
៤៨.៦៦០.០០០ ៛ + ៧៣០ ដុល្លារអាមេរិក ។

ដោយឡែក ប្រាក់បច្ច័យបួន ចេញថ្លៃយានជំនិះព្រះសង្ឃ ដែលនិមន្តមករៀនព្រះធម៌ នៅវត្តឧណ្ណាលោម និងវត្តសំពៅមាស ក្នុងឆ្នាំនេះ អស់ចំនួន ៦.០៧៥ ដុល្លារអាមេរិក ។

សូមអនុមោទនា !!!





# ជំណឹងអនុមោទនា

## ព.ស.២៥៥០

ចំនួនគម្ពីរព្រះត្រ័យបិដកដែលពុទ្ធបរិស័ទជូនសម្រាប់ធ្វើជាធម្មទាន តម្កល់ទុកតាមវត្តនានា ចាប់ពី ព.ស.២៥៤៥ មកមានចំនួន ៣៦១ ចប់ ។

ប្រាក់បូជាព្រះធម៌នៅអាមេរិក និងកាណាដា រយៈពេល ៣ខែ បាន ៨៥.២១០ ដុល្លារ ក្នុងនោះថែមប្រាក់បច្ច័យបួន ១០.១៤០ដុល្លារ ។

ចាប់ពីថ្ងៃ ៩ រោច ខែភទ្របទ ព.ស.២៥៤៩ មកដល់
ថ្ងៃ ៥រោច ខែជេស្ឋ ព.ស.២៥៥០ (រយៈពេល ៨ ខែ ២៦ ថ្ងៃ)
ក្រៅអំពីពេលរៀននៅវត្តឧណ្ណាលោម និងវត្តសំពៅមាស
ខ្ញុំព្រះករុណា ខ្ញុំបាទ សម្តែងព្រះធម៌ទេសនាបាន ៤៧៩ បុណ្យ
បានប្រាក់បូជាព្រះធម៌ចំនួន ៣៩៧.៨៤៤.០០០៛
(បីរយកៅសិបប្រាំពីរលាន ប្រាំបីរយសែសិបបួនពាន់រៀល)
ស្មើនឹង ៩៩.៤៦១ ដុល្លារអាមេរិក
ក្នុងនោះបានបន្ថែមប្រាក់បច្ច័យបួនចំនួន
៥៥.៨២២.០០០ ៛ ស្មើនឹង ១៣.៩៥៥ ដុល្លារអាមេរិក ។

ដោយឡែក ប្រាក់បច្ច័យបួន ចេញថ្លៃយានជំនិះព្រះសង្ឃ ដែលនិមន្តមករៀនព្រះធម៌ នៅវត្តឧណ្ណាលោម និងវត្តសំពៅមាស ក្នុងឆ្នាំនេះ អស់ចំនួន ១០.០៧០ ដុល្លារអាមេរិក (ចំណូល ១.២១៧ ដុល្លារ)។

សូមអនុមោទនា !!!